ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី២៦**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក់ ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្កេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ....................ទំព័រ ១
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ផ្ដើមពី ....................ទំព័រ ១៧
សួរដោយ លោក សេង ប៊ុនឃាង ផ្ដើមពី ....................ទំព័រ ២៦
សួរដោយ លោក វីលៀម ស្មីត ផ្ដើមពី ....................ទំព័រ ៣៩
សួរដោយ លោក ហុង គឹមសួន ផ្ដើមពី ....................ទំព័រ ៥២
សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៦៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺន័ | បារាំង |
| លោកស្រី វ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# **កិច្ចដំណើរការនីតិវិធី**

[០៩:០៧:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើអង្គហេតុជម្លោះប្រដាប់អាវុធ ។ អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់តុរាងក្រចកសេះនៅទីនោះ ។

មុននឹងប្រគល់វេទិកានេះជូនទៅលោកស្រីចៅក្រម ខ្ញុំសូមរំឭកដល់ភាគីដែលចូលរួមនៅក្នុងដំណើរការពិភាក្សាដេញដោលជ្រាបថា ដោយមានសំណូមពរពីខាងអ្នកបកប្រែភាសា ដែលកត់សម្គាល់ឃើញថា មានការលំបាកក្នុងការបកប្រែ ដោយសារការនិយាយញាប់ ទីមួយ ។ ទីពីរ ការនិយាយពាក់ព័ន្ធជាមួយនឹងអត្តសញ្ញាណនៃឯកសារដែលបង្ហាញជាលេខ ERN ឬក៏លេខសម្គាល់ផ្សេងៗនោះ សូមឲ្យអាននិយាយឲ្យយឺត ហើយនិងសូមឲ្យអានឲ្យច្បាស់មួយៗ ដើម្បីឲ្យខាងអ្នកបកប្រែស្ដាប់យល់ ហើយនឹងអាចបកប្រែបានត្រឹមត្រូវ ។ ខ្ញុំសង្ឃឹមថា អស់លោក លោកស្រី ដែលបានចូលរួមនៅក្នុងនីតិវិធីជជែកដេញដោលនេះនឹងប្រឹងប្រែង ខិតខំទាំងអស់គ្នា ដើម្បីធ្វើយ៉ាងណាឲ្យបានល្អប្រសើរ ហើយនិងដើម្បីគោលបំណងពន្លឿននៃកិច្ចពិភាក្សារបស់យើងឲ្យបានឆាប់រហ័ស ។

ជាកិច្ចបន្តនេះ សូមជូនភារៈនេះទៅលោកស្រីចៅក្រម ខាតរ៉ាយច៏ ដែលពីម្សិលមិញលោកស្រីបានតាំងសំណួរដល់ជនជាប់ចោទពាក់ព័ន្ធនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ប៉ុន្តែនៅមានសំណួរមួយចំនួនទៀតដែលត្រូវសួរ ។ សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៏៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក កាំង ហ្គេកអ៊ាវ កាលពីម្សិលមិញ ក្នុងពេលដែលៗការសំណួរជាច្រើនចំពោះលោក លោកបានបង្ហាញថា ទោះបីជានៅពេលនេះលោកទទួលស្គាល់ថាវាមានជម្លោះប្រដាប់អាវុធកើតឡើងរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ គឺវាកើតឡើងនៅក្នុងអំឡុងពេលពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ ការដឹងរបស់លោកចំពោះជម្លោះប្រដាប់អាវុធនោះ គឺមានលក្ខណៈកម្រិត ។ មុនថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ តើត្រឹមត្រូវដែរឬទេ?

[០៩:១១:៣៧]

**ឆ៖** ពីថ្ងៃ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃ៦ មករា ១៩៧៦ និយាយរួម ខ្ញុំនៅចងចាំបានខ្លះថា ខ្ញុំនៅចងចាំបានថា មានជនជាតិវៀតណាមមួយចំនួនចូលមកដល់ស-២១ ។ ទីមួយ អាណិកជនវៀតណាមដែលរស់នៅទឹកដីកម្ពុជាជាយូរមកហើយ មានមកខ្លះ ដោយសារប្រព្រឹត្តខុសនឹងរដ្ឋអំណាចរបស់គេជំនាន់នុ៎ង ។ ទីពីរ អ្នកស៊ីវិលវៀតណាមចូលមក ហើយខាងកងទ័ពកម្ពុជាប្រជាធិបតេយ្យចាប់បានបញ្ជូនមកស-២១ ក៏មានដែរ ។ ហើយទីបី ផ្ទាល់ខ្លួនខ្ញុំមិនបានអើតមើលឃើញឈ្លើយសឹក ឬបុគ្គលទាំងអស់នោះ ដោយផ្ទាល់ភ្នែកទេ តែនៅចងចាំបានថា មានទាហានវៀតណាមមកតិចតួចណាស់ មុនថ្ងៃ៦ មករា ១៩៧៨ នេះ គឺខ្ញុំចាំអ៊ីចឹង ។ រយៈកាលបែងចែកជាពីរអ៊ីចឹង ។

ឯចំណែកការងារសួរចម្លើយ ហើយនិងការងារប្រើប្រាស់ឈ្លើយសឹកវៀតណាម ហើយនិងជនជាតិវៀតណាម ក៏មានបែងចែកជាពីរដាច់ពីគ្នាដែរ ។ ទីមួយ យើងខ្ញុំសួរ ឲ្យគេសួរ ហើយខាងលើក៏មិនទាមទារដែរ សួរបន្តិចបន្តួចទេ ព័ត៌មានយោធានឹងក៏សួរបន្តិចបន្តួច ហើយមិនយកចិត្តទុកដាក់អីផង ។ ខ្ញុំមិនដែលបានរាយការណ៍ព័ត៌មានយោធាអីទៅខាងលើទេ។ នេះជម្រាបដោយត្រង់ ។ ច្រើនតែឲ្យគេសួរអំពីទិសដៅមកយកការណ៍ យកការណ៍រឿងអី? ដូច្នេះ អារម្មណ៍ខ្ញុំពេលនោះ ហើយប្រហែលជាស្របនឹងសភាពការណ៍ ដែលបក្សបញ្ជាឲ្យធ្វើកាលនោះ គឺគិតតែអំពីការយកការណ៍ ។ យកការណ៍ពីស្អី? ចូលកន្លែងណា? ទោះអ្នកឯងមកជាប្រដាប់អាវុធក៏ដោយ មកជារូបភាពស៊ីវិលក៏ដោយ ធម្មតាក៏ដោយ ទោះអ្នកឯងពីដើមមកធាតុពិតជាទាហានរដ្ឋាភិបាលភាគខាងត្បូងវៀតណាមក៏ដោយ ចូលមកគឺយើងខ្ញុំសួរមួយរយៈកាលមុននោះគិតគូរត្រឹមតែការមកការណ៍ពីទឹកដីកម្ពុជា ហើយនិងមករកទាក់ទងនឹងអ្នកណាខ្លះនៅទឹកដីកម្ពុជា ។ នេះសំណួរដែលយើងខ្ញុំគិតគូរដំបូងរឿងមុនថ្ងៃ៦ មករា ។

[០៩:១៤:៥៥]

ហើយខ្ញុំអនុញ្ញាតតទៅទៀត ។ ក្រោយថ្ងៃ៦ មករា ១៩៧៨ យើងខ្ញុំគិតគូរពីរឿងផ្សាយវិទ្យុ ។ គេក៏បញ្ជាមកអ៊ីចឹង គោលការណ៍ដែលចង់ឲ្យឈ្លើយសឹកវៀតណាម ឬក៏ប្រជាជនវៀតណាមឆ្លើយហ្នឹង ក៏គេណែនាំពីលើមក ហើយខ្ញុំបញ្ជាទៅអ្នកសួរផ្ទាល់ទៀត។ ឲ្យគាត់សួរយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំបញ្ជាទៀត អាហ្នឹងរឿងហ្នឹងវាចែកជាពីរកំណាត់ដាច់ដោយឡែកអ៊ីចឹង ។ នេះគឺសូមជម្រាបលោកជំទាវតាមការដែលយើងខ្ញុំចងចាំបាន ។ ឯចំណែក ឯកសារវានៅយ៉ាងម៉េច អាហ្នឹងខ្ញុំសូមអាន សុំយល់ឯកសារដែលមាននៅសល់ ស-២១ តទៅទៀត ដើម្បីជម្រាបលោកស្រី លោកជំទាវឲ្យបានច្បាស់ ។ ខ្ញុំសូមបញ្ចប់បញ្ហានេះត្រឹមប៉ុណ្ណេះ ។

[០៩:១៥:៥២]

**ស៖** សូមអរគុណ ។ យើងត្រឡប់ពិនិត្យមើលទៅលើឯកសារនោះ នៅក្នុងឯកសារលេខ E78.27 គឺទាក់ទងទៅនឹងតារាងជាខ្មែរ-អង់គ្លេស គឺមានលេខ ERN00333610 រហូតដល់លេខ 00333628 ។ យើងឃើញមានបញ្ជីលម្អិតអំពីអ្នកទោសវៀតណាម ដែលបានចូលមកដល់ស-២១ ។ បញ្ជីនោះ គឺរួមមានជនជាតិវៀតណាមទាំងអស់ មិនថាពួកគេត្រូវបានចាត់ថា ជាប្រជាជនសាមញ្ញ ពួកចារកម្ម ឬក៏ទាហាននោះទេ ។ កាលវិភាគនេះ ទៅលើបញ្ជីនោះ គឺវាមានចំនួនជនជាតិវៀតណាម ដែលចូលមកស-២១ គឺមាន គឺយើងទទួលបានពីបុគ្គលិកមកពីស-២១ គឺចំនួនរហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ គឺមានចំនួន៣៤៥នាក់ ។ តើលោកទទួលយកចំនួនតួលេខនៃការវិភាគបែបនោះដែរឬទេ ចំពោះជនជាតិវៀតណាម?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមជម្រាបដោយស្មោះត្រង់ថា បញ្ជីនេះខ្ញុំអត់ទាន់បានឃើញនៅឡើយទេ ។ ប៉ុន្តែ បើនិយាយតាមការចងចាំ ហើយសន្និដ្ឋាន ចំនួននេះយើងខ្ញុំ ខ្ញុំបាទអាចទទួលបាន ប៉ុន្តែ សូមលោកជំទាវមេត្តាឲ្យខ្ញុំបាទ បានឃើញបញ្ជីនេះដោយផ្ទាល់ភ្នែកផង ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំសូមសួរ ថាតើអាចបញ្ចាំងបញ្ជីនោះនៅលើអេក្រង់បានដែរឬទេ? គឺវាមានសមហេតុផលក្នុងការដាក់បញ្ចូលនៅក្នុងសំណុំរឿង តើលោកចង់បានលេខ ERN ឡើងវិញដែរឬទេ?

**លោក វីលៀម ស្មីត៖**

គឺយើងមាននៅក្នុងអេក្រង់របស់យើងហើយ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំស្នើសុំឲ្យខាងសោតទស្សន៍ធ្វើការភ្ជាប់អេក្រង់ទៅកាន់អេក្រង់របស់សហព្រះរាជអាជ្ញា ដើម្បីឲ្យជនជាប់ចោទមានលទ្ធភាពក្នុងការពិនិត្យមើលលើបញ្ជីនោះ ។

**ស៖** តើលោកចង់ឲ្យបញ្ចាំងមួយទំព័រម្តងៗនៅអេក្រង់នេះ ឬក៏យ៉ាងម៉េច?

[០៩:១៩:២១]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមឲ្យគេបញ្ចាំងទំព័របន្ទាប់តទៅ អានេះទំព័រទីមួយហើយ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។

[០៩:២០:០០]

**ឆ៖** សូមអរគុណ ។ សូមមេត្តាបញ្ចាំងតទៅទៀតចុះ ។ សូម១ បើអនុញ្ញាតសូមបញ្ចាំងបន្តទៅទំព័រ តទៅទៀត។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមបញ្ចាំងនូវទំព័របន្តបន្ទាប់ទៀត ដើម្បីឲ្យជនជាប់ចោទគាត់បានអានឈ្មោះនៅលើបញ្ជីទាំងនោះ ។ សូមអរគុណ ។

[០៩:២១:២០]

**ជនជាប់ចោទ៖**

សូមតទៅទៀត១១ ។ បាទ, សូមតទៅទៀត១ ។ សូមតទៅទៀត១១១១១ ។ សូមអរគុណ ។

[០៩:២៦:០៩]

**សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** តើលោកមានយោបល់អ្វីដើម្បីនឹងនិយាយទាក់ទងទៅនឹងបញ្ជីនេះទេ? ជាពិសេស គឺចំនួនសរុបដែលមានចំនួន៣៤៥នាក់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ចំនួនសរុបប៉ុណ្ណោះ ។ ខ្ញុំជឿ ជឿទាំងស្រុង ។ ចំនួនសរុប ៣៤៥នាក់ នេះខ្ញុំជឿ ជឿទាំងស្រុង ។

**ស៖** សូមអរគុណ ។ លោកក៏នឹងបានធ្វើការកត់សម្គាល់ផងដែរនៅក្នុងចំណោមអ្នកទោសអស់ទាំងនោះដែលជាជនជាតិវៀតណាម ត្រូវបានកត់បញ្ជីថា បានចូលមកមុននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ក្នុងចំណោមជនជាតិវៀតណាមទាំងអស់នេះ មានមួយចំនួន ដែលនៅក្នុងបញ្ជីនេះ ចូលមកក្នុងទឹកដីកម្ពុជាមុន (សុំទោស) មកដល់ស-២១ មុនថ្ងៃ៣១ ធ្នូ ១៩៧៨ មែន ។

ខ្ញុំនិយាយមិញខុសហើយ១ មុនថ្ងៃ៣១ ធ្នូ ១៩៧៧ ខ្ញុំនិយាយមិញ គឺ១៩៧៨ ខ្ញុំនិយាយខុសហើយ សូមកែ ។

**ស៖** សូមអរគុណ ។ ហើយឈ្មោះទាំងប៉ុន្មានទៀតដែលនៅសល់នោះចំនួនភាគច្រើនរបស់អ្នកអស់ទាំងនុ៎ង គឺមិនមានកាលបរិច្ឆេទពិតប្រាកដដែលបានចូលមកដល់កម្ពុជានោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ក្នុងបញ្ជីនេះមានឈ្មោះអ្នកមកដល់ ស-២១ តែមិនមានកាលបរិច្ឆេទចូល ។ ពិត ។

**ស៖** ហើយអ្នកដែលនៅសល់ផ្សេងទៀតនោះដែលមានចំនួនច្រើនដែរ បានមកដល់ ស-២១ នៅក្នុងអំឡុងឆ្នាំ១៩៧៨ តើជាការត្រឹមត្រូវដែរ ឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយអំមិញនេះ ខ្ញុំអត់បានរាប់ ប៉ុន្មានជាប៉ុន្មានទេ ប៉ុន្តែពិតជាមានអ្នកដែលមកដល់ក្នុងអំឡុងឆ្នាំ១៩៧៨ មែន ។

[០៩:២៩:០៧]

**ស៖** តើលោកមានបានធ្វើការកត់សម្គាល់ផងដែរទេថា ការរៀបរាប់អំពីមនុស្សអស់ទាំងហ្នឹងគឺស្ថិតនៅក្នុងក្រុបបីធំៗ គឺជាទាហាន ជាចារកម្ម ហើយនិងជាជនជាតិវៀតណាម តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកជំទាវ ។ អរគុណ ។

**ស៖** បើសិនជាយើងពិនិត្យមើលទៅលើឯកសារ E68.3.1 ដែលជាតារាងឧបសម្ព័ន្ធដែលមានលេខ ERN00333650 ហើយតារាងនេះប្រហែលជានឹងអាចត្រូវបានដាក់បង្ហាញនៅលើអេក្រង់ផងដែរពីកុំព្យូទ័ររបស់ខាងសហព្រះរាជអាជ្ញា ។ តារាងនេះ គឺបង្ហាញអំពីសមាសភាពនៃក្រុមដែលបាន ចូលមកនៅក្នុងស-២១ ហើយត្រូវបានបែងចែកជាបីក្រុម គឺមួយក្រុមនោះដែលមានពណ៌ស្វាយ គឺ តំណាងឲ្យកងទ័ពវៀតណាមដែលមានចំនួនសាមសិប្រាំភាគរយ ។ ហើយផ្នែកពណ៌ក្រហមវិញ គឺតំណាងឲ្យចារកម្មវៀតណាមដែលមានចំនួនសែសិបពីរភាគរយ ហើយនិងពណ៌សាច់នោះ គឺជាជនជាតិវៀតណាមដែលមានចំនួនម្ភៃបីភាគរយ ។ តើលោកព្រមទទួលយកនូវការវិភាគនៃចំនួនអ្នកទោសសរុបដែលបានចូលមក ស-២១ ជាជនជាតិវៀតណាមនេះដែរ ឬទេ?

**ឆ៖** អរគុណលោកជំទាវ ដ្យាក្រាមនេះខ្ញុំមិនតវ៉ាទេ ។

**ស៖** សូមអរគុណ ។ ហើយលោកក៏ធ្លាប់បានបង្ហាញផងដែរថា ចំនួនភាគច្រើននៃទាហានវៀតណាមដែលបានចូល ស-២១ នៅក្នុងអំឡុងឆ្នាំ៧៨ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** អរគុណលោកជំទាវ ។ ពិតមែន ចូលមកក្នុងអំឡុងឆ្នាំ១៩៧៨ ភាគច្រើនជាទាហាន ។

**ស៖** ហើយយើងក៏បានឯកភាពគ្នាផងដែរថា ពួកគេបានមកពីសមរភូមិមុខ តើត្រឹមត្រូវដែរឬទេ?

[០៩:៣១:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពិត ខ្ញុំសូមទទួលស្គាល់ដោយឥតប្រកែក ។

**ស៖** ហើយពួកគេបានចូលមកស-២១ ដោយស្លៀកពាក់ជាឯកសណ្ឋានយោធាផងដែរ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** សូមគោរពលោកជំទាវ! ខ្ញុំមិនតវ៉ាទេ ក៏ប៉ុន្តែគ្រាន់តែសុំបញ្ជាក់ថា ខ្ញុំអត់បានទៅឃើញផ្ទាល់ភ្នែកទេ១ ។ ជឿ១ហើយ ។

**ស៖** ក៏ប៉ុន្តែនៅពេលនុ៎ងជាពិសេស គឺនៅដើមឆ្នាំ ១៩៧៨ លោកបានដឹងយ៉ាងពិតប្រាកដថាមានចំនួនកាន់តែច្រើនឡើងនៃទាហានវៀតណាមត្រូវបានបញ្ជូលមកនៅស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ចាប់តាំងពីថ្ងៃ៦ មករា ដែលយើងខ្ញុំចងចាំកាលបរិច្ឆេទនេះជាងគេ ទាហានវៀតណាមចេះតែមក មកកាន់តែច្រើនឡើង១ នេះជារឿងពិតដែលយើងខ្ញុំនៅចងចាំ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។ ផ្នែកសោតទស្សន៍អាចត្រឡប់អេក្រង់ហ្នឹង មកទិដ្ឋភាពធម្មតាវិញ ។ នៅពេលដែលទាហានវៀតណាមអស់ទាំងនេះចូលមកស-២១ លោកក៏បានប្រាប់ពួកយើងផងដែរថា ចាប់តាំងពីឆ្នាំ១៩៧៨ មកលោកបាន ត្រូវបានអញ្ជើញដើម្បីឲ្យធ្វើការចាក់ផ្សាយសំឡេងរបស់ពួកគេតាមវិទ្យុ តើខ្ញុំអាចនិយាយថា ការផ្សាយសំឡេងតាមវិទ្យុនេះ គឺជាការឃោសនាមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បក្សកុម្មុយនីស្តកម្ពុជា ប្រាកដជាប្រើសំឡេងវៀតណាមភាសាវៀតណាមសម្រាប់ឃោសនា តែប៉ុន្មុ៎ងឯងទេ នេះគឺសូមបញ្ជាក់ប៉ុណ្ណោះ ។ សូមអរគុណ ។

**ស៖** បើដូច្នេះមែន តើលោកបានណែនាំឲ្យទាហានវៀតណាមអស់ទាំងហ្នឹង ទទួលការសួរចម្លើយ ដូច្នេះ គឺលោកអាចទទួលបាននូវចម្លើយអស់ទាំងហ្នឹង ដើម្បីចាក់ផ្សាយតាមវិទ្យុនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមនិយាយឲ្យចំបញ្ហាដែលខ្ញុំបានទទួលពីគេមកឲ្យធ្វើ។ ទិសដៅគេកំណត់ពីលើមកច្បាស់លាស់ ។ ផ្ទាល់ខ្លួនខ្ញុំបានបញ្ជាទៅឲ្យអ្នកសួរ ធ្វើម៉េចឲ្យបានន័យមួយដែលខាងលើត្រូវការ គឺវៀតណាមឈ្លានពានកម្ពុជា ដើម្បីយកទៅដាក់សម្ព័ន្ធឥណ្ឌូចិន។ នេះជារឿងពិត។

**ស៖** ហើយជាការពិតណាស់ គឺលោកបាននៅដាក់នូវទម្លាប់មួយ សម្រាប់ឲ្យអ្នកសួរចម្លើយក្នុងការសួរចម្លើយអ្នកទោសដែលជាឈ្លើយសឹកវៀតណាមនោះឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បាទ, មែន ។ ខ្លឹមសារនៃសេចក្តីសារភាពរបស់វៀតណាមនេះ យកផ្ញើទៅឲ្យពូនួន ។ ដូច្នេះ ខុសត្រូវយ៉ាងម៉េច គាត់កែលម្អជាបន្តបន្ទាប់ ។ ខ្ញុំកែតែខាងក្រោមជាបន្តបន្ទាប់ទៀត ។ ដូច្នេះ ទិសដៅដែលចង់បាននៅក្នុងការឃោសនានេះ ខាងលើកំណត់ច្បាស់លាស់។ ខ្ញុំខំរត់តាមបញ្ហានេះរហូត ។ សូមអរគុណ ។

**ស៖** ដូច្នេះជួនកាលចម្លើយសារហ្នឹង ត្រូវបានកែប្រែដើម្បីឲ្យបង្ហាញនូវភាពប្រសើរសម្រាប់ការឃោសនា តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! មានការកែប្រែបណ្តើរៗហូរហែ ។

**ស៖** ហើយទាក់ទងទៅនឹងបញ្ហាផ្នែកចាត់តាំងនោះ តើលោកដាក់ឈ្លើយសឹកជនជាតិវៀតណាមហ្នឹងនៅមួយផ្នែកពិសេសឬ នៅក្នុងបរិវេណស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បញ្ហានេះ ខ្ញុំអត់ដិតដល់ទេ ក៏អត់បានចេញបញ្ជាទៅឲ្យគេអនុវត្តយ៉ាងម៉េចដែរ ។ អានេះទុកឲ្យគេធ្វើទៅចុះ ។ ខ្ញុំអត់បាន ឆ្លើយពេលនេះអត់រួចទេ មានតែខាងក្រោមគេជួយ ថាត្រឹមណា ឬមិនមែន ។ អាហ្នឹងជម្រាបប្រសាសន៍ប៉ុណ្ណឹង ។

**ស៖** តើលោកបានចាត់តាំងអ្នកសួរចម្លើយជាក់លាក់ណាមួយ ដើម្បីសាកសួរទាហានវៀតណាមអស់ទាំងហ្នឹងដែរឬទេ?

**ឆ៖** សូមជម្រាបដោយស្មោះត្រង់ថា អ្នកដែលសួរចម្លើយទាហានវៀតណាម មានតែម្នាក់ទេ គឺបង ម៉ម ណៃ ។ ឯចំណែក អ្នកបកប្រែដែលខ្ញុំជួលគាត់ឲ្យចាត់តាំង គឺផា ថាចាន់ ដែលជាអ្នកបកប្រែឲ្យម៉ម ណៃ ហើយបង្រៀនបង ម៉ម ណៃ ភាសាវៀតណាមផង ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ហើយតើការសួរចម្លើយហ្នឹង គឺរួមទាំងការធ្វើទារុណកម្មផងដែរ ឬ?

[០៩:៣៧:៥៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ទារុណកម្មចំពោះបញ្ហាប៉ុណ្ណេះ អាចចៀសរួច បើភ្លាត់ក៏តិចតួចបំផុត ។ ហើយសារជាតិរបស់បង ម៉ម ណៃ ខ្ញុំនេះ មិនងាយធ្វើទារុណកម្មទេ ។ ដូច្នេះជាប្រចាំថ្ងៃ ខ្ញុំសូមនិយាយឲ្យត្រង់ឲ្យអស់ទៅចុះ ។ ជាប្រចាំថ្ងៃនៅកន្លែងសួរចម្លើយមានបីនាក់ បង ម៉ម ណៃ ជាអ្នកសួរ កិច្ចការអីនៅលើគាត់ ផា ថាចាន់ ជាអ្នកបកប្រែ ។ ទន្ទឹមនឹងខ្ញុំចាត់ទុកឲ្យ ចៅ សេង គាត់នៅរស់ក្បែរបង ម៉ម

ណៃ នេះបានឲ្យវាស្គាល់ខ្យល់អាកាសអីហ្នឹងគេដែរ នេះប៉ុណ្ណឹង ។ ដូច្នេះ ខ្ញុំជឿថា ទារុណកម្មតិចបំផុត ។ សរុបមកវិញ សូមសរុបជូនប៉ុណ្ណឹង ។

**ស៖** ហើយដោយសារតែគោលនយោបាយដែលត្រូវអនុវត្តនៅស-២១ នោះ ថាតើទាហានវៀតណាម អស់ទាំងហ្នឹង ទីបញ្ចប់គឺត្រូវបានសម្លាប់ឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! គ្មានរួចម្នាក់ទេ សុទ្ធតែត្រូវបញ្ជាឲ្យកម្ទេចទាំងអស់ ។

**ស៖** ដូច្នេះដើម្បីឲ្យខ្ញុំបញ្ជាក់ឲ្យបានច្បាស់នោះ គឺលោកបានធ្វើការវាយតម្លៃទៅលើចម្លើយសារភាពមួយចំនួនរបស់ទាហានវៀតណាមអស់ទាំងនោះ ។ ជាពិសេសនៅក្នុងអំឡុងឆ្នាំ១៩៧៨ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** អរគុណលោកជំទាវ ។ គឺពិតជាត្រឹមត្រូវហើយ ។ សូមចប់ ។

**ស៖** ខ្ញុំចង់ត្រឡប់ទៅប្រភេទអ្នកចារកម្មម្តង ។ ហេតុអ្វីបានជាអ្នកទាំងអស់នោះ ត្រូវបានគេចាត់ទុកថា ជាពួកចារកម្ម?

**ឆ៖** សូមជម្រាបលោកជំទាវ! ដែលគេចាត់ទុកជាចារកម្ម បើតាមខ្ញុំចាំ ដូចជាខាងលើកំណត់មក រឿងនេះមិនច្បាស់ទេ ក៏ប៉ុន្តែយើងអាចនិយាយបានមួយម៉ាត់ថា ខាងលើកំណត់មក ព្រោះមិនមានផែនការអីវ៉ែអធិកអធមទេ ។ ចូលមក បើថាទោះបីជាប្រដាប់អាវុធ ក៏វាងល្ងប លបៗ ។ ដូច្នេះ ខ្ញុំជឿថាការកំណត់ជាចារកម្ម គឺខាងលើគេប្រាប់មក អាហ្នឹងគិញយួន ។ គេនិយាយអ៊ីចឹង ។ អាហ្នឹងខ្ញុំប្រើពាក្យពីជំនាន់ហ្នឹងអ៊ីចឹងចុះ ។ សូមអរគុណ ខ្ញុំសូមចប់ប៉ុណ្ណេះ ។

**ស៖** នៅពេលដែលអ្នកចារកម្មទាំងអស់នោះ បានមកស-២១ ថាតើលោកមានបានរៀបចំចំពោះការសួរចម្លើយទៅដល់ពួកគេដែរឬទេ?

**ឆ៖** សូមបញ្ជាក់ថា នៅពេលដែលពួកចារកម្មចូលមកស-២១ ខ្ញុំបញ្ជាឲ្យបង ម៉ម ណៃ សួរចម្លើយ ។ មិនឲ្យអ្នកណាទៀតសួរទេ ព្រោះប្រាជ្ញាបណ្តុះបណ្តាលគាត់ឲ្យចេះភាសាយួន ហើយសួរចម្លើយជាពិសេសក្នុងបញ្ហាហ្នឹងតែប៉ុណ្ណោះ ចេះភាសាវៀតណាម ហើយជាពិសេសសួរ ដឹងឮ ហើយក្តាប់តែបញ្ហាវៀតណាមនេះ តែម្នាក់គត់នៅក្រោមការដឹកនាំរបស់ខ្ញុំតែប៉ុននុ៎ង ។

[០៩:៤១:៤៩]

**ស៖** ថាតើខ្ញុំអាចសន្និដ្ឋានថា លោកបានចេញបញ្ជាឲ្យមានការធ្វើទារុណកម្ម ឬក៏លោកអនុញ្ញាតឲ្យមានការសួរចម្លើយ ដោយមានការធ្វើទារុណកម្មទៅលើពួកចារកម្មទាំងអស់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ជាគោលការណ៍រួមរបស់បក្សកុម្មុយនីស្តកម្ពុជា ទារុណកម្មអាចប្រើក្នុងករណីចាំបាច់ ចៀសមិនរួចទេ ។ ដូច្នេះ ក្នុងបញ្ហាចារកម្មនេះ ពិតជាមាន តិច ឬច្រើន ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែសូមបញ្ជាក់ធាតុពិតរបស់បង ម៉ម ណៃ មិនងាយធ្វើទារុណកម្មទេ ។ សូមបញ្ជាក់ប៉ុណ្ណោះ សូមអរគុណ ។

**សៈ** តើលោកបាននិយាយថា លោកប្រាកដថា លោក ម៉ម ណៃ គឺមិនធ្វើទារុណកម្មចំពោះពួកគេ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមញែកបញ្ហានេះជាពីរ ដើម្បីឲ្យស្រួលស្តាប់ ។ ធាតុពិតរបស់បង ម៉ម ណៃ មិនងាយធ្វើទារុណកម្មទាល់តែសោះ នេះធាតុពិតរបស់គាត់ ។ ក៏ប៉ុន្តែ ករណីចាំបាច់ខ្លះ គាត់ធ្វើក៏តិចតួច នេះខ្ញុំសូមបញ្ជាក់ជូនរបៀបនេះ ។

**សៈ** នៅពេលដែលលោកធ្វើការវិភាគលើចម្លើយសារភាពរបស់បុគ្គលដែលត្រូវបានគេចាត់ថាជាពួកចារកម្ម ថាតើលោកបានពិនិត្យមើលសមាសភាព ឬចំណុចផ្សេងៗ ដែលគាំទ្រទៅលើការចោទប្រកាន់ថា ពួកគេជាចារកម្មនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះ ខ្ញុំបានពិតមើល ត្រង់ដែលឲ្យខ្ញុំចារលើសេចក្តីសារភាព ខ្ញុំដូចជាមិនបានចារទេ ។ ប៉ុន្តែ គ្រាន់តែមានអនុស្សាវរីយ៍ ដែលខ្ញុំនៅចងចាំ ។ មានចារកម្មចារបុរសវៀតណាមម្នាក់ ឆ្លើយថា ក្នុងខែនេះ កងទ័ពវៀតណាមមកវ៉ៃយកខេត្តនេះ ។ ក្នុងខែនោះកងទ័ពវៀតណាមមកវ៉ៃយកខេត្តនោះ ។ កាលណោះនៅស-២១ មានផែនទីតូចសម្រាប់ប្រើការ ។ ដល់ខ្ញុំយកទៅរាយការណ៍ជូនមេ លោកគ្រូសុន សេន គាត់សើច គាត់ថា បើយួនវាមកវ៉ៃយកអ៊ីចឹង យើងបានដឹងណាធ្វើស្រែសង្គមនិយម ធ្វើភ្លឺមួយហិកតាបួនជ្រុងនោះ ។ គាត់សើច ។ ដូច្នេះ ខ្ញុំក៏ឈប់គិតគូរពីរឿងហ្នឹងធ្ងន់ពេកទៅ វរៗ ខាងលើចោទថាខ្ញុំធ្លាក់ទៅក្នុងឧបាយកលឃោសនាចិត្តសាស្ត្ររបស់ខ្មាំង ។ ខ្ញុំក៏លែងគិតគូរទៅ ។

[០៩:៤៤:៤៥]

ប៉ុន្តែ ដល់ក្រោយមក ខ្ញុំបានយករឿងមួយទៀតទៅរាយការណ៍ជូនមេ ចារបៀបវ៉ៃរបស់កងទ័ពវៀតណាម គេកំណត់គោល មួយគឺអក្សរ “អ៊ិន” អក្សរវៀតណាម ថា “ង៉ាយ” គឺថ្ងៃ គេហៅ ថ្ងៃ ។ មុននឹងចាប់ផ្តើមវ៉ៃ គេកំណត់ ដកមួយ ឬដកពីរ ឬបូកមួយ ឬបូកពីរ ។ បើកាលណាគេកំណត់គ្នាអ៊ីចឹងហើយ ឧបមាថាកាលវ៉ៃលុកលើកនេះ បក្សណែនាំឲ្យកងទ័ពអង្គភាពអនុសេនាធំមួយនេះ បូកពីរ ដល់

អ៊ិន កំណត់មកថ្ងៃ៥តុលា កងទ័ពត្រូវតែវ៉ៃនៅថ្ងៃ៧តុលា ព្រោះវាប្ញូកពីរនោះ ។ អ៊ីចឹង អារឿងហ្នឹង ខ្ញុំបានរាយការណ៍ទៅលើ មេ ជូនមេម្តង ។

ដូច្នេះ សរុបមកអារឿងចារគិញ ចារបុរស ខ្ញុំនៅមានអនុស្សាវរីយ៍ តែប៉ុណ្ណឹងឯង ដែលខ្ញុំនៅចងចាំទាល់ឥឡូវ ។ ក្រៅពីនោះ ខ្ញុំអត់មានចងចាំអីគេ ប៉ុន្តែបើមានឯកសារមកអាហ្នឹងវាស្រួលរំឭក ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[០៩:៤៦:០៥]

**សៈ** អ៊ីចឹង យើងអាចមើលទៅលើឧទាហរណ៍មួយ ដែលលោកបានធ្វើការវិភាគទៅលើចំណុចនេះ គឺចម្លើយសារភាព ដែលជាភាសាខ្មែរ គឺជាចម្លើយសារភាពអ្នកទោសវៀតណាម ទ្រឹង យ៉ាំងឡាក់ គឺលេខ 00240048 ដល់លេខ 00240070 ។ នៅក្នុងនេះ គឺយើងឃើញមាន លេខERNផ្សេងទៀត លេខ00284002 ដែលវាហាក់ដូចជាលោកបានធ្វើចំណារលើចម្លើយសារភាព ទ្រឹង យ៉ាំងឡាក់ ហើយលោកបានធ្វើការសង្ខេបទៅលើចម្លើយសារភាពនោះ លោកអាចពិនិត្យមើលទៅលើលេខERN ចុងក្រោយ ដែលខ្ញុំបានអានអម្បាញ់មិញនេះ ។ តើលោកចង់ឲ្យបញ្ចាំងតាមរយៈអេក្រង់ដែរ ឬទេ?

**ឆ៖** លោកជំទាវ សូមអរគុណលោកជំទាវ ខ្ញុំសូមឲ្យមានការបញ្ចាំងតាមអេក្រង់ ។

**សៈ** នេះគឺជាលេខERNភាសាអង់គ្លេស គឺលេខ00284002 ។

**លោក វីលៀម ស្មីត៖**

ថាតើលោកស្រីចៅក្រមចង់បានភាសាអង់គ្លេស ឬភាសាខ្មែរ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

គឺខ្ញុំចង់បានភាសាខ្មែរ ។

**លោក វីលៀម ស្មីត៖**

ឯកសារដែលលោកស្រីចៅក្រមបានលើកឡើង គឺមានលេខ00240048 នោះរហូតដល់លេខ 00240070 គឺវាមានឯកសារចំនួនម្ភៃបីទំព័រ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំចង់ពិនិត្យមើលឯកសារចុងក្រោយ ដែលមានលេខERN00284002 ដែលហាក់ដូចជាភ្ជាប់ទៅនឹងចម្លើយសារភាពដើមដែលមានទំព័រច្រើននោះ ។ ហើយលេខERN គឺវាបង្ហាញអំពីចំណុចសង្ខេប និងហត្ថលេខារបស់ជនជាប់ចោទ ។ ដូច្នេះហើយ វាជាចំណុចល្អក្នុងយើងបញ្ចាំងភាសាខ្មែរ ។

**លោក វីលៀម ស្មីត៖**

យើងមានឯកសារសង្ខេប ។ ប៉ុន្តែ ចំណារទាំងពីរនោះ គឺត្រូវបានបកប្រែពេញលេញហើយ ហើយយើងបានស្នើសុំឲ្យមានការបកប្រែ បញ្ជាំងទៅលើចំណុចបកប្រែ បើសិនជាលោកស្រីចៅក្រម ត្រូវការនោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។

**លោក វីលៀម ស្មីត៖**

យើងបានរកឃើញឯកសារភាសាអង់គ្លេស យើងនឹងដាក់នៅក្នុងអេក្រង់ ហើយយើងក៏មានឯកសារភាសាខ្មែរពេញលេញ នៅចំពោះរបាយការណ៍នោះដែរ ហើយយើងមានបញ្ជីនៃរបាយការណ៍ពីរដែលគាត់បានធ្វើការចំណារនៅចុងទំព័ររបស់ជនចាប់ចោទ ។ អ៊ីចឹង គឺយើងប្រហែលជាអាចធ្វើការពិនិត្យទៅលើឯកសារនេះ ។

[០៩:៥០:០៧]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំចាប់អារម្មណ៍លើចំណាររបស់ជនជាប់ចោទ ដែលខ្ញុំជឿថាគឺមាន នៅក្នុងឯកសារលេខ 0024 0049 ។

**លោក វីលៀម ស្មីត៖**

យើងមាននៅលើអេក្រង់របស់យើងហើយ យើងរង់ចាំខាងសោតទស្សន៍ក្នុងការបញ្ជូន និងភ្ជាប់រូបភាព ។ លោកស្រីចៅគឺសូមឲ្យខាងសោតទស្សន៍ធ្វើការធ្វើការភ្ជាប់ទៅលើអេក្រង់ភ្លាម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** នៅពេលនេះលោកបានឃើញនៅលើអេក្រង់របស់យើងជាភាសាខ្មែរ គឺសេចក្តីសង្ខេបនៅលើចំណុចចំនួនប្រាំមួយ ។ ថាតើវាជាចំណុចសង្ខេបទាក់ទងទៅនឹងអ្នកទោសវៀតណាម ទ្រឹង យ៉ាំងឡាក់ ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! សេចក្តីសង្ខេបនេះពិតជារបស់ខ្ញុំ ទោះបីខ្ញុំមិនស៊ីញ៉េ ហើយខ្ញុំគ្រាន់តែដាក់ឈ្មោះក៏ដោយ ។ ហើយខ្ញុំសូមឆ្លើយជម្រាបលោកជំទាវថា នៅក្នុង “ខ” ទីពីរ មានមនុស្សបីនាក់ដែលឆ្លើយ ទីមួយ គឺ ទ្រឹង យ៉ាំងឡាក់ ទីពីរ គឺ ង៉ូវ យ៉ាំងឈុន ហើយទីបី ឡេ យ៉ាំងឡាក ។ ដូច្នេះ

នេះជាសេចក្ដីចំណាររបស់ខ្ញុំ ដែលខ្ញុំតែកាលណាខ្ញុំមានចារប៉ុណ្ណោះហើយ បញ្ជូនទៅលើហើយ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។ នៅក្នុងសេចក្ដីសង្ខេបក្រៅពីការកត់សម្គាល់ទៅលើបុគ្គលបីនេះដែលមកដល់នៅថ្ងៃទី ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយពួកគេបានចូលមកស-២១ នៅថ្ងៃ៥ ខែមេសា ឆ្នាំ១៩៧៦ ថាតើលោកបានធ្វើសេចក្ដីសង្ខេបចំពោះចម្លើយសារភាពរបស់ពួកគេដោយរៀបរាប់អំពីស្ថានភាពយោធារបស់ជនជាតិវៀតណាម ដែលបានរុញចូលប្រាំរយម៉ែត្រនៅតាមព្រំដែន។ ហើយការចាប់ខ្លួន ទ្រឹង យ៉ុំងឡាក់ ដោយតំបន់យោធា២៥ គឺគេបានបញ្ជូនបុគ្គលនេះមកស-២១ ។

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ សេចក្ដីសង្ខេបនេះវាអ៊ីចឹង ភារកិច្ចរបស់ពួកគិញទាំងបីនាក់នេះ គឺមកយកការណ៍ទីតាំងកងទ័ពខ្មែរនៅត្រង់ណា ចំនួនប៉ុន្មាន អាវុធស្អីខ្លះចូលមកទឹកដីខ្មែរចម្ងាយប្រាំរយម៉ែត្រពីព្រំដែន កន្លះគីឡូ។ យោធានតំបន់២៥ ចាប់ពួកនេះបាននៅថ្ងៃ២៩ ខែ២ ១៩៧៦ ។ រួចបានក្រោយមកទៀត មន្ទីរនគរបាលតំបន់២៥ បញ្ជូនមកស-២១ នៅថ្ងៃ៥ ខែមេសា ១៩៧៦ ។ ដូច្នេះវាជាងពីរខែ ។ ខាងតំបន់២៥ គេទុកនៅនុំងទាល់តែមានបញ្ជាពីលើ គឺពីអចិន្ត្រៃយ៍ឲ្យខាង២៥ផ្ញើមកស-២១ បាន១២៥ វាផ្ញើមក ។ ផ្ញើមកដល់ ស-២១ នៅថ្ងៃ៥ ខែមេសា ១៩៧៦ ឯចម្លើយនេះយើងខ្ញុំសរុបជូនទៅខាងលើវិញ នៅថ្ងៃ១០ ខែមេសា ១៩៧៦ ។ សរុបសង្ខេបខ្លី ហ្នឹងសូមជម្រាបជូនលោកជំទាវប៉ុណ្ណោះ ។

[០៩:៥៤:២៥]

**ស៖** ប្រសិនបើយើងត្រឡប់ទៅលេខ ERN00240053 ថាតើនេះគឺជាសេចក្ដីសង្ខេបដែលរៀបចំឡើងដោយលោកចំពោះចម្លើយសារភាពពួកចារកម្មវៀតកុង ដែលបានចូលមកកម្ពុជានៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៦ នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ នេះជាសេចក្ដីសង្ខេបរបស់ខ្ញុំ ។

**ស៖** នៅក្នុងសេចក្ដីសង្ខេបនេះ លោកបាននិយាយថា “ពួកចារកម្មដែលបានរៀបរាប់អំពីផែនការរួមដោយចង់ធ្វើការផ្លាស់ប្ដូរបង្គោលឡាក់ មកប្រាំមួយរយម៉ែត្រនៅក្នុងទឹកដីកម្ពុជា ឬក៏ចាប់យកវាលស្រែ ដើម្បីឲ្យប្រជាជនធ្វើការរកឧសនិងចាប់ត្រី ហើយធ្វើបង្កើតជាបញ្ហាផ្សេងៗ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពិត ។ នេះជាសេចក្តីសង្ខេបរបស់ខ្ញុំ ខ្លឹមសារក្នុងនេះខ្ញុំទទួលស្គាល់ទាំងអស់ ។

**ស៖** សេចក្តីសង្ខេបនេះ គឺធ្វើឡើងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៦ ត្រឹមត្រូវដែរ ឬទេ?

**ឆ៖** អរគុណ ត្រឹមត្រូវហើយ ជម្រាបប្រសាសន៍ ។

**ស៖** សូមអរគុណ ។ គឺយើងអាចផ្លាស់ប្តូរចរន្តរូបភាពមករូបភាពដើមវិញ ។

បន្ទាប់ពីបុគ្គលទាំងអស់នោះត្រូវបានគេកំណត់ថា ជាពួកចារកម្ម ហើយត្រូវបានគេសួរចម្លើយ ហើយប្រហែលរងទារុណកម្មផងដែរ ។ ថាតើពួកគេនោះត្រូវបានគេសម្លាប់ចោលដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ជាគោលការណ៍រួមឲ្យតែខ្មាំងគឺត្រូវតែកម្ទេច ។ ដូច្នេះ ពួកអស់នេះត្រូវបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជាខ្មាំងហើយ ។ ចៀសមិនរួចពីកម្ទេចទេ ។

**ស៖** ខ្ញុំចង់ចូលទៅដល់ប្រភេទជនជាតិវៀតណាមប្រភេទទីបី គឺជនស៊ីវិលវៀតណាម តើយើងអាចមើលឯកសារ E68.30 ដែលវាជាតារាងមួយថ្មី គឺមានលេខ ERN00333645 ហើយវាជាឯកសារ ហើយវាជាឯកសារភាសាខ្មែរ និងអង់គ្លេស គឺតារាងជាភាសាខ្មែរ និងអង់គ្លេស ។

[០៩:៥៨:២២]

**លោក វីលៀម ស្មីត៖**

ថាតើវាជាតារាង ឬក៏វាជាបញ្ជី?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

វាជាបញ្ជី ។

**លោក វាលៀម ស្មីត៖**

គឺខ្ញុំដាក់នៅក្នុង អេក្រង់ របស់ហើយ គឺវាស្ថិតនៅក្នុងប្រភេទដូចគ្នា គឺជាបញ្ជី ។

គឺខ្ញុំសូមការអនុញ្ញាតពីលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមបង្គាប់ឲ្យខាងសោតទស្សន៍ធ្វើបង្វែររូបភាពទៅកាន់រូបភាពរបស់អេក្រង់សហព្រះរាជអាជ្ញា។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** នៅពេលដែលយើងមើលបញ្ជីនេះ តើលោកអាចប្រាប់ខ្ញុំដែរឬទេ? ថាតើបុគ្គលក្នុងចំណោមនេះ គឺត្រូវបានចាប់ពីទឹកដីប្រទេសវៀតណាម? លោកអាចជម្រាបប្រសិនបើលោកចង់ឲ្យធ្វើការចូល

ទៅទំព័រមួយទៀត ។

**ឆ៖** អរគុណ, ខ្ញុំបានអានហើយ ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានដែរឬទេ? ថាតើមានជនជាតិវៀតណាមណានៅក្នុងបញ្ជីនេះដែលត្រូវបានចាប់ខ្លួនពីទឹកដីវៀតណាមនោះ?

**ឆ៖** ទីមួយយើងឃើញនៅលេខរៀងទីបី ថៅ កុសល ខ្មែរក្រោម តួនាទីអត់មានទេ ចាប់ពីស្រុកយួន ។ ទីបី យើងឃើញលេខរៀង៩៩ ដាច់ សួរ៉េ ក៏ចាប់ពីស្រុកយួនដែរ ។ ហើយទី១១ ដួ វ៉ាន់កូ អត់មាន១ ដាក់ពីណាមក-- សូមទោស, ដាញ់ ហេង ខ្មែរក្រោមដែរ ជាលោកសង្ឃចាប់មកពីខាងយួនដែរ ។ ហើយទី១៣ ដួ យ៉ាំងភូ ចាប់មកពីបាដុក ដូច្នេះពីប្រទេសវៀតណាមហើយបាដុកនេះ ។ ដួ យ៉ាំងតុង ក៏ពីបាដុកដែរ ។ អ៊ឹង រស់ស៊ីទួន អ្នកជំនួញក្រុងភ្នំពេញ កន្លែងចាប់ពីវៀតណាម ។ ឡាយ ឡេង ឡេង ប្រពន្ធ ប៊ុន ឈាង ចាប់មកពីខាងវៀតណាមដែរ ។ ដូច្នេះ ក្នុងចំណោមនេះមានប្រាំមួយនាក់ ក្នុងចំណោមដប់ប្រាំពីរនាក់នេះ មានប្រាំពីរនាក់មានចំណារក្នុងនេះ ថាចាប់ពីវៀតណាម ។ សូមអស់ ។

[១០:០២:២៧]

**ស៖** សូមអរគុណ ។ នៅពេលដែលអ្នកអស់ទាំងនេះត្រូវបានគេចាប់ខ្លួនហើយបញ្ជូនមកស-២១ តើពួកគេត្រូវបានសួរចម្លើយ និងអាចត្រូវបានគេធ្វើទារុណកម្មដែរឬទេ? ហើយក្រោយមកនឹងដែលត្រូវបានគេសម្លាប់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពួកនេះមកដល់ បើតាមខ្ញុំចាំទេ រំឭករឿងនេះឡើងវិញ គេយកមកសួរចម្លើយ មើលទៅអ្នកណាយល់ដឹងល្មមនឹងផ្សាយវិទ្យុកើត គេយកអ្នកនោះមកសួរ ។ ចំណែកឯអ្នកផ្សេងទៀត ទុកចោលទេ អត់បានសួរទេ ។ ដល់ចុងបញ្ចប់យកទៅកម្ទេចទាំងអស់ ។

**ស៖** ហើយតើពួកគេហ្នឹង ត្រូវបានសួរចម្លើយដោយអ្នកទោស ដោយអ្នកយាមដែលលោកបានចាត់តាំងឲ្យសួរចម្លើយវៀតណាមដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អ្នកយាមគ្មានសិទ្ធិសួរចម្លើយអ្នកទោសទេ ជនរងគ្រោះទេ។ ចំពោះដោយឡែក--

**ស៖** ខ្ញុំនឹងកែសំណួររបស់ខ្ញុំ ។ តើពួកគេនឹងត្រូវបានសួរចម្លើយ ដោយអ្នកសួរចម្លើយដែលលោកបានចាត់តាំងឲ្យសួរចម្លើយអ្នកទោសជាជនជាតិវៀតណាមនោះ ឬ?

[១០:០៤:០៥]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ប្រាកដ គឺបុគ្គលតែមួយហ្នឹង ដែលសួរចម្លើយជនជាតិវៀតណាម ។

**ស៖** ខ្ញុំក៏មានឃើញការកត់សម្គាល់ដែរ ថាមានជនជាតិវៀតណាមនោះ ទាំងប្រុសទាំងស្រីនៅលើបញ្ជីនេះ ។ តើមានកុមារជនជាតិវៀតណាមដែលត្រូវបានគេបញ្ជូនមកស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ចូលដល់បញ្ហាកុមារខ្ញុំក្លាប់មិនបានល្អិតទេ។ ក៏ប៉ុន្តែ បើសិនជាមានជាប់មកនឹងខ្លួនម៉ែឪ ជាគោលការណ៍ត្រូវតែកម្ទេចហើយ អត់មានទុកទេ ។

**ស៖** ហើយលោកមានគោលនយោបាយដោយមិនកត់ចូលក្នុងបញ្ជីនូវឈ្មោះកុមារៗ ដែលត្រូវបាន គេបញ្ជូនមកស-២១ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** រឿងកត់បញ្ជី កត់អីនេះ ខ្ញុំក្លាប់មិនជាប់ទេ ។ ក៏ប៉ុន្តែ ថាឲ្យបានណែនាំដូចជាអត់ណែនាំក៏ប៉ុន្តែ តាមការសង្កេតប្រហែលជាមានបញ្ហាហ្នឹងមែន ។

**ស៖** ដូច្នេះ នៅទីបញ្ចប់យើងមិនអាចដឹងថា តើមានកុមារជនជាតិវៀតណាមប៉ុន្មាននាក់ ដែលអាចត្រូវបានចាប់ខ្លួន ហើយនិងឃុំខ្លួន ហើយទីបញ្ចប់ត្រូវបានសម្លាប់នៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពិតជាខ្វះព័ត៏មាន យើងមិនអាចប៉ាន់ប្រមាណចំនួនបានទេសូមគោរព ។

**ស៖** សូមអរគុណ ។ ដូច្នេះជាសង្ខេបលោកបានទទួលស្គាល់ថា នៅក្នុងអំឡុងពេលពីដើមឆ្នាំនៃប្រតិបត្តិការរបស់ស-២១ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មានចំនួនអ្នកទោសវៀតណាមចំនួនបីរយសិបប្រាំនាក់ ដែលត្រូវបែងចែកជាបីក្រុមធំៗនោះ គឺត្រូវបានបញ្ជូនមក ស-២១ ហើយត្រូវបានសួរចម្លើយ ហើយជាញឹកញាប់ណាស់ត្រូវបានគេធ្វើទារុណកម្ម ហើយជាទីបញ្ចប់ គឺពួកគេត្រូវបានសម្លាប់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវ ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែសូមមានមតិបន្តិច សូមលោកជំទាវអធ្យាស្រ័យ ខ្ញុំចង់ប្រើពាក្យញឹកញាប់ ដែលត្រូវធ្វើទារុណកម្មទេ ។ ខ្ញុំចង់សូមលោកជំទាវមានប្រសាសន៍ថា ទារុណកម្មមាន ដោយករណីចៀសមិនរួច ខ្ញុំសូមជម្រាបប៉ុណ្ណេះ ។ សូមអរគុណ ។

**ស៖** នៅពេលដែលលោកជាប្រធានមន្ទីរស-២១ តើលោកមានបានដឹងថា ជាគោលការណ៍ទូទៅការប្រព្រឹត្តមកលើជនជាតិបរទេស ដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ការប្រព្រឹត្តិមកលើឈ្លើយសង្គ្រាមដែលត្រូវបានគេចាប់បានមកពីសមរភូមិ ហើយមកឃុំខ្លួននោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមមេត្តាលោកជំទាវមានប្រសាសន៍សួរខ្ញុំម្តងទៀត ខ្ញុំក្តាប់អត់បាន សំណួរអំមិញ សូមទោស ។

**ស៖** តើលោកមានបានដឹងពីច្បាប់អ្វីទេ អំពីការប្រព្រឹត្តិមកលើឈ្លើយសឹកសង្គ្រាមនោះ?

[១០:០៨:១៣]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បញ្ហានេះខ្ញុំសូមឆ្លើយជាពីរកំណាត់ ។ កំណាត់ទីមួយ អំពីគោលការណ៍អនុវត្តចំពោះឈ្លើយសឹក ខ្ញុំអត់បានរៀន អត់បានឃើញច្បាប់ណាទេ ដូចខ្ញុំបានជម្រាបលើកមុនអ៊ីចឹង សូម្បីតែសេចក្តីថ្លែងការណ៍ជាសាកលនៃសិទ្ធិមនុស្ស ខ្ញុំឃើញតែម្តងគត់ នៅពេលដែលខ្ញុំរៀននៅថ្នាក់កុមារដ្ឋានប្រហែលជាឆ្នាំ១៩៥១ ប៉ុនន៉ុងទេ ហើយក្រោយមករកទាំងឯកសារនេះមិនឃើញទៀតផង ។ ដូច្នេះ ទីមួយ គឺខ្ញុំអត់បានឃើញទេ ច្បាប់អន្តរជាតិរបស់យើងដែលនៅជាធរមានពេលនោះនិយាយអំពីបញ្ហាឈ្លើយសឹក ។ ទីពីរ ខ្ញុំសូមជម្រាបបញ្ជាក់ថា រឿងវៀតណាមហើយនិងកម្ពុជានេះ ដូចខ្ញុំរំឭកពីខាងដើមអ៊ីចឹង វៀតណាមកាប់ខ្មែរ នៅតំបន់២៥ ខ្មែរកាប់វៀតណាម ខ្ញុំទុកថា វារឿងស៊ីទៅស៊ីមក ។ ដូច្នេះ ម្យ៉ាងទៀតបញ្ហាគេប្រើមកហើយ អើធ្វើៗ ចៀសមិនរួច។

ដូច្នេះ វាមានបញ្ហាបីនេះ ទីមួយ គឺ ច្បាប់អត់បានយល់ ។ ទីពីរ ការទាស់ទែងខ្វែងគំនិតគ្នារវាងវៀតណាមនិងកម្ពុជា ខ្ញុំទុកជារឿងស៊ីទៅស៊ីមក ។ ទីបី គឺរឿងគេប្រគល់មកឲ្យធ្វើហើយ ធ្វើបើមិនធ្វើវាមិនកើត នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមអរគុណ ។

**ស៖** សូមអរគុណ។ អ៊ីចឹង លោកមិនបានដឹងអំពីច្បាប់ទាក់ទងទៅនឹងការប្រព្រឹត្តិមកលើឈ្លើយសឹកទេ ។ ចុះចំណែកលោកវិញ ទៅតាមការយល់ដឹងចំណេះដឹងផ្ទាល់របស់លោកនោះ តើលោកមានបានដឹងទេថា ឈ្លើយសឹកសង្គ្រាមគួរតែទទួលបាននូវកម្រិតនៃការប្រព្រឹត្តិមកលើ គឺមានន័យថា ការគោរព និងការទទួលខុសត្រូវលើសុខមាលភាពរបស់ពួកគេផងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងមិនដឹងវាពិតមែន ដូចខ្ញុំបានជម្រាបអម្បាញ់មិញអ៊ីចឹង រឿងដែលដឹង ហើយរឿងដែលខ្ញុំគិតជាប្រចាំ គឺថារឿងវៀតណាមនិងកម្ពុជា នេះវាស៊ីសងគ្នាទៅវិញទៅមក ។ ខ្មែរកាប់វៀតណាម វៀតណាមកាប់ខ្មែរ ជាហូរហែ។ ដូច្នេះ ខ្ញុំអត់មានបានគិតពីរឿងស្អីដែលច្បាប់អន្តរជាតិការពារទេ តែចូលមកដល់ហើយ គេឲ្យធ្វើម៉េច គឺធ្វើហើយ ព្រោះអាហ្នឹងវាជារឿងស៊ីទៅស៊ីមក វៀតណាមកាប់ខ្មែរ ខ្មែរកាប់វៀតណាម រយៈកាលនេះខ្ញុំយល់អ៊ីចឹង ។ សូមអរគុណ ខុសវាខុសហើយ ក៏ប៉ុន្តែការយល់ជំនាន់នុ៎ងវាអ៊ីចឹង ។

**ស៖** ដូច្នេះទាក់ទងទៅនឹងការបែងចែកពួកគេថាជា គិញវៀតណាម ឬក៏ជាជនជាតិវៀតណាម នោះ ហើយទៅតាមការយល់ដឹងផ្ទាល់របស់ខ្លួន តើលោកយល់ដឹងថា ការប្រព្រឹត្តិមកលើពួកគេហ្នឹង គឺជាអំពើមួយដែលខុសឆ្គងទាំងស្រុងនោះឬ?

[១០:១:៤០]

**ឆ៖** បើយើងនិយាយអំពីការយល់ដឹងកាលនោះ ខ្ញុំបានជម្រាបលោកជំទាវហើយ ខ្ញុំមិនយករឿងនេះញ៉ែងៗមកធ្វើជាលេសទៀតទេ បើយើងនិយាយតាមច្បាប់មនុស្សជាតិ មនុស្សធម៌អន្តរជាតិ វាខុសហ្នឹង វាខុសពេកណាស់ទៅហើយ ឧក្រិដ្ឋកម្មអស់ហ្នឹង ខ្ញុំអត់ប្រកែកទេ ។ នេះជារឿងពិត ហ្នឹងខ្ញុំសូមទទួល ។ នេះសូមបញ្ជាក់អ៊ីចឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ។ លោកប្រធានខ្ញុំអត់មានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម តើមានសំណួរអ្វីសួរដល់ជនជាប់ចោទទេ អំពីអង្គហេតុនេះ? សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំចង់បកត្រឡប់ទៅលើបញ្ហាជនជាតិស៊ីវិលវៀតណាមម្តង ។ ប្រហែលយើងអាចត្រឡប់មករូបភាពធម្មតានៅលើអេក្រង់វិញបាន ។ សូមអរគុណ ។

ឥឡូវនេះ ខ្ញុំចង់ឲ្យយើងពិនិត្យមើលឡើង វិញទៅលើបញ្ហាអ្នកទោសជាជនជាតិវៀតណាមនៅក្នុងប្រភេទដែលថា ជាជនជាតិស៊ីវិលវៀតណាម ពីព្រោះយើងមានបីប្រភេទគឺជាឈ្លើយសឹកវៀតណាម ជាគិញវៀតណាម និងជាជនជាតិស៊ីវិលវៀតណាម ហើយបាននិយាយថា ពួកគេភាគច្រើនត្រូវបានចាប់ខ្លួននៅក្នុងប្រទេសវៀតណាម ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់លាស់ថែមទៀតទេ ថាតើលក្ខខណ្ឌនៃស្ថានភាពនៃការចាប់ខ្លួនហ្នឹង វាកើតឡើងយ៉ាងដូចម្តេចដែរ? តើវាកើតឡើងវាយ៉ាងដូចម្តេច គឺបានកើតឡើងនៅក្នុងអំឡុងពេលប្រតិបត្តិការយោធាឬ? ហើយហេតុអ្វីបានជាជនជាតិវៀតណាមស៊ីវិលអស់ទាំងហ្នឹងត្រូវបានចាប់ខ្លួន?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! លក្ខណៈដែលនៃការចាប់ តើចាប់បែបម៉េច? ទ័ពរបស់កម្ពុជាប្រជាធិបតេយ្យចូលលុកទៅដល់ទឹកដីវៀតណាម ឬក៏ពួកយកការណ៍គេទៅឈ្លបចាប់? ខ្ញុំពេល

នោះមិនបានគិតគូរនឹកនាដល់រឿងហ្នឹងទេ ហើយក៏មិនបានដេញដោលសួរគេរឿងនុ៎ងដែរ ឲ្យគេបញ្ជូនមកហើយក៏ចាត់តាំងឲ្យគេសួរទៅ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកបាននិយាយថា អ្នកដែលត្រូវបានបញ្ជូនមកស-២១ ទាំងអស់ហ្នឹង គឺត្រូវបានចាត់ទុកថាជាខ្មាំង ។ នៅក្នុងចំណោមអ្នកដែលមានឈ្មោះក្នុងបញ្ជីជាជនជាតិស៊ីវិលនោះ គឺមានមនុស្សមួយចំនួនដែលត្រូវបានចាត់ទុកថា ជាលោកសង្ឃ ហើយលោកក៏បាននិយាយថា លោកសង្ឃម្នាក់នុ៎ងឯងនៅក្នុងបញ្ជីនេះ គឺជាខ្មែរក្រោម ។ អ៊ីចឹងសំណួររបស់ខ្ញុំនោះគឺថា តើគាត់ត្រូវបានបញ្ជូនមកស-២១ មកពីគាត់ហ្នឹង គឺចាត់ទុកថាជាខ្មាំងដោយសារគាត់ហ្នឹងជាលោកសង្ឃ ឬក៏មកពីថាគាត់ហ្នឹងជាខ្មែរក្រោម? តើមានគោលនយោបាយជាក់លាក់ណាមួយទេ ទាក់ទងទៅនឹងចំណុចនេះក្នុងការចាត់តាំងទៅលើស្ថានភាពដែលថា ពួកគេហ្នឹងជាលោកសង្ឃនោះ?

**ឆ៖** លោកមានប្រសាសន៍សួរខ្ញុំច្បាស់ហើយ អំពីគោលមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមអធិប្បាយដូចតទៅ៖

គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាចំពោះសាសនា ខ្ញុំបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេតរួចហើយ ប៉ុន្តែវានៅក្នុងសំណុំរឿងទី២ បើលោកចៅក្រមអនុញ្ញាតឲ្យខ្ញុំបញ្ជាក់ជូននៅពេលនេះត្រួសៗ ខ្ញុំនឹងបញ្ជាក់ជូន ។

ចំណែកទីពីរ និយាយអំពីប្រជាជនកម្ពុជាក្រោម ចលនាតស៊ូកម្ពុជាក្រោម និងបក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំចង់ជម្រាបបញ្ហានេះឲ្យច្បាស់លាស់ជូនលោកចៅក្រមដែរ ក៏ប៉ុន្តែ ទិដ្ឋភាពដែលយើងខ្ញុំប៉ាន់ប្រមាណនៅក្នុងឯកសារនេះ គឺបក្សកុម្មុយនីស្តកម្ពុជា គេចាត់ទុកអ្នកអស់នេះ ជាគិញៗ ។ ដូច្នេះ បញ្ហាទីមួយ អំពីបញ្ហាជាមួយនឹងសាសនា ហើយបញ្ហាទីពីរ ជាមួយនឹងចលនាកម្ពុជាក្រោម សូមលោកចៅក្រម មេត្តាពិចារណាឲ្យខ្ញុំឆ្លើយឬយ៉ាងម៉េច?

លោកចៅក្រមជាទីគោរព! ចំពោះពុទ្ធសាសនា ហើយនិយាយជារួមសាសនាទូទៅ ។ ប៉ុល ពត ប្រឆាំងនឹងសាសនាជាទូទៅ ។ ក៏ប៉ុន្តែ មាគ៌ាកិច្ចដំណើរការប្រឆាំងនេះ ប៉ុល ពត ឆ្លាតណាស់ ឆ្លាតជាងគេជាងឯង ។ ជាមួយពុទ្ធសាសនាចុះ ដែលជាសាសនាមានមនុស្សច្រើនលើសលប់នៅកម្ពុជា ប៉ុល ពត គាត់លើកមកថា របស់ដែលអាក្រក់ គឺ “លទ្ធិកម្មផល” ។ ខ្ញុំសូមតទៅទៀត ឯចំណែកលោកសង្ឃ ព្រះភិក្ខុសង្ឃមិនសាហារ ព្រោះព្រះភិក្ខុសង្ឃពុទ្ធសាសនាមិនសាហារ ព្រោះព្រះភិក្ខុសង្ឃក្នុងពុទ្ធសាសនាជាកូនកសិករ ។ ក្រពះរបស់លោកសង្ឃពឹងផ្អែកលើឆ្នាំងបាយកសិករ កសិករឲ្យរស់ ព្រះសង្ឃក្នុងពុទ្ធ

សាសនារស់ ។ ដូច្នេះ ក្នុងមួយជីវិតដែលខ្ញុំបាទធ្វើការងារនៅមន្ទីរនគរបាល គេមិនដែលបញ្ជូនមនុស្សមកដោយសារមូលហេតុជឿសាសនាទេ ។ ដោយឡែកក្រោយ១៧ មេសា ភ្លាម ខ្ញុំមានដំណឹងច្បាស់លាស់ថា គេលួចសម្លាប់ព្រះសង្ឃរាជ ហួត តាត ។

ហើយខ្ញុំសន្និដ្ឋានសរុបបានថា អ្នកដឹកនាំសាសនាសំខាន់ៗ គេលួចសម្លាប់ ។ ចំណែក លោកសង្ឃដែលនៅភ្នំពេញ ព្រះភិក្ខុសង្ឃដែលនៅភ្នំពេញ គេជម្លៀស គេដេញចេញទៅជនបទ ។ កូនកសិករផ្សេងទៀតគេចាប់ផ្សឹក អ្នកណាមិនព្រមផ្សឹក អាហ្នឹងបានគេគិតគូរ ។ អ្នកណាមិនព្រមផ្សឹក អាហ្នឹងបានគេគិតគូពីរឿងចាប់ចង ចាប់ផ្សឹកហើយបានគេចាប់ចង ។

ក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីៗ ដែលកូនចៅសហចៅក្រមស៊ើបអង្កេតគេធ្វើ ខ្ញុំឃើញមានភស្តុតាងមួយគួរឲ្យជឿ មានចៅអធិការមួយអង្គព្រះនាម ប្រាក់ សយ ចៅអធិការហ្នឹងព្រះនាម ប្រាក់ សយៗ ។ គាត់មិនព្រមផ្សឹកប្រហែលជាត្រូវគេកម្ទេច ។ សរុបមក រឿងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះសាសនា គឺអ៊ីចឹង ។ នេះខ្ញុំនិយាយអំពីមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះព្រះពុទ្ធសាសនា ។ តាមការសង្កេតបែបនេះ ខ្ញុំមិនមានជំនឿថា ព្រះសង្ឃកម្ពុជាក្រោមអង្គនេះ ត្រូវគេចាប់ដោយសារការប្រតិបត្តិសាសនាទេ ។

[១០:២៤:៣០]

ទីពីរ សូមនិយាយជម្រាបលោកចៅក្រមអំពីអាប្បកិរិយារបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះចលនាតស៊ូនៅកម្ពុជាក្រោម ។ បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកបក្សកុម្មុយនីស្តវៀតណាម ថាជាមិត្ត ជាមិត្តដែលមានទំនាស់ ។ ដូច្នេះ ខ្ញុំមិនដែលទាន់ឃើញភស្តុតាងណាដែលបញ្ជាក់ថា គាត់ទៅចាប់ដៃចលនាតស៊ូកម្ពុជាក្រោម ដើម្បីវាយបក្សកុម្មុយនីស្តវៀតណាមទេ ។ ខ្ញុំមិនទាន់មានឃើញភស្តុតាងណាដែលបញ្ជាក់ថា ខ្ញុំមិនទាន់ឃើញភស្តុតាងណាដែលបញ្ជាក់ឲ្យឃើញថា ប៉ុល ពត ចាប់ដៃចលនាតស៊ូខ្មែរកម្ពុជាក្រោមដើម្បីវាយបក្សកុម្មុយនីស្តវៀតណាមទេ ។ ខ្ញុំមានភស្តុតាងមួយផ្ទុយទៅវិញ រវាងឆ្នាំ១៩៧៧ ចលនាតស៊ូខ្មែរក្រោម គេបញ្ជូនប្រតិភូគេបីនាក់ តែប្រតិភូជាន់ទាបទេ មកសូមចរចាជាមួយបក្សកុម្មុយនីស្តកម្ពុជា សូមពឹងផ្អែកបក្សកុម្មុយនីស្តកម្ពុជាដើម្បីឲ្យជួយចលនាគេ ។ ខ្ញុំបានឲ្យគេរៀបចំឯកសារនេះស្រួលបួលណាស់ផ្ញើទៅខាងលើ ដល់ទៅខាងលើសម្រេចមកវិញ ឲ្យកម្ទេច ។ ដូច្នេះ ខ្ញុំមិននិយាយអំពីរឿងញ៉ែៗថាត្រូវតែកម្ទេចតាមបញ្ជាគេទេ ។ រឿងនេះវាពិត ។ ក៏ប៉ុន្តែ ខ្ញុំចង់បញ្ជាក់នៅពេលនេះគឺទោះបីគាត់មានទំនាស់ស្រួចស្រាល់ជាមួយនឹងបក្ស ។ រឿងដែលខ្ញុំចង់បញ្ជាក់ពេលនេះគឺថា រឿងដែល

ខ្ញុំចង់បញ្ជាក់នៅពេលនេះគឺ ប៉ុល ពត មិនចាប់ដៃចលនាតស៊ូខ្មែរកម្ពុជាក្រោមទុកជាមិត្តទេ ។

[១០:២៨:៣៣]

នេះគាត់ចាត់ទុកចលនាតស៊ូខ្មែរកម្ពុជាក្រោម ដែលធ្លាប់មានទំនាក់ទំនងជាមួយអាមេរិកាំងថាជាសត្រូវ ។ នេះជាចលនារួម ។ ដូច្នេះដោយឡែកបុគ្គលមួយនេះ ដែលគេចាប់ចូលមកគាត់ជាសង្ឃផង គាត់ជាកម្ពុជាក្រោមផងមិនដឹងជាមូលហេតុគិញ គាត់ធ្លាប់ចាត់តាំងឲ្យគេចូលមកស្រុកខ្មែរ ឬយ៉ាងម៉េច? អាហ្នឹងខ្ញុំអត់ប៉ានឆ្លើយបញ្ជាក់ទេ ឯកសារវារំលងទៅច្រើនឆ្នាំហើយ ។ សូមអត់ទោស ។

**ស៖** ខ្ញុំហាក់ដូចជាមិនយល់ច្បាស់សោះ ចំពោះអ្វីដែលលោកបានលើកឡើងប្រហែលជាបញ្ហាបកប្រែ ឬក៏យ៉ាងម៉េច? ប៉ុន្តែខ្ញុំហាក់ដូចជាយល់នូវសម្តីចុងក្រោយរបស់លោក ប៉ុល ពត បានពិចារណាថា ចលនាតស៊ូរបស់ខ្មែរក្រោមនោះ គឺជាផ្នែកមួយនៃខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ ដោយសារតែគាត់គិតថាអ្នកទាំងអស់នោះគឺវាមានសម្ព័ន្ធភាពជាមួយនឹងអាមេរិកាំង ។ ថាតើលោកនិយាយបែបនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ប៉ុល ពត ចាត់ទុកបញ្ហាហ្នឹងអ៊ីចឹង ។ សូមអរគុណ។ សូមចប់ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

ខ្ញុំនៅមានសំណួរមួយចំនួនទៀត តើយើងគួរតែសម្រាកនៅពេលនេះ ឬក៏សម្រាកក្រោយពេលខ្ញុំសំណួររបស់ខ្ញុំបញ្ចប់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតទៀតទៅ រហូតដល់ម៉ោងខ្វះដប់ប្រាំ ចាំសម្រាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** យើងបានលើកឡើងម្សិល ឬក៏ថ្ងៃណាមួយដែលយើង ខ្ញុំមិនសូវចាំច្បាស់ទេ យើងបាននិយាយអំពីបុគ្គលដែលជាសមាជិកនៃរណសិរ្សរួបរួមជាតិ ហើយលោកបានរៀបរាប់ថាសមាជិកបីនាក់នៅក្នុងរណសិរ្សនោះ គឺត្រូវបានគេដោះលែងចេញពីស-២១ ។ នេះគឺជាបញ្ហាលើកលែងលើករណីបុគ្គលបីនាក់នោះ ។ ដូច្នេះ តើអាចពន្យល់ជូនយើងខ្ញុំដែរឬទេ ហេតុអ្វីបានជាអ្នកទាំងបីនោះត្រូវបានគេដោះលែង? ហើយថាតើរណសិរ្សនោះ គាត់មានធ្វើជាតំណាងអ្វីសម្រាប់បក្សកុម្មុយនីស្តកម្ពុជា?

[១០:៣២:១២]

**ឆ៖** សូមអរគុណលោកចៅក្រមដែលលោកបានលើកសំណួរនេះៗ ។ ចលនាហ្វុលរ៉ូ ជាចលនាមួយដែលដំបូងឡើយបារាំងជាអ្នកបង្កបង្កើត ដល់ក្រោយមកខ្ញុំបានដំណឹងថា អាមេរិកាំងក៏ទៅក្ដាប់ចលនានេះដែរ ។ ដំបូងនៅក្នុងឆ្នាំ១៩៧៨ ដែរ ពួកហ្វុលរ៉ូៗ គេបានចាត់តាំងប្រតិភូជាន់ទាបម្នាក់ ឬពីរនាក់ បើតាមខ្ញុំចាំគឺពីរនាក់ មកទាក់ទងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ក្នុងសំណូមពរដូចចលនាខ្មែរក្រោមអ៊ីចឹង ។ ចម្លើយពី ប៉ុល ពត មកតាមរយៈ ពូនួន ក៏ដូចគ្នាដែរ ឲ្យកម្ទេច ។ មិនបានប៉ុន្មានខែ ឬប៉ុន្មានថ្ងៃទេ ហ្វុលរ៉ូ គេចាត់តាំងពីរនាក់មកទៀត។ ពួកពីរនាក់នេះទើបមកដល់ស-២១ ពូនួន ហៅខ្ញុំទៅធ្វើការ ។ ទៅដល់គាត់ប្រាប់ថា មិត្តឌុច អង្គការឲ្យ-- គាត់មានប្រសាសន៍ថា មិត្តឌុច អង្គការឲ្យទុកពួកហ្វុលរ៉ូ ពីរនាក់ហ្នឹង មិត្តកុំវ៉ៃណា ។ ដូច្នេះ ខ្ញុំក៏ឲ្យគេសួរស្រួលបួល លើកអំពីសំណូមពរអី ស្រួលបួលជូនទៅគាត់ ។

ដល់លើកសំណូមពរអីស្រួលបួលជូនទៅគាត់ គាត់រៀបចំឲ្យចេញដំណើរ ឲ្យគេជូនដំណើរទៅជួបម្ចាស់ដើមគេវិញ គឺទៅជួបអង្គការ ហ្វុលរ៉ូ វិញ ។ ពួកពីរនាក់នេះ ម្នាក់ឈ្មោះ អ៊ីពើង ពូនិល សក្តិបី។ ហើយម្នាក់ទៀតឈ្មោះ អ៊ី ផ្គេន ។ ពីរនាក់នេះ ខ្ញុំមិនទាន់បានលែងចេញផង មកម្នាក់ទៀត ។ ហើយគោលការណ៍តែពួក ហ្វុលរ៉ូ ដោះលែងហើយ ខ្ញុំស-២១ អនុវត្តគោលការណ៍ហ្នឹងទៅហើយ អត់សួរ ទុកជាមិត្ត ។

ខ្ញុំសូមនិយាយឲ្យជ្រុលបន្តិចទៅទៀត ចលនានេះនៅខ្ពង់រាបតែងង្វៀង ។ ដល់ក្រោយមកខ្ញុំឮផ្សាយតាមវិទ្យុខ្មែរក្រហម ដេហ្គាហ្វុលរ៉ូ ។ ខ្ពង់រាបនេះ វៀតណាមហៅថា ខ្ពង់រាបតែងង្វៀង ជនជាតិភាគតិច គេហៅថា ខ្ពង់រាបដេហ្គា ។ ខ្ពង់រាបនេះ វៀតណាមហៅ តែងង្វៀង ។ ចំណែកជនជាតិភាគតិច គេហៅខ្ពង់រាបនេះ ថាខ្ពង់រាប ដេហ្គា ។ ដេហ្គាៗ ។

**សៈ** សូមឲ្យលោកធ្វើការប្រកបឈ្មោះនោះបន្តិច នៅពេលដែលលោកលើកឡើងពីឈ្មោះនោះ?

**ឆ៖** សូមទោស ខ្ញុំមិនបានឃើញអក្សរពេញតួទេ ប៉ុន្តែ ឥឡូវខ្ញុំប្រកបតាមសំឡេងដែលខ្ញុំទទួលបាន *ដេអ៊ីហ្គេអា (DEGA)* ។ ដូច្នេះ កាលដែលខ្ញុំនិយាយហួសនេះ ដើម្បីបញ្ជាក់ថា ប៉ុល ពត ហើយនិង ហ្វុលរ៉ូ បានទាក់ទងគ្នា ។ ដោយសារតែ គាត់បានដោះលែងពីរនាក់ហ្នឹង ។ ហើយម្នាក់ទៀត អ៊ីបីអ៊ីបាញ ហ្នឹងរត់ទៅជាមួយនឹងខ្ញុំ ក្រោយ៧ មករា រត់ទៅជាមួយខ្ញុំ ទៅបែកគ្នានៅត្រង់ស្រុកលាជ ខេត្តពោធិសាត់ ។

[១០:៣៩:០៤]

សរុបមកវិញ ខ្ញុំសូមនិយាយអំពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងពួកហ្វុលរ៉ូ ។ ប៉ុល ពត គាត់នៅតែចាត់ទុកពួកហ្វុលរ៉ូ ជាខ្មាំង។ ទោះបីក្រោយ ៣១ ធ្នូ ១៩៧៧ ក៏ដោយ ក៏គាត់នៅចាត់ទុកពួកហ្វុលរ៉ូ ជាខ្មាំង ។ ដល់ពេលដែលទឹកចូលច្រមុះគាត់មែនទែន ទើបគាត់ចាត់ទុកពួកហ្វុលរ៉ូ ជាមិត្ត ។ ទ្រឹស្តីរបស់គាត់ទឹកចូលច្រមុះហើយ កុំថាបាច់ទៅដល់ពោង សូម្បីតែកូនដបមួយក៏តោងទៅ ។

ដូច្នេះ ខ្មាំងត្រូវតែកម្ទេច យ៉ាងច្រើនណាស់ត្រឹមទុកឲ្យរស់នៅក្នុងឋានៈជាអ្នកទោសរួចជីវិត ។ ទីពីរ មិត្តត្រូវតែឧបត្ថម្ភ ដោះលែង ជូនឲ្យទៅជួបមេវិញ ។ នេះគឺខ្ញុំសូមរាយការណ៍អំពីអាកប្បកិរិយានយោបាយរបស់ ប៉ុល ពត១ ចំពោះ ហ្វុលរ៉ូ វាប្រែប្រួលអ៊ីចឹង បានជាគាត់ក្រោយមក គាត់ដោះលែង ពីព្រោះគាត់ចាត់ទុក ហ្វុលរ៉ូ ជាមិត្ត ។

សូមអរគុណ សូមបញ្ចប់ចម្លើយរបស់ខ្ញុំប៉ុណ្ណេះ ។

**ស៖** តើលោកយល់ស្របដែរឬទេ ចំពោះការចាត់ទុកថា ហ្វុលរ៉ូ គឺជាកងកម្លាំងយោធា ហើយប្រសិនបើដូច្នោះមែននោះ តើលោកចាត់ទុកថា ហ្វុលរ៉ូ បានចូលរួមនៅក្នុងជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម?

**ឆ៖** ខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េចទេ ប៉ុន្តែ ខ្ញុំសូមរាយការណ៍ជូនមកអំពីការយល់ដឹងរបស់ខ្ញុំ ។ អ៊ីពើង ពូនិល ដែលបក្សកុម្មុយនីស្តកម្ពុជាឲ្យខ្ញុំដោះលែងហ្នឹងសក្តិបី ។ ឯចំណែក មេ ហ្វុលរ៉ូ ធំជាងគេហ្នឹងឈ្មោះ អ៊ីតាហាំ មីញ៉ុល១ ។ អ៊ីតាហាំមីញ៉ុល ជាឧត្តមសេនីយ៍ គេមានអាវុធ ឬគ្មានអាវុធ ខ្ញុំអត់បានដេញសួរទេ កាលនុ៎ង ។ ពីព្រោះដឹងថា គេឲ្យដោះលែងហើយអរ ត្រូវតែខំសម្រេចភារកិច្ចនេះឲ្យបាន ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយ សូមចាប់បន្តដំណើរការសវនាការទៀត ។

*[សវនាការសម្រាកពីម៉ោង១០:៤៤នាទី ដល់ម៉ោង ១១:០៨ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀតលើអង្គហេតុ នៃជម្លោះប្រដាប់អាវុធនេះ ។ ហើយមុននឹងជូនវេទិកានេះទៅលោកចៅក្រម ហ្សង់ម៉ាក ខ្ញុំសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជន ដែលបានចូលរួមនៅក្នុងអង្គសវនាការនៅថ្ងៃនេះថា កិច្ចដំណើរការស្តាប់សក្ខីកម្មលើសាក្សី KW09 ដែលយើងមានកាលវិភាគថានឹងធ្វើសវនាការ ស្តាប់សក្ខីកម្មរបស់គាត់នៅថ្ងៃនេះ ។ តាមការគណនាពេលវេលាសាជាថ្មីម្តងទៀតនេះ អង្គជំនុំជម្រះយល់ឃើញថា មិនអាចដំណើរការស្តាប់សក្ខីកម្មសាក្សី KW09 នៅថ្ងៃនេះបានទេ ដោយហេតុកិច្ចពិភាក្សាដេញដោលរបស់យើងដែលបានប្រព្រឹត្តទៅនេះមានការចំណាយពេលវេលាច្រើន លើសពីអ្វីដែលអង្គជំនុំជម្រះបានគណនាគ្រោងទុកនោះ ។ ហើយសាក្សីរូបនេះ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទអញ្ជើញគាត់មកផ្តល់សក្ខី-កម្មនៅក្នុងអំឡុងនៃអង្គជម្រះដំណើរការសវនាការ លើអង្គហេតុប្រតិបត្តិការស-២១ និងជើងឯក គឺនៅកាលៈទេសៈសមស្របណាមួយ ។

ដូច្នេះ មន្ត្រីតុលាការសូមជម្រាបជូនទៅខាងអង្គភាពគាំពារនិងសាក្សីអ្នកជំនាញ ដើម្បីចាត់ចែងរៀបចំជូនសាក្សី KW09 ត្រលប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ ។ ហើយការកោះហៅជាថ្មី គឺរង់ចាំកាលវិភាគសវនាការជាថ្មី ។

ជាកិច្ចបន្ត សូមប្រគល់វេទិកានេះជូនទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរសួរដល់ជនជាប់ចោទ ពាក់ព័ន្ធនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកអាចរំឭកប្រាប់យើងបានទេ អំពីថ្ងៃខែឆ្នាំដែល សុន សេន បានចាកចេញពីភ្នំពេញនោះ ហើយនិងថ្ងៃខែដែលលោកបានជួបជាមួយនឹង ពូនួន, អ៊ុំនួន នោះ?

**ឆ៖** រឿងនេះជារឿងចម្លែក ។ ដូច្នេះខ្ញុំចាំទាំងទីកន្លែង ខ្ញុំចាំទាំងថ្ងៃដែលខ្ញុំទៅជួប ពូនួន គឺនៅថ្ងៃ១៥ សីហា ១៩៧៧ ហើយទីតាំងគឺនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មិនមែននៅជាន់ផ្ទាល់ដីទេ គឺនៅជាន់ខាងលើ ។ ដូច្នេះ ខ្ញុំសុំបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមចប់ ។

[១១:១៣:០០]

**ស៖** មិនចាំបាច់ផ្តល់ព័ត៌មានពិស្តារឲ្យខ្ញុំទេ គ្រាន់តែខ្ញុំចង់ដឹងអំពីថ្ងៃខែឆ្នាំតែប៉ុណ្ណោះ ។

តើលោកដឹងពីហេតុផលអ្វីទេដែល សុន សេន បានចាកចេញពីភ្នំពេញ ហើយតើលោកមានបានដឹងថា គាត់ទៅទីណា ហើយទៅធ្វើអ្វីនៅកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពេលដំបូងហ្នឹង ទិសដែលគាត់ទៅ មិនដឹងជាទៅខាងមេមត់ ដើម្បីរៀបចំទីតាំង ឬរៀបចំកម្លាំងយ៉ាងម៉េចក៏មិនដឹងទេ ។ ដល់ក្រោយមកឃើញមកទារយកមិត្តហ៊ី ទៅទៀតទៅជួយការពារមន្ទីររបស់គាត់ ។ ហើយបន្ទាប់មក ឮគាត់ទូរស័ព្ទពីខ្ញុំ មកខ្ញុំពីអ្នកលឿង គាត់មកនៅអ្នកលឿង បោះទីតាំងមួយនៅអ្នកលឿង ។ ដូច្នេះ ខ្ញុំដឹងប៉ុននុំង ។

**សៈ** តើទីតាំងដែលកាត់ឈរនៅឯណា?

**ឆ៖** ដែលគាត់តេអូមកខ្ញុំគឺ អ្នកលឿង ។ លោកចៅក្រម អាចជ្រាបហើយ អ្នកលឿង គឺទៅតាមផ្លូវលេខ១ រហូតទៅដល់មេគង្គ ។

**សៈ** ហើយបន្ទាប់មកទៀត យើងអាចនិយាយថាទីតាំងហ្នឹងគឺនៅ ជិតព្រំដែនខ្មែរវៀតណាមឬ?

**ឆ៖** មិន១ជិតទេ ឆ្ងាយ ។ ត្រូវឆ្លងកាត់ខេត្តពីរ ។ អ្នកលឿងនៅក្នុងខេត្តកណ្តាល ឆ្លងពីអ្នកលឿង ឆ្លងទន្លេមេគង្គទៅ ទៅខេត្តព្រៃវែង ហើយបានឆ្លងពីព្រៃវែងទៅ បានទៅចូលដែនដីវៀតណាម ។ តាមខ្ញុំស្មានអ្នកលឿងមិនដល់មួយរយគីឡូម៉ែត្រពីភ្នំពេញទេ ។ មិនអ្នំអត់ប្តូរភ្លើសទេ មិនដល់មួយគីឡូម៉ែត្រពីភ្នំពេញទេ-- មិនដល់មួយរយគីឡូម៉ែត្រពីភ្នំពេញ ។ មិនដល់១ ។

**សៈ** សំណួរមួយទៀត ទាក់ទងទៅនឹងប្រធានបទផ្សេងមួយទៀត ។ ពីមុនមានបាននិយាយអំពីការសួរចម្លើយអ្នកទោសជាជនជាតិវៀតណាម ហើយលោកបានប្រាប់យើងថា ការសួរចម្លើយបែបហ្នឹងត្រូវបានធ្វើឡើង ដោយអ្នកសួរចម្លើយតែម្នាក់គត់គឺ ម៉ម ណៃ ។ ហើយនៅក្នុងសំណុំរឿងគឺមានចម្លើយសារភាពជាច្រើន ដែលបានធ្វើសេចក្តីព្រាងបកប្រែជាភាសាបារាំង នោះគឺជាចម្លើយសារភាពរបស់ជនជាតិវៀតណាម ។ តើលោកមានបានដឹងអំពីចម្លើយសារភាពជាភាសាបារាំង ដែលបានបកប្រែជាភាសាបារាំងនោះដែរឬទេ? ហើយតើនរណាគេជាអ្នកព្រាងចម្លើយសារភាពជាភាសាបារាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អ្នកដែលចេះបារាំងអាចសរសេរបាន គឺជនជាតិវៀតណាមម្នាក់ជាស័ក្តិពីររបស់ទាហានរបស់រដ្ឋាភិបាលភាគខាងត្បូងវៀតណាមឈ្មោះ វូ ឌឹងង៉ោ ។ មនុស្សនុំងចេះបារាំង ចេះអង់គ្លេស ។ បើមាន១ មានតែម្នាក់ហ្នឹងឯងដែលសរសេរ ។

[១១:១៨:១៧]

**សៈ** គឺមានចម្លើយសារភាពមួយចំនួនដែរ ដែលមានសរសេរជាភាសាបារាំងនោះ ។ ហើយលោកប្រធាន ខ្ញុំអត់មានសំណួរសម្រាប់ជនជាប់ចោទទៀតទេ ។

**ប្រធានអង្គជំនុំ៖**

បន្តទៅនេះ គឺដល់អង្គជម្រះត្រូវប្រគល់វេទិកានេះជូនទៅភាគី ដើម្បីធ្វើការដេញដោលជនជាប់ចោទលើអង្គហេតុនៃជម្លោះប្រដាប់អាវុធ ។ ហើយមុននឹងប្រគល់វេទិកា ខ្ញុំសូមរំឭកដល់ភាគីដែលចូលរួមនៅក្នុងការពិភាក្សាឲ្យបានជ្រាបថា អង្គហេតុដែលយើងបានដាក់ពិភាក្សានេះ គឺអង្គហេតុស្ដីពីជម្លោះប្រដាប់អាវុធ ។ និយាយជាចំគឺ ជម្លោះប្រដាប់អាវុធ រវាងកម្ពុជាប្រជាធិបតេយ្យនិងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យពី ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

ទីពីរ ដោយការកត់សម្គាល់របស់អង្គជម្រះឃើញថា ការកំណត់ការគណនាពេលវេលាក្នុងការធ្វើការសវនាការ មានការយឺតយ៉ាវដូចពីម្សិលមិញ និងថ្ងៃនេះ ដែលតាមផែនការគ្រោងទុក យើងរៀបចំគណនាពេលវេលាសម្រាប់ធ្វើសវនាការ ទាំងសាក្សីពីររូបផង ហើយត្រូវបានអាក់ខានមិនអាចធ្វើបានដោយហេតុផលពេលវេលា ដែលមានការអូសបន្លាយក្នុងការពិភាក្សាដេញដោល ។

[១១:២០:០៤]

ដូច្នេះ ខ្ញុំសូមរំឭកបញ្ជាក់ឡើងវិញថា អង្គហេតុនៃការជម្លោះប្រដាប់អាវុធនេះ ត្រូវញែកបានច្បាស់លាស់ រវាងអង្គេហេតុនៃជម្លោះប្រដាប់អាវុធ និងអង្គហេតុប្រតិបត្តិការស-២១ ។ ជាការពិតណាស់ នៅក្នុងការពាក់ព័ន្ធទៅនឹងរឿងហេតុនៃជម្លោះប្រដាប់អាវុធ វាផលដែលកើតឡើងនៅស-២១ ប៉ុន្តែ ប្រព្រឹត្តកម្មទាំងឡាយដែលកើតឡើងនៅមន្ទីរស-២១ ចំពោះជនជាតិវៀតណាម ទាំងជនស៊ីវិលទាំងឈ្លើយសឹកវៀតណាមនោះ ត្រូវបានចៅក្រម ខាគរាយថ៌ បានសួរដេញដោល ចំពោះជនជាប់ចោទហើយជនជាប់បានចោទឆ្លើយជាមូលដ្ឋាន មានលក្ខណៈជាទូទៅនុ៎ង ឃើញថា ច្បាស់លាស់សមល្មមដែលអាចសព្វគ្រប់ព័ត៍មាន ដែលយើងអាចទទួលយកបានហើយ ។ ដោយឡែកបញ្ហាផ្សេងទៀតទាក់ទិនជាមួយនឹងប្រព្រឹត្តកម្មជាក់ស្ដែង ដែលអង្គហេតុនេះ យើងនឹងទៅពិភាក្សាដេញដោលនៅក្នុងអង្គហេតុស្ដីពីប្រតិបត្តិការស-២១ និងជើងឯកដែលបន្ទាប់ពីអង្គហេតុជម្លោះប្រដាប់អាវុធនេះ ។ អ៊ីចឹងសូមភាគីដែលចូលរួមនៅក្នុងការតាំងសំណួរពាក់ព័ន្ធជាមួយនឹងអង្គហេតុជម្លោះប្រដាប់អាវុធហ្នឹង ត្រូវប្រុងប្រយ័ត្ន ហើយផ្ចិតផ្ចង់ក្នុងការតាំងសំណួរផ្សេងៗ ពាក់ព័ន្ធតែទៅនឹងអង្គហេតុទូទៅ ស្ដីពីជម្លោះប្រដាប់អាវុធប៉ុណ្ណោះ មិនឲ្យចូលជ្រៅទៅក្នុងប្រតិបត្តិការនៅមន្ទីរស-២១ទេ ។ ទោះបីមានការពាក់ព័ន្ធជាមួយនឹងជនជាតិវៀតណាម ដែលបានបញ្ជូននេះមកដល់ស-២១ ក៏ដោយ ទុកឱកាស ទុកអង្គហេតុ

នោះ ទៅជដែកពិភាក្សាដេញដោលនៅក្នុងអង្គហេតុក្រោយទៀត បន្ទាប់ពីអង្គហេតុនេះ ។

សូមអញ្ជើញ សហព្រះរាជអាជ្ញា តើមានសំណួរអ្វីសួរពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលបានលើកឡើងនេះ ចំពោះជនជាប់ចោទដែរឬទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក កាំង ហ្គេកអ៊ាវ លោកបានលើកឡើងពីម្សិលមិញថា ទំនាស់រវាងកម្ពុជា ហើយនិងវៀតណាម វាគឺជាទំនាស់រ៉ាំរ៉ៃ និងស្លាប់រស់ ។ តើនេះជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមែនដែរទេ?

**ឆ៖** ត្រូវហើយ វាជាមាគ៌ានយោបាយមួយដែលយើងខ្ញុំយល់ច្បាស់ថាវាអ៊ីចឹង ។

**ស៖** ហើយលោកបានដឹងពីការប្រយុទ្ធរវាងកងព័ទទាំងពីរហ្នឹងដែរទេ?

**ឆ៖** ដែលដឹងច្បាស់លាស់មែនទែន ចូលជាសង្គ្រាមពិតប្រាកដ គឺក្រោយថ្ងៃ០៦ មករា ដែលខ្ញុំចាំខ្ញុំដឹង ។

**ស៖** អ៊ីចឹង ថាតើលោកដឹងថាមានទាហានវៀតណាម ចូលឈ្លានពានកម្ពុជាអត់?

**ឆ៖** វៀតណាមចូលឈ្លានពានកម្ពុជា វាមកជាសង្គ្រាមពិតប្រាកដ នៅក្រោយរបស់ដែលខ្ញុំហៅថាថ្ងៃ០៦ មករា ១៩៧៨ ។

**ស៖** ហើយតើលោកមានទស្សនៈយ៉ាងណាដែរ ចំពោះទាហានវៀតណាមដែលចូលឈ្លានពានកម្ពុជាទាំងនោះ?

**ឆ៖** ខ្ញុំបានរាយការណ៍ជម្រាបលោកជំទាវ ខាតរាយថ៍ ចៅក្រមជំនុំជម្រះយើងរួចហើយថា រវាងកម្ពុជានិងវៀតណាម វាជារឿងស៊ីទៅស៊ីមក គេវ៉ៃយើង យើងវ៉ៃគេ ។ ខ្ញុំគិតអ៊ីចឹង ពេលនុ៎ង ។

[១១:២៤:១០]

**ស៖** តើនៅពេលនុ៎ង លោកគិតថា មានចិត្តថាស្អប់ទាហានវៀតណាមទាំងអស់នោះទេ?

**ឆ៖** អារឿងនេះ វាជាអារម្មណ៍ពេលនោះ លំបាករំឭកឡើងវិញណាស់ ក៏ប៉ុន្តែរឿងដែលខ្ញុំរំឭកឡើងវិញ ហើយនៅចាំមិនភ្លេច គឺរឿងគេកាប់យើង យើងកាប់គេ ឈ្លោះគ្នា មិនឈ្លោះគ្នា ។ ដូចខ្ញុំបានជម្រាបពីលើកមុន កាលពីសម័យដែលស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា អ៊ីចឹង ។ រឿងនេះវារ៉ាំរ៉ៃ បើសិនជាមាគ៌ាសហព័ន្ធឥណ្ឌូចិន វារស់នៅកម្ពុជា មាគ៌ាឯករាជ្យម្ចាស់ការរបស់ ប៉ុល ពត វាស្លាប់នៅកម្ពុជា នេះជានយោបាយដែលយើងខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអំមិញថា វាជាទំនាស់

ស្លាប់រស់ ហើយវាភ្ញុំអ៊ៃ ។ ភ្ញុំអ៊ៃយ៉ាងម៉េច? ដូចខ្ញុំបានជម្រាបរួចមកហើយ ប៉ុន្តែ អាន៉ុងវាឯកសារនៅអ៊ែ ០០២ ទេ ។ ក្រោយ១៩៥៤ ក៏ដោយ ក៏ ឡេ យន់ គាត់នៅតែទុកខ្លួនគាត់ជាបិតាឥណ្ឌូចិន នេះជារឿងពិត ។

[១១:២៥:៣៥]

ដូច្នេះ ប៉ុល ពត ខ្លួនឯងចង់បានបក្សមួយ ដែលខ្លួនមានឋានៈស្មើគ្នាជាមួយនឹងបក្សវៀតណាម មានឋានៈស្មើគ្នាជាមួយនឹងបក្សឡាវ មានឋានៈស្មើគ្នាជាមួយនឹងបក្ស ម៉ាក្ស-លេនីន ទាំងអស់ក្នុងលោកហ្នឹង ខ្ញុំយល់ឃើញអ៊ីចឹង ។ ដូច្នេះ ឲ្យខ្ញុំស្អប់ លក្ខណៈអីពិសេសដូចគ្មានទេ វានៅត្រឹមយល់ថា គេអ៊ៃយើង យើងអ៊ៃគេ គេសម្លាប់ខ្មែរ យើងក៏អាចស្លាប់វៀតណាមវិញបានដែរ ។

**ស៖** លោកបានលើកឡើងថា ប៉ុល ពត មានបំណងចង់ឲ្យបក្សកុម្មុយនីស្តកម្ពុជាហ្នឹង មានឋានៈជាស្មើជាមួយនឹងបក្សកុម្មុយនីស្តផ្សេងៗទៀត ។ អ៊ីចឹង ថាតើ ប៉ុល ពត មានចេញសេចក្តីថ្លែងរណ៍អ្វីទាក់ទងនឹងបញ្ហានេះដែរទេ?

**ឆ៖** រឿងថ្លែងការណ៍ជាទម្លាប់បក្ស ម៉ាក្ស-លេនីន នៅលើសាកលលោក គេមិនថ្លែងការណ៍ទទឹងទទែងទេៗ គេរក្សាសម្ងាត់ ។

**ស៖** ពីព្រោះខ្ញុំឃើញថា មានសេចក្តីថ្លែងការណ៍មួយរបស់ ប៉ុល ពត នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨ ដែលបានដកស្រង់ចេញពីសុន្ទរកថារបស់ ប៉ុល ពត ដែលជាលេខាគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយបានលើកឡើងថា ពួកវាបានប្រព្រឹត្តក្នុងលក្ខណៈអួតអាងព្រហើនកោងកាច និងឈ្លានពានបំផុត ដែលគេជឿថាជាបិតាឥណ្ឌូចិន និងជាបងធំឥណ្ឌូចិន ។ ពួកវាបានប្រកាសជាសាធារណៈថា ពួកអ្នកតូចតាចទាំងអស់នៅក្នុងឥណ្ឌូចិន ត្រូវតែគោរខ្លួន និងស្តាប់បញ្ជារបស់ខ្លួន ។ ហើយឯកសារនេះមាននៅក្នុង ERN ជាភាសាខ្មែរគឺ 00224837 រហូតដល់ 00224852 ហើយភាសាអង់គ្លេសគឺ 00008671 ដល់ 00008678 នៅក្នុងទំព័រទី២ នៃភាសាខ្មែរ ។ តើលោកបានដឹងសេចក្តីថ្លែងការណ៍នេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំបាទឆ្លើយនឹងសំណួររបស់លោកអំមិញនេះ គឺនឹកទៅដល់មុនថ្ងៃ៣១ ធ្នូ ១៩៧៧ ។ ឯចំណែក សេចក្តីថ្លែងការណ៍នេះ ចៀសមិនរួចពីខ្ញុំបានអាន បានឮយ៉ាងហោចណាស់ក៏បានឮតាមវិទ្យុដែរ តែវាភ្លេច ។ សូមអរគុណ ដែលលោកបានលើកបញ្ហានេះ មកសួរ ។

[១១:២៩:២៧]

**សះ** តើនៅក្នុងអំឡុងពេល កម្ពុជាប្រជាធិបតេយ្យកាន់អំណាចហ្នឹង តើលោកមានដឹងទេថា ជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិតេបយ្យ ហើយនិងវៀតណាមហ្នឹង មានប៉ុន្មានដំណាក់កាល សំខាន់ៗ តើលោកបានដឹងទេ? លើកតែចំណុចដែលសំខាន់ៗ ។

**ឆះ** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ដូចខ្ញុំបានបញ្ជាក់ហើយបញ្ជាក់ទៀត នៅជាមួយ នឹងលោកជំទាវ ខាតរាយថ៍ រួចហើយថា ដំណាក់កាលមានពីរ ។ ដំណាក់កាលទីមួយ គឺពី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃ០៦ មករា ១៩៧៨ អានេះពួកខ្ញុំ ខ្ញុំនិយាយ៦មករា ចេះតែជាប់ហើយ ព្រោះខ្ញុំចាប់ អារម្មណ៍តែអាហ្នឹងជាង ។ ក្នុងរយៈកាលនេះ ខ្ញុំគិតថា អើយើងប្រើពាក្យខ្មែរថា ការវ៉ៃទៅវ៉ៃមក គេវ៉ៃ យើង យើងវ៉ៃគេ តែតាមពិត វាជាភាសាដែលខ្ញុំនិយាយឲ្យស្រួលស្តាប់តែប៉ុនន៎ុងទេ។ ក៏ប៉ុន្តែ សិនជា មើលជាក់ស្តែងនៅពេលនោះ ខ្មែរលួចចូលទៅយកការណ៍ពីយួន យួនលួចចូលមកយកការណ៍ពីខ្មែរ អាហ្នឹងយើងនិយាយតាមភាសាជំនាន់នោះ ។ យើងទៅយកការណ៍ពីគេ ទៅលួចចាប់មនុស្សពីគេ ឬក៏ យ៉ាងម៉េចទៅអាហ្នឹងវាៗអ៊ីចឹង ។ គេចូលដីយើងលួចយកការណ៍ពីយើង គេវ៉ៃយើងដូចជានៅក្នុងសំណួរ ដែលខ្ញុំសរសេរជូនទៅលើហ្នឹង គេមកចង់បោះបង្គិតបង្គោលព្រំដែននេះ អាហ្នឹងវានេះហើយ ។ ហើយ តាមពិតជម្រាប លោកព្រះរាជអាជ្ញាថា រឿងអស់នេះ ខ្ញុំវាភ្លេចអស់ទៅហើយ ។ រឿងដែលខ្ញុំនៅចាំគឺ ទំនាស់នយោបាយវាដើរតួ អារឿងលួចចូលព្រំដែន បង្គិតព្រំដែនអីៗយ៉ាងម៉េច ខ្ញុំគិតជារឿងកំប៉ិកកំប៉ុក ទេ ។ ទំនាស់នយោបាយ វាដើរតួគឺគេចង់យកយើងជាសហព័ន្ធឥណ្ឌូចិន ហ្នឹងហើយដែលខ្ញុំចេះតែ និយាយថា ទំនាស់ ប៉ុល ពត, ឡេ យន់ នេះខ្ញុំនិយាយឲ្យចំបញ្ហាអ៊ីចុះ មិនសំដៅលេខាបក្សវៀតណាម ទាំងអស់សុទ្ធតែអ៊ីចឹងទេ ។ ទំនាស់ ប៉ុល ពត ឡេ យន់ ជាទំនាស់ស្លាប់រស់ មួយចង់កសាងសហព័ន្ធ ឥណ្ឌូចិន មួយចង់ដាក់កម្ពុជាឲ្យនៅជាឯករាជ្យ នេះវាខុសគ្នាអ៊ីចឹង ។ ដូច្នេះ ទំនាស់នយោបាយដែល ខ្ញុំគិត អារឿងប៉ះគ្នាមួយគ្រាំងពីរគ្រាំងក្មេងៗនៅខាងក្រោម ខ្ញុំមិនសូវបានគិតទេ ខ្ញុំអត់បានតាមដានទេ ហើយចម្លើយដែលលោកជំទាវ ខាតរាយថ៍ បង្ហាញខ្ញុំអំមិញហ្នឹង ជារឿងពិត ខ្ញុំចារ ខ្ញុំសរសេរ ខ្ញុំដឹង ។ សូមអរគុណ ។

[១១:៣២:០៩]

**សះ** ចុះលោកបានដឹង អំពីផែនការប្រើកម្លាំង ដើម្បីបណ្តេញជនជាតិវៀតណាមចេញពីកម្ពុជា ដែរឬទេ? ព្រោះថានៅក្នុងឯកសារសៀវភៅខ្មៅ ដែលចងក្រងដោយកម្ពុជាប្រជាធិបតេយ្យ ត្រង់ទំព័រ

៦៤, ៦៥ បានសរសេរថា "បក្សកុម្មុយនីស្តកម្ពុជា បានស្នើសុំឲ្យវៀតណាមដកចេញមុនខែឧសភា ឆ្នាំ១៩៧៥ ។ ហើយត្រូវដកចេញឲ្យអស់នៅចុងខែមិថុនា ឆ្នាំ១៩៧៥" ហើយនៅក្នុងសៀវភៅនុ៎ង ក៏បានសរសេរផងដែរថា"មានតែវៀតណាមមួយផ្នែកប៉ុណ្ណោះដែលដកចេញពីកម្ពុជា" ហើយនៅក្នុងនុ៎ង បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជូនកងទ័ពដើម្បីបណ្តេញ អ្នកជនជាតិវៀតណាមហ្នឹងចេញ ។ តើលោកបានដឹងពីបញ្ហានេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បញ្ហានេះខ្ញុំអត់បានដឹងទេ ដូចខ្ញុំបានជម្រាបម្សិលមិញអ៊ីចឹង ។ សៀវភៅខ្មៅហ្នឹង ទាល់តែប្រហែលដូច៨៣ អ៊ីចឹង បាន១ខ្ញុំឃើញ សូម្បីតែសៀវភៅខ្មៅហ្នឹង ដល់ទៅឆ្នាំ១៩៨៣ បានខ្ញុំឃើញ ។ ដូច្នេះ រឿងទំនាស់ដេញចេញអីហ្នឹង ខ្ញុំអត់ដឹងទេ ។

**ស៖** យោងតាមការលើកឡើងកន្លងមក ឃើញថា លោកធ្លាប់បានចូលរួមប្រជុំ ឬក៏វគ្គបណ្តុះបណ្តាលជាមួយនឹងមេដឹកនាំធំៗ ។ តើនៅពេលនោះ គេបានលើកពីបញ្ហាជម្លោះប្រដាប់អាវុធជាមួយកម្ពុជា រវាងកម្ពុជា និងប្រទេសជិតខាង ឬក៏ប្រទេសណាផ្សេងទៀតដែរទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំអត់ដែលបានចូលរួមប្រជុំទេ នេះទីមួយ ។ ឯចំណែក មេហៅខ្ញុំទៅធ្វើការ គឺគេទៅឲ្យខ្ញុំរាយការណ៍ការងារ ហើយដើម្បីគេកែតម្រង់ការងាររបស់ស-២១ ។ ដូច្នេះ យើងខ្ញុំសូមប្រើពាក្យនេះ ថា "ធ្វើការ" តាមពាក្យខ្មែរក្រហមដែលនិយាយពីមុន ។ ឯចំណែក រឿងរៀនសូត្រ (សូមទោស) រឿងរៀនសូត្រ ខ្ញុំមែនទៅរៀន ។ ទៅរៀនសូត្រ គេច្រើនតែនិយាយអំពីទំនាស់ ឡេ យន់ ហើយនិង ប៉ុល ពត អំពីមាគ៌ាឯករាជ្យម្ចាស់ការនេះឯង នេះរឿងទៅរៀនសូត្រ ។ ឯចំណែក ការងារដែលគេហៅខ្ញុំទៅធ្វើការងារ គឺការងារស-២១ តើត្រូវធ្វើអ្វីខ្លះ? អ្នកឯងធ្វើអានេះខុស អ្នកឯងធ្វើអានេះត្រូវ គេកែតម្រូវអ៊ីចឹង ។

[១១:៣៥:០០]

**ស៖** ព្រោះថា ពីម្សិលមិញលោកបានលើកឡើងថា លោកបានចូលរួមក្នុងវគ្គមួយ ដែលមាន ប៉ុល ពត ជាអ្នកឧទ្ទេសនាម ហើយបាននិយាយថា ប៉ុល ពត បានលើកអំពីពីជ័យជម្នះរបស់កងទ័ពកម្ពុជាទៅលើកងទ័ពវៀតណាម តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា ដែលបានលើកសំណួរនេះ ។ បើតាមខ្ញុំហៅអាកន្លែងហ្នឹង ពេលហ្នឹងគេហៅថា មីទ្ទិង អបអរជ័យជម្នះកងទ័ពរបស់ ប៉ុល ពត ដែល ប៉ុល ពត គាត់ធ្វើថ្ងៃ៦ មករា ខ្ញុំចូល ។ នៅ ស-២១ កាលនោះមានតែខ្ញុំទេ ទៅម្នាក់ឯង ។

**ស៖** តើនៅពេលដែលលោកបានដឹង អំពីបញ្ហាជម្លោះនេះ ដែលថ្នាក់លើរបស់លោកបានប្រាប់ដូចលោករៀបរាប់អំមិញអ៊ីចឹង ។ លោកបានយកអាបញ្ហាជម្លោះហ្នឹង ទៅបង្ហាត់បង្រៀន ឬក៏បណ្តុះបណ្តាលដល់បុគ្គលិករបស់លោកដែរឬទេ?

**ឆ៖** អរគុណ ។ អ្វីដែលលេខាបក្សគេឧទ្ទេសនាមមកឲ្យខ្ញុំ ខ្ញុំជាលេខាគណៈកម្មាធិការ ស-២១ យកទៅបើកបង្រៀនភ្លាម ។ ខាងនយោបាយឲ្យកម្មាភិបាលនៅខាងក្រោមគេយល់ នេះជាក្រិតក្រមដែលយើងខ្ញុំត្រូវតែធ្វើ ។

**ស៖** តើនៅ ស-២១ ហ្នឹង មានមេដឹកនាំធំៗធ្លាប់ទៅបង្រៀនអំពីជម្លោះប្រដាប់អាវុធហ្នឹង នៅទីនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា លោកមានប្រសាសន៍សួរខ្ញុំ ថាតើនៅស-២១ មានមេដឹកនាំធំៗទៅបង្រៀន? ខ្ញុំជឿថា លោកសំដៅអំពីមេដឹកនាំអចិន្ត្រៃយ៍ចូលទៅបង្រៀននៅស-២១ ។ មានតែម្នាក់គត់ គឺលោកគ្រូ សុន សេន គាត់អញ្ជើញទៅបើតាមខ្ញុំចាំ គឺថ្ងៃ២៤ មេសា ១៩៧៧ ។

**ស៖** តើលោកមានដឹងទេ ថាមូលហេតុអ្វីបានជាគាត់ទៅបង្រៀននៅ ស-២១ ហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! លោកគ្រូ សុន សេន គាត់អញ្ជើញទៅនេះ យើងនិយាយថា បង្រៀនវាអត់ទាន់ចំទេ តាមពិតគាត់ទៅដឹកនាំធ្វើសន្និបាតប្រចាំឆ្នាំរបស់ស-២១ នៅ ស-២១ ដើម្បីឲ្យយល់ថាមតិខាងក្រោម គេមានមតិយ៉ាងម៉េចចំពោះការដឹកនាំរបស់ផ្ទាល់ខ្លួនខ្ញុំផង ។ ដូច្នេះ គាត់អញ្ជើញទៅហ្នឹងជាសន្និបាតប្រចាំឆ្នាំរបស់ ស-២១ មិនមានទៅបង្រៀនវគ្គនយោបាយដូចធម្មតាទេ ។

[១១:៣៨:០៧]

**ស៖** តាមដែលខ្ញុំអ្វីដែលលោកលើកឡើង បានន័យថា សុន សេន មិនមានកម្មវិធីទៅបង្រៀនអ្វីក្រៅពីវគ្គដែលលោកបានលើកអំមិញហ្នឹងទេ? អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ប្រចាំឆ្នាំៗនោះ គាត់បង្រៀនធម្មតាៗ គឺបង្រៀននៅមើល់១៩៧៧ ។ បង្រៀននៅក្បែរបុរីកីឡា អគារមួយដូចដំបូលទូកនោះ អាហ្នឹងគាត់បង្រៀនប្រចាំឆ្នាំនៅនុ៎ង ។ ឯចំណែកថ្ងៃ២៤ ខែមេសា ឆ្នាំ១៩៧៧ គាត់អញ្ជើញទៅនុ៎ង ដឹកនាំសន្និបាតប្រចាំឆ្នាំរបស់គណៈកម្មាធិការស-២១ ។

**ស៖** កាលពីម្សិលមិញលោកបានលើកឡើងដែរថា បក្សកុម្មុយនីស្តកម្ពុជាបានរក្សាការប្រយុទ្ធគ្នារវាងកម្ពុជាហើយនិងវៀតណាមហ្នឹង គឺរក្សាទុកជាសម្ងាត់ ។ តើលោកដឹងទេថា របបនេះមានគោល

បំណងអ្វីក្នុងការដែលមិនប្រកាសជម្លោះនេះជាសាធារណៈ?

**ឆ៖** នេះខ្ញុំវិភាគហើយសន្និដ្ឋានរាយការណ៍ជូនសហព្រះរាជអាជ្ញាទេ សន្និដ្ឋាន ជាសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ។ ខ្ញុំសន្និដ្ឋានថា ទំនាស់រវាងបក្សម៉ាក្ស-លេនីនពីរ ដែលមានប្រទេសនៅជិតខាងគ្នា គេត្រូវពុះពារដោះស្រាយជាសម្ងាត់ ។ ដូច្នេះ ការប៉ះទង្គិចគ្នា ខ្ញុំប្រើពាក្យប៉ះទង្គិចគ្នាវាចំជាង ។ ការប៉ះទង្គិចគ្នាខាងនយោបាយក៏ដោយ ខាងអាវុធក៏ដោយ ជាពិសេសខាងនយោបាយគេទុកជាសម្ងាត់ៗ ។ ដល់ក្រោយពីផ្ទុះសង្គ្រាមហើយ បានចេញសេចក្ដីថ្លែងការណ៍ ដែលលោកមានប្រសាសន៍លើកឡើងអំមិញអ៊ីចឹង ។ ដូច្នេះ គេទុកជាសម្ងាត់ នេះខ្ញុំជឿថា វាជាទម្លាប់របស់បក្សម៉ាក្ស-លេនីនពីរដែលមានប្រទេសជិតខាងគ្នា។ នេះគឺអ៊ីចឹង ។

**ស៖** មុននេះបន្តិចលោកបាននិយាយថា សុន សេន បានទៅនៅអ្នកលឿង តើពេលនោះលោកដឹងទេថា សុន សេន ទៅនៅអ្នកលឿងដើម្បីធ្វើអ្វីនៅពេលនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ ។ ខ្ញុំមិនដឹងច្បាស់ទេ ក៏ប៉ុន្តែ រឿងកិច្ចការយោធាហ្នឹង ។ ហើយខ្ញុំសូមបញ្ជាក់បន្តិចទៅទៀត មេខ្ញុំគាត់ចេញពីភ្នំពេញទៅៗនៅខាងក្រៅ ។ ខ្ញុំភាគច្រើនយ៉ាងយូរនៅអ្នកលឿង ក៏ប៉ុន្តែឯកសារស-២១ ជាសេចក្ដីសារភាពជូនទៅ ពួន្ធន ក៏ដោយ ក៏ខ្ញុំឃើញចំណាររបស់លោកគ្រូ សុន សេន រហូតដល់ថ្ងៃ១១ ខែ១១ ១៩៧៧ ។ ដូច្នេះ ការងារនៅស-២១ គាត់ដឹកនាំនៅតែដឹកនាំគិតគូរដដែល ។ នេះគឺខ្ញុំសូមជម្រាបអ៊ីចឹង ។ នេះឯកសារដែលនៅសល់ៗស-២១ នៅឡើយទេ ហើយជាក់ស្ដែងមិនដឹងជាគាត់គិតគូរបញ្ហាហ្នឹង យ៉ាងម៉េចតទៅទៀតទេ ។

[១១:៤១:៣០]

**ស៖** ម្សិលមិញលោកបានលើកឡើងថា យូរៗម្ដង សុន សេន តែអូមករកម្ដងមែនទេ? ហើយក្នុងអំឡុងពេលនោះ គាត់តែអូទំនាក់ទំនងដើម្បីអ្វីដែរ? ហើយតើគាត់បានប្រាប់ពីបញ្ហាជម្លោះអ្វីជាមួយវៀតណាមដែរទេនៅក្នុងអំឡុងពេលតែអូនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មេតែអូមកសួរខ្ញុំ សំខាន់ គឺតាមដានការងារនៅស-២១ នេះ ឲ្យតែមេជួបខ្ញុំ គឺតាមដានការងារ តម្រង់ទិសការងារ កែលម្អការងារ ។ ឯចំណែក បញ្ហាសមរភូមិ ទំនាស់នយោបាយយ៉ាងម៉េច ជាពិសេសទំនាស់នយោបាយយ៉ាងម៉េច? ទុកសម្រាប់វគ្គប្រចាំឆ្នាំបានគេនិយាយ ។ ដូច្នេះ ការជួបគ្នារបៀបនេះ គឺមេតាមដានការងារ តម្រែតម្រង់ការងារ ឯចំណែកទំនាស់រវាងខ្មែរ វៀតណាម ទំនាស់រវាងខ្មែរជាមួយនឹងប្រទេសណាផ្សេងទៀត ។ ឧទាហរណ៍ ឡាវ

អីៗហ្នឹង គេទុកនិយាយនៅវគ្គសិក្សាប្រចាំឆ្នាំ ។

**ស៖** តើលោកដឹងទេថា ទាហានវៀតណាមដែលចាប់បាននៅសមរភូមិបញ្ជូនទៅណាខ្លះ លោកមានដឹងទេ?

**ឆ៖** ខ្ញុំមិនដឹងទេ ជម្រាបដោយត្រង់មិនដឹងទេ ។ មិនដឹងជាប៉ុន្មាននាក់ គេកម្ទេចនៅសមរភូមិនុ៎ង មិនដឹងជាប៉ុន្មាននាក់ គេបញ្ជូនមកខ្ញុំ ហើយអាចមានខ្លះទៀតទៅកន្លែងផ្សេង ឬយ៉ាងម៉េច ខ្ញុំមិនច្បាស់ ។

**ស៖** លោកដឹងទេថា ទាហានវៀតណាម ដែលបញ្ជូនមកដល់ស-២១ ហ្នឹង មានសភាពយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំអត់បានទៅមើលផ្ទាល់ទេ ។

**ស៖** ម្សិលមិញលោកបានជម្រាបលោកស្រីចៅក្រមថា បុគ្គលិករបស់លោកធ្លាប់ចេញទៅដឹកជញ្ជូនអ្នកទោសវៀតណាមចំនួនពីរដង នៅខាងខេត្តស្វាយរៀងហើយនិងកំពង់ចាម ។ អ្នកដែលចេញទៅចាំបាច់ត្រូវតែមានបញ្ជាពីលោក ហើយត្រូវលិខិតដើរផ្លូវពិសេសទៀត ។ តើនៅពេលនោះលោកបានបញ្ជាអ្នកណាខ្លះទៅដឹកជញ្ជូនទាហានវៀតណាមដែលចាប់បាននោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា រឿងនេះខ្ញុំបានរាយការណ៍ជម្រាបជូនលោកជំទាវខាតរ៉ាយច៍ ចៅក្រមជំនុំជម្រះរួចហើយ ។ ខ្ញុំសូមបញ្ជាក់បន្ថែមឲ្យច្បាស់ ហើយពាក្យតែដដែលទេ ។ សំបុត្រពិសេសពីរដង ប្រើប្រាស់សម្រាប់ចេញក្រៅ ហើយមានតែពីរដងហ្នឹងគត់ ឈប់ប្រើសំបុត្រដើរផ្លូវពិសេស ។ ឯចំណែកទិសដែលទៅយកទាហានវៀតណាមនេះ មិនមែនជាទិសតាមផ្លូវលេខ៧ ឬក៏មិនដឹងជាទិសតាមផ្លូវលេខ១ ខ្ញុំមិនចាំច្បាស់ ។ ខ្ញុំចាំមិនច្បាស់ ក៏ប៉ុន្តែទៅ ចេញទៅដែលប្រើសំបុត្រដើរផ្លូវពិសេសហ្នឹង តែពីរដងទេ ។ ឯចំណែកក្រៅពីនោះ ខ្ញុំរង់ចាំទទួលពីខាងក្រៅគេបញ្ជូនមក គឺមិត្តលីនគាត់បញ្ជូនមកហើយយើងខ្ញុំនៅរង់ចាំទទួល ។

**ស៖** សំណួររបស់ខ្ញុំ គឺថា តើលោកបញ្ជាឲ្យនរណាខ្លះទៅនុ៎ង? នេះជាសំណួរ ។

**ឆ៖** តែកាលបានបញ្ជាមកអ៊ីចឹង ខ្ញុំបញ្ជាឲ្យ មិត្តហ៊ុយ គេអនុវត្ត គេបែងចែកឲ្យអ្នកណាទៅ (សុំទោស) តែកាលណាបានបញ្ជាមកអ៊ីចឹង ខ្ញុំមិនដែលទៅបញ្ជាផ្ទាល់ទេ ខ្ញុំបញ្ជាប្រយោល ឲ្យមិត្តហ៊ុយគេអនុវត្ត ។ ខ្ញុំបញ្ជាប្រយោលទេ ។

**ស៖** អ៊ីចឹងបានន័យថា លោកអត់បានដឹងថាអ្នកខ្លះដែលបានចូលរួមទៅជាមួយ ហ៊ា ទេ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ហ៊ា ក៏មិនទៅទៀតៗ ។ បញ្ហាហ្នឹង ខ្ញុំបញ្ហាជាប្រយោល ដូច្នេះ ហ៊ា អាចចាត់តាំង ហ៊ុយ ឬអ្នកណាផ្សេងទៀត ។ ហ៊ា មិនដែលប៉ានដើរចោលកន្លែងទេ ។

**ស៖** ហើយលិខិតដើរផ្លូវពិសេសនេះ តើអ្នកណាជាអ្នកសម្រេចចេញ?

**ឆ៖** ដើរផ្លូវពិសេសនេះ ខ្ញុំសុំមិននិយាយអំពីកំណើតអី ដែលបានប្រើលិខិតដើរផ្លូវពិសេសទេ ។ លិខិតដើរផ្លូវពិសេសនេះ ដំបូងប្រគល់មកឲ្យខ្ញុំ ហើយដល់ប្រតិបត្តិការហ្នឹងចប់ ខ្ញុំប្រគល់ជូនលោកគ្រូ សុន សេន វិញ ពីដៃខ្ញុំទៅគាត់ ។ ដោយឡែកលើកពីរ ខ្ញុំឃើញតឹង គ្នារៀបចំដល់ម៉ោងចេញហើយបាន គេឲ្យខ្ញុំទៅទទួលលិខិតដើរផ្លូវពិសេសនេះ នៅផ្លូវព្រះមុនីវង្ស នៅនឹងមុខរោងចក្រសេវេនអាប់ ។ ដល់ខ្ញុំមកដល់វិញភ្លាម ឲ្យទូរស័ព្ទឲ្យ មិត្តផន នីរសារលោកគ្រូ សុន សេន មកទទួលយកលិខិតដើរផ្លូវនេះទៅវិញភ្លាម ។ ដូច្នេះ លិខិតដើរផ្លូវអត់ប៉ានទុកនៅស-២១ យូរទេ ។ ព្រោះអី? ព្រោះលិខិតដើរផ្លូវពិសេសហ្នឹង មានបំរាមមមួយហាមមិនឲ្យឆែក មិនឲ្យឆែកឡានៗ ដូច្នេះ លិខិតដើរផ្លូវពិសេសនេះ គេយើងខ្ញុំប្រើតែពីរដងទេ ។ ចប់ ។

**ស៖** តើលោកចាំបានទេថា កាលដែលទៅចំនួនពីរលើកហ្នឹង ចាប់បានទាហានវៀតណាមហ្នឹងប៉ុន្មាននាក់ លោកចាំបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! យើងខ្ញុំអត់ទៅចាប់ទេ បើសិនជាទៅណ៎ា ។ ទៅយកវៀតណាម ទៅអីក៏ដោយ អត់ទៅចាប់ទេ ទៅយករបស់ដែលគេចាប់ស្រាប់យកមក ។ ដូចខ្ញុំបានជម្រាបលោកជំទាវ ខាតវ៉ាយថ៍ ម្សិលមិញថា មិនដឹងជាទៅទិសណា? ឬបាត់ដំបង ឬក៏ខាងព្រំដែន ។ ដូច្នេះ អាលិខិតដើរផ្លូវពីរហ្នឹង មិនដឹងយ៉ាងម៉េចទេ សូមរក្សាថា មានប្រើពីរ ទៅទីណាខ្លះ មិនច្បាស់ចាំបញ្ជាក់ទាំងអស់គ្នាទៅ ពេលដែល មិត្តហ៊ុយ គាត់មក ។

**ស៖** អ៊ីចឹង បានន័យថាលោកមិនចាំចំនួនមនុស្សដែលទទួលបានទេ អ៊ីចឹងមែនទេ?

[១១:៤៨:៣០]

**ឆ៖** រឿងល្អិតជាក់ស្តែងអ៊ីចឹង ខ្ញុំអត់ចាំទេ ។

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាលិខិតដើរផ្លូវពិសេសនេះត្រូវបានបញ្ឈប់ដោយមូលហេតុអ្វី?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ គ្រាន់តែសូមសន្និដ្ឋាន ។ លិខិតដើរផ្លូវនេះ ពិសេសនឹងអំណាចណាស់ ព្រោះហាមមិនឲ្យឆែក ដូច្នេះ គេមិនប៊ានទុកចិត្តប្រើស-២១ ឲ្យកាន់អាលិខិតហ្នឹងទេ យូរច្រើនដងពេក ទេ ហើយមិនប៊ានឲ្យទុកយូរទៅទៀត ។

**ស៖** តើលោកមានបាន ពេលនោះតើលោកបានស្នើទៅថ្នាក់លើរបស់លោក ដើម្បីចេញលិខិត ដើរផ្លូវអ្វីផ្សេងទៀតទេ?

**ឆ៖** រឿងនេះ ខ្ញុំភ្លេចអស់ទៅហើយ ។

**ស៖** លោកចាំបានទេថា តើអង្គភាពណាខ្លះដែលបញ្ជូនអ្នកទោសវៀតណាមហ្នឹង ទាហានហ្នឹង មកមន្ទីរស-២១?

**ឆ៖** អ្នកដែលមកហ្នឹង គឺពួកមិត្ត លីន គឺអង្គភាពរបស់៨៧០ ហ្នឹងតែម្តង ។

**ស៖** តើលោកដឹងថា ជាទូទៅប៉ុន្មានថ្ងៃ ទើបគេបញ្ជូនទាហានវៀតណាម មកស-២១ ម្តង បន្ទាប់ពីថ្ងៃ៦ មករា ១៩៧៨ មក?

**ឆ៖** បញ្ហាអស់នេះអត់ទៀតទាត់ទេ វាអាស្រ័យសមរភូមិ ។

**ស៖** ញឹកញាប់ដែរទេ?

**ឆ៖** បើសិនជាយើងនិយាយថា ហ៊ឺ!មិនចាំទេ មួយអាទិត្យដឹង ពីរអាទិត្យដឹង ឬក៏ឆាប់រហូត ត្រឹមប្រាំថ្ងៃអីក៏មិនដឹង មិនចាំទេ ។

**ស៖** អ៊ីចឹងតើលោកចាំទេ នៅពេលណាដែលមានការបញ្ជូនអ្នកទោស ទាហានវៀតណាមហ្នឹង មក ស-២១ ច្រើនជាងគេបំផុត?

**ឆ៖** អត់ចាំទេ បញ្ជីយើងអំមិញហ្នឹង ជាភស្តុតាងហើយប្រសិនជាលោកព្រះរាជអាជ្ញាចង់ឲ្យខ្ញុំ ឆ្លើយឲ្យបញ្ជីហ្នឹងមក ខ្ញុំយកទៅសរុបខែណាមកប៉ុន្មានៗ ។

**ស៖** លោកបានលើកឡើងថា លោកបានបង្រៀនអំពីរបៀបសួរចម្លើយទៅអ្នកទោស ទៅអ្នក សួរចម្លើយអ្នកទោសវៀតណាម តើលោកចេះវិធីនេះមកពីណា?

**ឆ៖** ខ្ញុំមនុស្សដែលខ្ញុំប្រគល់ឲ្យសួរចម្លើយវៀតណាមនេះ ជាមនុស្សដែលខ្ញុំឲ្យសួរចម្លើយចាប់ តាំងពីកកើតមន្ទីរស-២១ មក បង ម៉ម ណៃ ។ ដូច្នេះ អត់មានបង្រៀនអីជាពិសេសទេ រុញមនុស្សទៅ ឲ្យគេសួរទៅអត់មានបង្រៀនអីថែមទៀតទេ គ្រាន់តែឲ្យគេរៀនអក្សរយួន អក្សរវៀតណាម ភាសាវៀត ណាម ជាមួយ វិផា ថាចាន់ ។

**ស៖** តើលោកបានណែនាំដល់អ្នកសួរចម្លើយរបស់លោកហ្នឹង ឲ្យសរសេរ ឬក៏និងថតសំឡេងនូវចម្លើយសារភាពរបស់អ្នកទោសវៀតណាម ដើម្បីផ្សព្វផ្សាយតាមវិទ្យុ ឬក៏យកទៅប្រើក្នុងកិច្ចប្រជុំអ្វីផ្សេងៗដែរទេ?

**ឆ៖** ខ្ញុំពិតជាបានណែនាំ តាមគោលការណ៍កែតម្រូវពីខាងលើ ។

**ស៖** លោកបានលើកឡើងថា លោកជ្រើសរើស ម៉ម ណៃ ឲ្យសួរចម្លើយអ្នកទោសវៀតណាម តើមានមូលហេតុអ្វីខ្លះដែលអាច ដែលលោកជ្រើសរើសគាត់ហ្នឹង?

**ឆ៖** ទីមួយការយល់ដឹងគេខ្ពស់ដែរ ខាងកម្រិតវប្បធម៌គាត់ លីស្សង់ បានបរិញ្ញាខាងខ្មែរ ដូច្នេះយើងប្រើគាត់ទៅទិសហ្នឹង វាល្អជាងប្រើអ្នកផ្សេងទៀត ។

[១១:៥៣:០៣]

**ស៖** លោកម្សិលមិញក៏បានជម្រាបលោកស្រីចៅក្រមដែរថា នៅមន្ទីរស-២១ ហ្នឹងក៏មានការថតភាពយន្ត ។ តើការថតភាពយន្តនោះជារបៀបបន្ទោសបង្អាប់ ឬក៏ជារបៀបតម្កើងទៅលើអ្នកទោសវៀតណាមនុ៎ង? ហើយនរណាជាអ្នកបញ្ជាឲ្យថតភាពយន្តបែបនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បន្ទោសបង្អាប់ ឬតម្កើង ខ្ញុំមិនប៉ានិយាយទេ ប៉ុន្តែខ្ញុំសូមរាប់រៀបអំពីរបៀបដែលថត ។ ទាហានវៀតណាមមកជាឯកសណ្ឋាន ចូលមកដល់មាត់ទ្វារដោះមួក ហើយលើកដៃគោរព ដល់ទៅខ្ញុំសូមគោរពបក្សកុម្មុយនីស្តកម្ពុជា គាត់និយាយជាវៀតណាមសូមគោរពបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំឈ្មោះនេះ អីៗទៅ ពាក់ស័ក្តិប៉ុណ្ណោះ ហើយចូលមកឈ្លានពានទឹកដីកម្ពុជា ។ នេះរបៀបថតនៅនឹងកន្លែងផ្ទះខ្ញុំត្រង់ផ្លូវលេខ៩៥ នេះថតអ៊ីចឹង ។ អ្នកដែលថតឈ្មោះមិត្តថេង ហៅ ពូល ក្មួយបង្កើតរបស់ ប៉ុល ពត ដែលទៅរៀនថតកុននៅឯចិន ។ អ្នកដែលនាំមិត្ត ថេង ហៅ ពូល នេះមក គឺមិត្ត ប៉ង់ ទាល់តែមិត្តប៉ង់ នាំមកបាន ស-២១ ទទួល ។ បើមិត្ត ប៉ង់ មិននាំមកទេ គឺ ស-២១ អត់ទទួលទេ ។ ខុសចាត់តាំង អ្នកឯង ថេង ក៏ដោយតែបើ ប៉ង់ មិននាំមក ខុសចាត់តាំងអត់ទទួលទេ ។ ដូច្នេះ មិត្តប៉ង់ នាំមិត្តថេង មកថត ។ ថតឆាកនៅផ្ទះខ្ញុំផ្លូវលេខ ឯផ្លូវ៩៥ ទៅថតនៅក្បែរនេះទៅទៀត អាព្រៃល្បះៗ ចង់ក្បែរផ្លូវម៉ៅសេទុងនោះ ហើយនិងផ្លូវវត្តមហាមន្ត្រីនោះ ។ ថតធ្វើជារបៀបទ័ពវៀតណាមលើកដៃចុះចូលអីៗហ្នឹង ថតឯណោះទៀត។ មិត្តហ៊ី នាំទៅឯណោះ ។

**ស៖** តើអ្នកណាជាអ្នកបញ្ជាឲ្យថតនោះ តើលោកអាចជម្រាបបានទេ?

**ឆ៖** ពូទួន ប៉ុន្តែ មិនមែនជាយោបល់ផ្ទាល់របស់ពូទួន ទេ គឺបញ្ជាពីលើមកទៀតហើយ ពីពួកបងប៉ុល ។

**ស៖** នៅក្នុងឯកសារD65 លោកបានទទួលស្គាល់ថា មានចម្លើយសារភាពរបស់ស្ត្រីវៀតណាមដែលបានផ្សាយតាមវិទ្យុ តើស្ត្រីនោះមានតួនាទីជាអ្វី ហើយចម្លើយរបស់ស្ត្រីនោះ និយាយពីអ្វីខ្លះលោកចាំបានទេ?

**ឆ៖** ស្ត្រីនោះជាស្ត្រីខ្មែររត់ទៅនៅវៀតណាម ដោយគាត់ចេះវៀតណាម ហើយដោយសំឡេងគាត់ពីរោះ ហើយគាត់ហ្នឹង ក៏មានការចំពាក់ចំពិននឹងរឿងយកការណ៍សម្ងាត់អីហ្នឹង ។ ដូច្នេះការថតនេះទីមួយ ដើម្បីបញ្ជាក់ថា នៅស្រុកវៀតណាមវាអត់បាយស៊ី ។ ហើយនិយាយពីប្រជាជននៅស្រុកនោះ គេច្រៀងពីរឿងឃ្លានពេកអីៗហ្នឹង វាអត់បាយស៊ី ។ ហ្នឹងរឿងដែលខ្ញុំនៅចាំ ព្រោះវាចម្លែកដែរ ។ ចម្លើយសារភាពមួយដែលមានចម្រៀង ។ ហ្នឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង ខ្ញុំនៅចាំ ។

[១១:៥៦:៤៥]

**ស៖** តើលោកដឹងទេជាទូទៅចម្លើយសារភាព ដែលទទួលបានពីអ្នកទោសវៀតណាមហ្នឹងវាជាការពិតទាំងអស់ដែរឬទេ?

**ឆ៖** ចម្លើយផ្សាយវិទ្យុជាចម្លើយដែលយើងតម្រង់ទិសៗ។ ចម្លើយដែលយើងតម្រង់ទិស យើងចង់ឲ្យគេនិយាយ ។

**ស៖** តើជាការពិតដែរឬទេ?

**ឆ៖** តែយើងតម្រង់ទិស តាមចិត្តយើងចង់ហើយ ។

**ស៖** មានន័យថា បង្ខំឲ្យគេឆ្លើយតាមអ្វីដែលយើងចង់បាន?

**ឆ៖** តម្រង់ទិសឲ្យគេឆ្លើយតាមដែលយើងចង់បានៗ ។ យើងចង់បានឲ្យគេនិយាយថា កងទ័ពវៀតណាមអត់បាយស៊ី ស៊ីតែកន្ទក់ គេនិយាយតាមហ្នឹង ។

**ស៖** នៅក្នុងសៀវភៅរបស់លោក ណាយ៉ាន់ ចាន់ដា ត្រង់ទំព័រ២៨៧ ជាភាសាខ្មែរបានសរសេរថា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ វិទ្យុក្រុងភ្នំពេញបានផ្សព្វផ្សាយសារដោយចម្លែកមួយ ដោយអំពាវនាវឲ្យធ្វើការកាប់សម្លាប់ពូជសាសន៍វៀតណាម និងការបោសសម្អាតក្នុងជួរកងទ័ពរបស់កម្ពុជាខ្លួនឯងផ្ទាល់ ។ អ្វីៗទាំងអស់គ្រាន់តែជាតួលេខប៉ុណ្ណោះ ។ យុទ្ធជនម្នាក់ៗក្នុងជួររបស់យើងត្រូវតែសម្លាប់វៀតណាមឲ្យបាន៣០នាក់ តើលោកបានដឹងបញ្ហានេះទេ?

**ឆ៖** យុទ្ធជនសម្លាប់ យុទ្ធជនវៀតណាមឲ្យបានសាមសិបនាក់?

**ស៖** យុទ្ធជនម្នាក់សម្លាប់វៀតណាមឲ្យបានសាមសិបនាក់ នេះជាសម្ដីនៅក្នុងសៀវភៅរបស់លោកណា យ៉ាន់ ចាន់ដា ដែលបានថា ជាការផ្សព្វផ្សាយរបស់វិទ្យុក្រុងភ្នំពេញនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ តើលោកបានស្ដាប់វិទ្យុប្រទះនឹងព័ត៌មាននេះទេ?

**ឆ៖** ខ្ញុំសូមជម្រាបដោយត្រង់ថា វិទ្យុខ្ញុំមិនងាយដែលបានស្ដាប់ទេ ។ ក៏ប៉ុន្តែ បើតាមខ្ញុំចាំ មិនដឹងជាប្រភពហ្នឹងពីរៀនសូត្រ ឬក៏ពីមើលស្អីទេ ។ យុទ្ធជនយើងម្នាក់បើសម្លាប់បានយុទ្ធជនវៀតណាមសាមសិបនាក់ នេះជាជោគជ័យមួយ ។

[១១:៥៩:៣០]

**លោក សេង ប៊ុនឃាង៖**

លោកប្រធានបើពិនិត្យទៅលើពេលវេលា ឃើញថាដល់ហើយ ប៉ុន្តែ ខ្ញុំនៅមានសំណួរបន្តិចបន្តួចទៀត ប្រហែលជាដប់នាទីទៀត តើអនុញ្ញាតបន្ត ឬក៏ឈប់សម្រាកសិន ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំចង់ធ្វើការបញ្ជាក់ថា អ្វីដែលលោកប្រធានបាននិយាយកាលពីមុននោះទាក់ទងទៅនឹងតម្រូវការក្នុងការធ្វើសំណួរហ្នឹងឲ្យបានពិតប្រាកដជាក់ស្ដែង ហើយពាក់ព័ន្ធតែទៅនឹងអង្គហេតុនៅចំពោះមុខអង្គសវនាការនេះ ហើយខ្ញុំចង់និយាយថា សំណួរជាច្រើនដែលត្រូវបានសួរអម្បាញ់មិញនេះ គឺបានសួររួចហើយ ហើយជនជាប់ចោទក៏បានឆ្លើយនឹងសំណួរអស់ទាំងហ្នឹងរួចហើយ តើខ្ញុំអាចនិយាយបន្ថែមទៅលើអ្វីដែលលោកប្រធានបាននិយាយរួចហើយនោះថា យើងគួរតែកំណត់សំណួររបស់យើងហ្នឹងឲ្យបានច្បាស់លាស់ ។ ដូច្នេះ គឺមិនមែនសំណួរច្រំដែល ឬក៏សំណួរដែលមិនពាក់ព័ន្ធ ។ ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវ ដល់ម៉ោងត្រូវពិសារអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ ហើយរហូតដល់ម៉ោងមួយកន្លះនៅរសៀលនេះ សូមបន្តនូវដំណើរការនីតិវិធីសវនាការយើងទៅទៀត ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយនិងឲ្យនាំគាត់ត្រឡប់មកសាលសវនាការវិញឲ្យបានមុនម៉ោង មួយកន្លះរសៀលនេះ ។ ហើយភាគីក៏ដូច្នោះដែរ សូមអញ្ជើញឲ្យបានតាមម៉ោងកំណត់ ។

*[សវនាការសម្រាកពីម៉ោង ១២:០២ នាទីដល់ម៉ោង ១៣:៤២ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាស បន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

សូមអញ្ជើញលោក អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមស្នើទៅលោកប្រធានថា ថ្ងៃស្អែកហ្នឹងនឹងមានសវនាការស្តីពីការគ្រប់គ្រងតុលាការ ។ អ៊ីចឹងតើមានគម្រោង ឬក៏ការរៀបចំរបៀបវារៈសម្រាប់ថ្ងៃស្អែកទេ? ព្រោះព័ត៌មាននេះ ត្រូវបានផ្សព្វផ្សាយដោយលោកប្រធានរួចរាល់ហើយ ។ អ៊ីចឹងបើមាននោះ ខ្ញុំពេញចិត្តនឹងទទួលនូវរបៀបវារៈសម្រាប់កិច្ចប្រជុំនៅថ្ងៃស្អែក ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានមានចំណាប់អារម្មណ៍បញ្ហានេះ ហើយជាសម្តីរបស់ខ្ញុំ ដែលខ្ញុំបានជម្រាបជូនដំណឹងនោះ ក៏បានលើកឡើងអំពីថា នឹងជូនអំពីរបៀបវារៈដែលត្រូវប្រជុំសម្រាប់ថ្ងៃប្រជុំនៅថ្ងៃស្អែកនោះដែរ ក៏ប៉ុន្តែដូចជាលោកមេធាវី អស់លោក លោកស្រីបានជ្រាបហើយ យើងទាំងអស់គ្នាសុទ្ធតែមមារញឹកដូចគ្នានៅក្នុងដំណើរការសវនាការនេះ ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ គឺអង្គជំនុំជម្រះបានពិភាក្សាគ្នា ហើយនិងបានរៀបចំនៅរបៀបវារៈនោះហើយ ។ ហើយយើងបានរៀបចំជាមូលដ្ឋាននោះរួចហើយ នៅតែពិភាក្សាលម្អិតនៅពេលដែលសម្រាកនារសៀលនេះ យើងនឹងពិភាក្សាគ្នាបញ្ហានេះដើម្បីឲ្យជាការបញ្ចប់នូវរបៀបវារៈ ហើយនិងជម្រាបជូនដល់ភាគីទាំងអស់ ដែលបានដឹងនៅក្នុងអំឡុងពេលប្រហែលជាចុងក្រោយនៃដំណើរការដេញដោលនៅរសៀលនេះ ។ បានន័យថា យើងនឹងប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការផ្តល់ព័ត៌មាននេះ ជូនដល់ភាគីជាមុន ដើម្បីបានជ្រាបនិងបានចូលរួមមតិយោបល់នៅក្នុងដំណើរជជែកពិភាក្សានៅថ្ងៃស្អែក ដើម្បីទីមួយ គឺថាឲ្យចំបញ្ហា ទីពីរ គឺឲ្យបានលឿននៅក្នុងការជជែកពិភាក្សានោះ ដើម្បីអង្គជំនុំជម្រះមានឱកាសនៅក្នុងបំពេញកិច្ចការមួយចំនួនទៀតដែលជាបន្ទាន់ ។ ចំពោះមុខនេះ ត្រូវតែពិនិត្យ ប្រជុំពិភាក្សាដើម្បីដោះស្រាយសម្រាប់សប្តាហ៍បន្តបន្ទាប់ ។

បាទ ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តធ្វើសំណួរសួរជនជាប់ចោទ ពាក់ព័ន្ធនឹងអង្គហេតុ ដែលកំពុងតែដាក់ពិភាក្សាដេញដោលនេះ គឺអង្គហេតុជម្លោះប្រដាប់អាវុធ ។ ប្រសិនបើមានសូមអញ្ជើញ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន ។ ជាដំបូងខ្ញុំសូមអនុញ្ញាតជម្រាបជនជាប់ចោទថា សូមឱ្យលោកឆ្លើយឱ្យចំនឹងសំណួរ ចៀសវាងឆ្លើយទៅនឹងបញ្ហាផ្សេង ដែលនាំឱ្យមានការខាតពេលវេលា និងអាចមានការភ័ន្តច្រឡំផងដែរ ដូចដែរកន្លងមក ។

**ស៖** សំណួរសួរថា នៅក្នុងអំឡុងពេលដែលលោកកាន់តំណែងស-២១ ហ្នឹង លោកបាននិយាយថា លោកមិនបានដឹងថា វាជាអំពើខុសច្បាប់ទៅនឹងច្បាប់អន្តរជាតិអីទេ គឺលោកគិតតែពីធ្វើតាមបញ្ជារបស់គេ ។ អ៊ីចឹងសួរថា តើនៅពេលណាដែលលោកបានដឹងអំពើទាំងអស់នេះ ជាអំពើខុសឆ្គងនោះ?

**ឆ៖** ខ្ញុំចាប់ផ្តើមដឹង នៅពេលដែលឃើញដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេត នេះច្បាប់ដឹងជាផ្លូវការច្បាស់លាស់ ។ ចាប់ផ្តើមដឹងមែនទែន ពីហ្នឹងមក ។

**លោក សេង ប៊ុនឃាង៖**

លោកប្រធានខ្ញុំអត់សំណួរហើយ សូមអនុញ្ញាតឱ្យខាងសហការីអន្តរជាតិបន្តសំណួរប្រសិនជាមាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោក លោកស្រីចៅក្រម សួស្តីជនជាប់ចោទ! ខ្ញុំមានសំណួរសម្រាប់ជនជាប់ចោទ ហើយខ្ញុំគិតថា ប្រហែលជាស៊ីពេលម្ភៃនាទី ដើម្បីធ្វើការបញ្ជាក់ពីចំណុចមួយចំនួន ដែលខ្ញុំនៅមិនទាន់បានច្បាស់នៅក្នុងអំឡុងពេលមួយថ្ងៃកន្លះមកនេះ ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំចង់សួរលោកនូវសំណួរមួយចំនួនអំពីភាពផ្សេងគ្នា រវាងការបែងចែកប្រភេទអ្នកទោសនៅស-២១ ថាជាជនស៊ីវិល ជាតិញ្ញ ឬក៏ជាទាហាននោះ ។ ដូចដែលលោកបានដឹងហើយ នៅក្នុងបញ្ជីអ្នកទោសដែលគ្រប់ៗគ្នាបានទទួលនេះ គឺអាស្រ័យទៅលើឯកសារដែលទទួលបាននៅស-២១ ។ ហើយដូចជាចៅក្រម ខាតរ៉ាយច៍ បានមានប្រសាសន៍នៅថ្ងៃនេះអ៊ីចឹង គឺមានការបែងប្រភេទអ្នកទោសហ្នឹង ជាបីប្រភេទ គឺមានជាតិញ្ញ ជាជនស៊ីវិល ហើយនិងជាទាហានដែរជាឈ្លើយសឹក ។ ដំបូងលោកចៅក្រម ខ្ញុំនឹងសូមឱ្យធ្វើការបង្ហាញឯកសារដែលមានលេខ នោះគឺជាចម្លើយរបស់ជនជាប់ចោទ នៅចំពោះមុខសហចៅក្រមស៊ើបសួរ ដែលមានលេខ 001527587 ខ្មែរ

មានលេខ 00177580 ហើយនិងភាសាបារាំង 00177595 ។ សូមឲ្យដាក់ឯកសារនេះបញ្ចាំងនៅលើអេក្រង់ ហើយដំបូងសូមឲ្យភ្ជាប់អេក្រង់ហ្នឹង មកអេក្រង់ខាងរបស់កំព្យូទ័រសហព្រះរាជអាជ្ញា ។

[១៣:៤៩:១០]

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសសោតទស្សន៍ សូមភ្ជាប់ប្រព័ន្ធរូបភាពមកប្រព័ន្ធកំព្យូទ័រ របស់សហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ ។ ខ្ញុំសូមរំឭកថា ឯកសារនេះ គឺលេខD65 ។ លោក លោកស្រីចៅក្រម ខ្ញុំសូមឲ្យលោកប្រធានឲ្យក្រឡាបញ្ជីធ្វើការអានកន្លែងដែលយើងគូសសញ្ញាពណ៌ក្រហម ដើម្បីអានជូនជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី អាននូវអក្សរដែលមាននូវគំនូសបន្ទាត់រង្វង់ពណ៌ក្រហមព័ទ្ធជុំវិញនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

និងចុងក្រោយៗថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាតិវៀតណាមភាគច្រើនដែលរស់នៅកម្ពុជាត្រូវបានកម្ទេច ។ ដូច្នេះ នៅមានជនជាតិវៀតណាមតិចតួចណាស់ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានឃើញនៅក្នុងបញ្ជីឈ្មោះចាស់នៅស-២១ មានជនជាតិវៀតណាម ដែលនៅរស់ នៅក្នុងប្រទេសកម្ពុជាដែរ ។ ជនស៊ីវិល និងទាហានវៀតណាម ត្រូវបានប្រព្រឹត្តកម្មដូចគ្នា ។ ពួកគេត្រូវបានសួរចម្លើយបន្ទាប់មកត្រូវបញ្ជូនទៅសម្លាប់ ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណ ។ លោក កាំង ហ្កេកអ៊ាវ តើលោកយល់ស្របដែរឬទេ? ប្រសិនបើខ្ញុំលើកឡើងថា វាមិនគិតថា ជនជាតិវៀតណាមណាទេ ដែលជាអ្នកទោសនៅស-២១ មិនថាគាត់ជាយុទ្ធជន ចារកម្ម ឬជនស៊ីវិល ។ អ្នកទាំងអស់នោះ នឹងត្រូវគេសម្លាប់ ដោយសារតែពួកគេជាជនជាតិវៀតណាមឬក៏គាត់មានសញ្ជាតិជាជនជាតិវៀតណាម ។

**ស៖** តើលោកយល់ស្របចំពោះការលើកឡើងរបស់លោកនៅចំពោះមុខចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** និយាយរួម ខ្ញុំបានជម្រាបជាហូរហែ អង្គសវនាការយើងតាំងពីដើមមកថា មនុស្សដែលគេបញ្ជូនចូល ស-២១ សុទ្ធតែជាខ្មាំងដែលត្រូវកម្ទេច ។ ដូច្នេះ ក្នុងរួមទាំងអស់នោះ វាពិតជាមានជនជាតិវៀតណាម ទាហាន ស៊ីវិល ចារបុរសដូចគ្នា គេបញ្ជូនចូលមកហើយ យើងខ្ញុំត្រូវតែកម្ទេចដោយខានមិនបាន ខានគឺខុស ។ បើនិយាយតទៅទៀត យើងខ្ញុំរាប់រៀបពីចំនួនអាណិកជនវៀតណាម ខ្ញុំសូមបញ្ជាក់ថាអាណិកជនវៀតណាម ។ អាណិកជនវៀតណាមនៅសល់ នៅកម្ពុជារហូតដល់១៧មេសា តិចណាស់ តិចមែនទែន សឹងតែអត់ ខ្ញុំបានរៀបពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រច្បាស់ហើយ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេ ។

**ស៖** សូមអរគុណ ។ លោកបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា “អ្នកទាំងអស់នោះ វាត្រឹមត្រូវដែរឬទេ វាជាបញ្ហាគោលនយោបាយ ដែលថា អ្នកទាំងអស់នុ៎ង ត្រូវតែគេសម្លាប់ដោយសារតែគាត់ជាជនជាតិវៀតណាម” ថាតើវាជាគោលនយោបាយទាក់ទងនឹងតួនាទីរបស់បុគ្គលទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា មិនមែនត្រឹមតែគេសម្លាប់ ដោយសារតែជាជនជាតិវៀតណាមទេ ។ អ្នកណាក៏ដោយ ខ្មែរក៏ដោយ ចិនក៏ដោយ អ្នកណាក៏ដោយ ឲ្យតែបញ្ជូនស-២១ គឺត្រូវតែកម្ទេច នេះគឺជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងនុ៎ង ក៏ពិតជាមានជនជាតិវៀតណាម នេះជាគោលនយោបាយរួម ។

**ស៖** សូមអរគុណ ។ ព័ត៌មានដែលលោកមានជាប្រធានស-២១ ថាតើវៀតណាម គឺជាចារកម្មឬក៏ត្រូវបានគេចោទថាជាចារកម្មក៏ដោយ គឺព័ត៌មានទាំងអស់នោះ គឺវាដកស្រង់ចេញពីចម្លើយសារភាពផ្សេងៗ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ខ្ញុំពិបាកឆ្លើយ គឺពីព្រោះសំណួររបស់លោក ខ្ញុំមិនទាន់យល់ច្បាស់ ប៉ុន្តែ ឥឡូវខ្ញុំសាកល្បងឆ្លើយឡើងវិញ ។ តាមកាលដែលខ្ញុំចេះដឹងចាំ ជនជាតិវៀតណាម ជាអាណិកជនវៀតណាម ដែលរស់នៅកម្ពុជា គេបញ្ជូនមក មិនមែនដោយហេតុតែគាត់ជាជនជាតិវៀតណាមទេ ដោយសារមានកំហុសជាមួយនឹងគេ គេបញ្ជូនមក ។ ហើយឯចំណែកជនជាតិវៀតណាមដែលចូលមកពីស្រុកវៀតណាម ទោះបីជាតាមរូបភាពណាក៏ដោយ គេចាប់បញ្ជូនមក ស-២១ តាមឈ្មោះជាគិញ ។ នេះគឺសូមបញ្ជាក់បន្ថែមប៉ុណ្ណោះ ។

**ស៖** នៅពេលដែលលោកនិយាយថាអ្នកទាំងអស់នោះជាចារបុរស ថាតើលោកដឹងថាពួកគេជាចារបុរសនេះយ៉ាងម៉េច? គឺដោយសារតែចម្លើយសារភាពរបស់ពួកគេ គឺចម្លើយសារភាពនោះ គឺជាបញ្ជាចម្បងដែលទទួលបានថា ពួកគេជាចារបុរស ឬក៏មានព័ត៌មានផ្សេងទៀត?

**ឆ៖** ចម្លើយសារភាពវាក្រោយទេ ។ ព័ត៌មានផ្សេងទៀតគ្មានទេ គឺធាតុពិតអ្នកណាដែលចូលពីទឹកដីវៀតណាម ចូលទឹកដីកម្ពុជាជាជនស៊ីវិលក៏ដោយ ទាហានក្លែងក្លាយហ្នឹងក៏ដោយ គេចាត់ទុកជាគិញៗ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់មួយទៀត ដើម្បីឲ្យច្បាស់ទាំងអស់គ្នា អាណិកជនវៀតណាមដែលនៅស្រុកខ្មែរតាំងពីជាតិណាជាតិណីមក តែកាលណាគេចាត់បញ្ជូនមកស-២១ ព្រោះវាប្រឆាំងនឹងរដ្ឋអំណាចគេ អាហ្នឹងគេទុកជាអ្នកប៉ះបោរជាអ្នកប្រឆាំង អ្នកមិនគោលរពរដ្ឋអំណាច ។ ឯចំណែកជនជាតិវៀត-ណាមទាំងឡាយណាដែលចូលមកទឹកដីកម្ពុជាក្រោយ ១៧ មេសា គេចាត់ទុកជាគិញៗ ។ ខុស ឬត្រូវ គេបញ្ជូនមកហើយ មកស-២១ គិញ ហើយតែគេបញ្ជូនមកហើយចាប់ដូចគ្នាទេ ។

**ស៖** ខ្ញុំសន្និដ្ឋានថា ថាតើលោកដែលផ្ទៀងផ្ទាត់ទៅលើព័ត៌មានដែលផ្តល់ឲ្យនោះ ថាតើវាត្រឹមត្រូវដែរឬទេ? លោកដែលមាន ដែលផ្ទៀងផ្ទាត់ដែរឬទេ?

**ឆ៖** រឿងនេះវាជា ខ្មែរយើងមិនដឹងជាគេហៅស្អីទេ បារាំងគេហៅ *រ៉ូទីន* វាស៊ាំណាស់ទៅហើយតាំងយើងខ្ញុំធ្វើប្រធានមន្ទីរ១៣ម្ល៉េះ ឲ្យតែគេចាប់បញ្ជូនមកគិញ ។ អ្នកចូលមកពីដី លន់ នល់ មកដីរំដោះ គិញ ខុស ឬត្រូវ ម-១៣ ត្រូវតែវ៉ៃសួរចម្លើយ ហើយកម្ទេច ។ ដូច្នេះ ជនជាតិវៀតណាមដែលចូលមកពីទឹកដីវៀតណាមមកទឹកដីកម្ពុជា គិញ ខុស ឬត្រូវអត់បាន អាហ្នឹងអត់គិតទេធ្វើម៉េចឲ្យតែបានឲ្យគេ ហើយកម្ទេចទៅ ។

**ស៖** សូមអរគុណ ។ ដូច្នេះប្រសិនបើលោកឆ្លើយថា តើមែន ឬមិនមែនលោកមិនបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃព័ត៌មានដែលលោកបានផ្តល់ឲ្យនេះទេ? តើលោកយល់ស្របដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ ប្តូរប្រព័ន្ធរូបភាពទៅជារូបភាពប្រក្រតីឡើងវិញ ។

**ឆ៖** ខ្ញុំសូមឆ្លើយថា មានត្រូវ និងមានមិនត្រូវ ។ អ្នកដែលឆ្លើយថា គិញ មានត្រូវ មានមិនត្រូវហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹងធម្មតា ។

**ស៖** សូមអរគុណ ។ ហើយព័ត៌មានដែលលោកយកពីអ្នកទោសវៀតណាម នៅក្នុងចម្លើយសារភាពរបស់ពួកគេទាំងអស់នោះ គឺលោកមិនបានជឿអំពីភាពពិតប្រាកដនូវអ្វីដែលបានឡើងនៅក្នុង

ចម្លើយសារភាពនោះទេ ។ តើលោកយល់ស្របដូច្នេះដែរឬទេ?

[១៣:៥៨:១១]

**ឆ៖** មិនជឿទាំងស្រុង ។

**ស៖** ដូច្នេះ ដោយផ្អែកទៅលើចំណុចនេះ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ ដែលថាអ្នកជនជាតិវៀតណាមទាំងអស់នោះដែលនៅស-២១ គឺអាចត្រូវបានគេចាត់ទុកថា ជាតិញវៀតណាម? គឺគាត់ទាំងអស់នោះក៏អាចជាជនស៊ីវិលផងដែរ តើលោកយល់ស្របទៅលើចំណុចនេះដែរឬទេ?

**ឆ៖** អ្នកដែលគេចោទថា ជាតិញវៀតណាម ទោះបីជាស៊ីវិល ឬជាយោធាក្លែងភេទក៏ដោយ ក៏មួយចំនួនតូចអាចជនស្លូតត្រង់វៀតណាម ដែលលួចចូលមករកស៊ីនៅស្រុកខ្មែរ ។ មួយចំនួនតូច ។

**ស៖** លោកចង់ដឹងដោយសារតែលោកអត់បានធ្វើការពិនិត្យទៅលើចម្លើយទាំងអស់នោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ធម្មតាទេ យើងខ្ញុំពិនិត្យមិនបានដិតដល់ទេរឿងចម្លើយវៀតណាម ព្រោះចម្លើយខ្មែរដែលសំខាន់ៗវាច្រើន ។

**ស៖** សូមអរគុណ ។ ខ្ញុំនឹងចូលទៅដល់អង្គហេតុមួយទៀត ហើយវាជាចំណុចការសួរមួយដោយសង្ខេប គឺវាទាក់ទងទៅនឹងថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ លោកបានលើកឡើងថា នួន ជា ប្រាប់លោកថា សុន សេន គឺនឹងទៅសមរភូមិមុខ ។

លោកចៅក្រម ខ្ញុំសូមឲ្យខាងសោតទស្សន៍ធ្វើការផ្លាស់ប្តូរចរន្តរូបភាពមកខាង អេក្រង់ របស់សហព្រះរាជអាជ្ញា ។ គឺឯកសារនេះ គឺD65 ERN00147522 ភាសាអង់គ្លេស ERN គឺ 00146492 ហើយភាសាបារាំងគឺ 00147896 គឺសូមឲ្យដាក់ឯកសារនេះនៅក្នុងអេក្រង់ ជាភាសាខ្មែរ លោកចៅក្រមគឺ ខ្ញុំសូមលើកឡើងចំណុចដកស្រង់ខ្លីមួយ ដែលជនជាប់ចោទបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេត គឺចំណុចនេះគឺមាននៅក្នុងតារាងពណ៌ក្រហមសូមឲ្យក្រឡាបញ្ជីអាន។ គឺខ្ញុំសូមកែតម្រូវឯកសារលេខ D11 មិនមែន D65 នោះទេ ។

[១៤:០១:២៣]

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធរូបភាព មកផ្នែកទូរទស្សន៍របស់សហព្រះរាជអាជ្ញា ។

ក្រឡាបញ្ជី សែ កុលវុឌ្ឍី អាននូវអក្សរផ្នែកដែលមានបន្ទាត់ក្រហមគូសរង្វង់ជុំវិញនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

"ឆ្លើយ សុន សេន ចាកចេញព្រោះសង្គ្រាមជាមួយវៀតណាមខ្លាំងណាស់ ហើយគាត់ត្រូវបញ្ជូនឱ្យទៅសមរភូមិ ។ សហព្រះរាជអាជ្ញានិយាយថា មានពីរ ឬបីសំណួរដែរ ទីមួយ នៅពេលដែល សុន សេន ត្រូវបញ្ជាទៅសមរភូមិនៅឆ្នាំណា? ជនត្រូវចោទឆ្លើយថា តាមចាំឆ្នាំ១៩៧៧ នួន ជា ហៅខ្ញុំពី ស-២១ ទៅជួបនៅថ្ងៃ១៥ សីហា ១៩៧៧ ដើម្បីទទួលការងារនៅពុទ្ធិកសុរាម្រិត មានវត្តមានតែខ្ញុំនិងគាត់ប៉ុណ្ណោះ វាជាការជួបលើកទីមួយ តាមចាំគាត់ថា មិត្តខៀវ ទៅសមរភូមិ ហើយខ្ញុំទទួលភារៈជំនួស និងបញ្ជូនក្មេងពីរនាក់ជួយធ្វើការ គឺមិត្តប៉ង់ និង លីន ដែលឯងស្គាល់ហើយ ។ ពេល សុន សេន នៅគ្រប់គ្រង ប៉ង់ និង លីន ក៏ទៅ ស-២១ រួចហើយដែរ ។"

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណលោកចៅក្រម ។ ហេតុផលដែលខ្ញុំលើកឡើងចំណុចនេះ នៅក្នុងឯកសារនេះ គឺដោយសារតែនៅក្នុងភាសាអង់គ្លេសគឺ បានលើកឡើងថា សុន សេន ចាកចេញព្រោះសង្គ្រាមជាមួយវៀតណាមកើតឡើងខ្លាំងណាស់ ។ ហើយខ្ញុំបានផ្តោតទៅលើចំណុចនេះ នឹងចាប់អារម្មណ៍ទៅលើចំណុចនេះ ។ ខ្ញុំសន្និដ្ឋានថា សង្គ្រាមជាមួយវៀតណាមខ្លាំងណាស់នោះ គឺអត់មាននិយាយនៅក្នុងភាសាខ្មែរទេ ឬក៏មិនបានលើកឡើងនៅក្នុងនេះ ។

ទោះបីជាយ៉ាងណាក៏ដោយលោក កាំង ហ្គេកអ៊ាវ លោកបានលើកឡើងនូវចំណុចនេះ នៅមុខចៅក្រមស៊ើបអង្កេតថា សុន សេន គឺត្រូវបានបញ្ជូនទៅសមរភូមិមុខ ដោយសារតែបញ្ហាសង្គ្រាម ។ នេះគឺជាការ អ្វីដែលលោកបានយល់នៅឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរឬទេ? គឺគាត់នោះនឹងទៅជួយនៅបញ្ហានៅក្នុងសង្គ្រាម?

[១៤:០៤:២២]

**ឆ៖** ពាក្យនេះជាការយល់ឃើញរបស់ខ្ញុំ នៅពេលនុំងៗ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង នៅក្នុងសក្ខីកម្មរបស់លោក គឺមានលក្ខណៈមិនច្បាស់លាស់អំពីគោលបំណងចម្បងនៃការចាកចេញរបស់ សុន សេន តើនេះជាអ្វីដែលលោកយល់នៅពេលនោះ ឬក៏យ៉ាងម៉េច?

ខ្ញុំនឹងសួរដោយខ្លីៗអំពីខ្សែភាពយន្តដែលបាន ថតនៅស-២១ នៅពេលដែលកងទ័ពវៀតណាមត្រូវបាននាំចូលមកទីនោះ ឬក៏ប្រមូលផ្តុំនៅទីនោះ ដើម្បីឱ្យផ្តល់ចម្លើយសារភាពនៅក្នុងឯកសារខ្សែ

ភាពយន្ត ។ ហើយសំណួរទីមួយរបស់ខ្ញុំនោះ គឺថាខ្សែភាពយន្តនោះគឺបានថតឡើងនៅពេលដែលលោកមានវត្តមាននៅទីនោះដែរឬទេ?

[១៤:០៥:៤១]

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកសោតទស្សន៍ គឺផ្តាច់ប្រព័ន្ធរូបភាពពីទូរទស្សន៍កុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ហើយបង្វែរទៅរូបភាពធម្មតាឡើងវិញ ។

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោក ស្ទឹត ខ្ញុំជឿថា លោកកំពុងតែនិយាយអំពីព្រឹត្តិការណ៍ផ្សេងៗនៅក្នុងខ្សែភាពយន្ត ដែលសហព្រះរាជអាជ្ញាចង់បញ្ចូលទៅក្នុងសំណុំរឿង នេះគឺជាគោលបំណងនៃការសំណើដូចដែលខាងមេធាវីការពារក្តី ។ ថាតើខ្សែភាពយន្តនេះ គឺត្រូវដែលត្រូវបានធ្វើការថតដោយអាជ្ញាធរវៀតណាមនៅពេលដែលមកភ្នំពេញ ឬក៏ខ្សែភាពយន្តដែលជាកម្មវត្ថុនៃសំណើរបស់មេធាវីការពារក្តី ដែលចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចនៅឡើយ តែខ្ញុំចង់យល់ច្បាស់អំពីខ្សែភាពយន្តនេះ ។ តើជាខ្សែភាពយន្តមួយណា?

**លោក វីលៀម ស្ទឹត៖**

គឺសូមអរគុណ ។ ដើម្បីកុំឲ្យយើងច្រឡំ គឺខ្ញុំនិយាយអំពីខ្សែភាពយន្តដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ លើកឡើងព្រឹកមិញដែលអ្នកទោសវៀតណាមក្នុងពេលដែលត្រូវបានជាប់ខ្លួន ជាប់ឃុំនៅទីនោះលើកទីមួយហើយគេប្រើប្រាស់ខ្សែភាពយន្តនេះ ដើម្បីជាគោលបំណងនៃការឃោសនា ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

[១៤:០៧:២៧]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមសួរបំភ្លឺ គឺខ្ញុំមិនមានគោលបំណងយោងទៅលើរូបភាពខ្សែភាពយន្តទេ ។ ខ្ញុំនិយាយអំពីការផ្សាយតាមវិទ្យុ ហើយយើងហាក់ដូចជាមិនយល់ច្បាស់ថាតើលោកចង់បង្ហាញខ្សែរូបភាពៗយន្តមួយណា?

**លោក វីលៀម ស្មីត៖**

ដើម្បីធ្វើការបំភ្លឺដល់លោក លោកស្រីចៅក្រម បើសិនជាយើងអាចលើកឡើង អាចស្នើសុំឲ្យមានការបង្ហាញចម្លើយរបស់ជនជាប់ចោទបង្ហាញនៅចំពោះមុខចៅក្រមស៊ើបអង្កេតគឺ ឯកសារលេខ D65 ដែលមានលេខ ERN ជាភាសាអង់គ្លេសគឺ 00177587 ភាសាបារាំងគឺ 00177595 ហើយនិង ERNជាភាសាខ្មែរគឺ 00177580 ។ លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតឲ្យសោតទស្សន៍ធ្វើការភ្ជាប់រូបភាពមកកាន់ខាងសហព្រះរាជអាជ្ញា ដើម្បីឲ្យខ្ញុំអាចបង្ហាញទៅលអត្ថបទនេះបាន ។ លោកចៅក្រម ឡាវែន៍ មានសំណួរចង់សួរ ឬយ៉ាងម៉េច?

[១៤:០៨:៤៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ប្រហែលយើងឲ្យរៀបចំបញ្ហានេះ ឲ្យមានភាពងាយស្រួល តើជនជាប់ចោទអាចយើងខ្ញុំដែរឬទេ ថារូបភាពនេះ គឺពាក់ព័ន្ធទៅនឹងអ្នកទោសវៀតណាម គឺត្រូវបានថតនៅស-២១ ដើម្បីជាគោលបំណងនៃការឃោសនា ។ តើមានដែរឬទេ? តើលោកយល់ដែរឬទេ? តើខ្សែភាពយន្តនេះត្រូវបានថតនៅស-២១ ហើយវាមានថតអ្នកទោសវៀតណាម ហើយខ្សែភាពយន្តនេះ គឺថតឡើងដើម្បីគោលបំណងនៃការផ្សាយ និងការឃោសនា ថាតើមានខ្សែភាពយន្តថតបែបនោះដែរឬទេ?

**ឆ៖** ហើយសូមទោស អំមិញខ្ញុំស្មានថា លោកចៅក្រមសួរព្រះរាជអាជ្ញា បានជាខ្ញុំនៅស្ងៀម សូមទោស ។ ឥឡូវ ខ្ញុំសូមបញ្ជាក់ជូនលោកចៅក្រមដោយស្មោះ ហើយនិងដោយគោរព ។ មានខ្សែភាពយន្តមួយដែលថតឡើងដោយ មិត្តថេង ក្នុយរបស់ ប៉ុល ពត ។

ហើយថតហ្នឹងមានពីរកន្លែង ថតនៅផ្ទះខ្ញុំ នៅការិយាល័យរបស់ខ្ញុំមួយកន្លែង ដូចខ្ញុំបានរាយ-ការណ៍ជូនព្រឹកមិញហើយ ។ នៅក្នុងផ្ទះខ្ញុំតែម្តង នៅក្នុងផ្ទះខ្ញុំ ហើយទីពីរ គឺទៅថតនៅត្រង់ចន្លោះផ្លូវព្រះមុនីវង្ស នៅក្បែរផ្លូវព្រះមុនីវង្ស អ៊ូ!សូមទោសនៅក្បែរផ្លូវម៉ៅសេទុង និងនិយាយអំពីកន្លែងនុ៎ងវាមានព្រៃរបោះអីតូចៗទៅ ហើយនិយាយអំពីកងទ័ពវៀតណាមលើកដៃសុំចុះចាញ់ ។

ដូច្នេះខ្សែភាពយន្តនោះមានមែន មានថតនៅស-២១ មែន ពីរឆាកហ្នឹង ហើយទាហានហ្នឹងគឺពិតជាទាហានវៀតណាមមែន ជ្រើសរើសចេញពីគុកស-២១ពិត ដើម្បីជាឧបករណ៍សម្រាប់ឃោសនា ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណ ។ នៅពេលដែលលោកនិយាយថា ថតនៅក្នុងផ្ទះរបស់លោកហ្នឹង មានន័យ

ថាផ្ទះរបស់លោកហ្នឹងក៏ជាការិយាល័យរបស់លោកដែរ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំសូមឆ្លើយសំណួររបស់លោកជាពីរកំណាត់ ។ កំណាត់ទីមួយអំពីរឿងដែលលោកគ្រូ សុន សេន ចេញពីខ្ញុំទៅដែលលោកអធិប្បាយសង្ខេបសរុបអំមិញហ្នឹង ខ្ញុំសូមបញ្ជាក់ថែមបន្តិច ហើយទីពីរនិយាយអំពីការថតកុននេះ ។ នៅពេលដែល ពូនួន គាត់ហៅខ្ញុំទៅ គាត់ប្រាប់ថា ការចាំបាច់របស់សមរភូមិ នេះនិយាយឲ្យតាមពិតពាក្យអង្កាល់នុ៎ង ។ ការចាំបាច់នៃសមរភូមិ មិត្តខៀវ គាត់ទៅសមរភូមិ ខ្ញុំចុះមកជំនួស ។ នេះនិយាយពិត ។ រួចខ្ញុំមិនដឹងថាវាយ៉ាងម៉េចទេ ក៏ប៉ុន្តែឯកសារនៅសល់នៅស-២១ ខ្ញុំឃើញស៊ីញ៉េរបស់មេខ្ញុំ ក្រោយ១៧មេសា អ៊ូ!សូមទោស១៥សីហា យូរណាស់ គឺរហូតដល់ថ្ងៃ១១ វិច្ឆិកា ១៩៧៧ នៅតែឃើញស៊ីញ៉េមេខ្ញុំនៅឡើយទេ ។ ហើយការទាក់ទងរវាងខ្ញុំ និងគាត់តាម តេអូ មាន១រហូតយូរដែរ នេះគឺបញ្ជាក់អ៊ីចឹង ។

[១៤:១៣:០០]

សរុបមកវិញ ខ្ញុំបញ្ជាក់ពាក្យ មួយម៉ាត់ហ្នឹងឡើងវិញ គឺថាពូនួន គាត់ប្រាប់ខ្ញុំថាមិត្ត ខៀវ ទៅសមរភូមិដោយសេចក្តីចាំបាច់ នេះនិយាយអ៊ីចឹងដោយសេចក្តីចាំបាច់ ។ ឯចំណែក ទីពីរ ខ្ញុំសូមឆ្លើយបញ្ជាក់បន្ថែមនូវការដែលខ្ញុំបានជម្រាប លោកចៅក្រមអំមិញហើយ កន្លែងហ្នឹងធ្វើនៅការិយាល័យរបស់ខ្ញុំ នៅផ្លូវលេខ៩៥ នៅការិយាល័យ ផ្ទះខ្ញុំនៅជាប់ផ្លូវព្រះមុនីវង្សឯណោះ ។ អរគុណ សូមចប់ ។

**ស៖** សូមអរគុណ។ ហើយនៅពេលដែលធ្វើការថតខ្សែភាពយន្តហ្នឹង តើពេលហ្នឹង គឺមុនពេល សុន សេន ទៅសមរភូមិ ឬក៏ក្រោយពេល សុន សេន បានទៅសមរភូមិមុខរួចហើយ?

[១៤:១៣:៤៥]

**ឆ៖** សូមគោរពលោកព្រះរាជអាជ្ញា ។ សូមលោកជួយខ្ញុំបន្តិចទៅ មានប្រជុំមួយនៅហ្សាកាតា១ ប្រជុំអន្តរជាតិបែបប្រមុខរដ្ឋមិនដឹង រដ្ឋមន្ត្រីការបរទេសមិនដឹង នៅហ្សាកាតា ។ ដូច្នេះ ប៉ុល ពត ឲ្យ ស-២១ ថតរូបថតវៀតណាម ទាហានវៀតណាមខ្នាត១៨x២៤ ជ្រើសរើសមុខឲ្យស្អាតជាវៀតណាមហ្នឹងមួយបែបទៅ ហើយមួយបែបទៀតថតកុន ។ ដូច្នេះមានប្រជុំមួយនៅហ្សាកាតា ការថតកុនដើម្បីសេចក្តីត្រូវការចាំបាច់នៃការប្រជុំនុ៎ង ដូច្នេះប្រជុំថ្ងៃណា លោកព្រះរាជអាជ្ញាអាចរកថ្ងៃខែឃើញ ហ្នឹង សូមអរគុណ ។

**ស៖** ដូច្នេះ លោកមិនអាចប្រាប់យើងបានទេថា តើការធ្វើ ការថតហ្នឹងនៅឆ្នាំ១៩៧៦, ១៩៧៧ ឬក៏១៩៧៨ នោះ?

**ឆ៖** អរគុណ បើប៉ុនន៉ុងខ្ញុំជម្រាបបានដោយស្មោះ (១៩)៧៨ ៗ ។

**ស៖** សូមអរគុណ ។ លោកប្រធាន ខ្ញុំសូមឲ្យខាងផ្នែកសោតទស្សន៍ហ្នឹងចាក់ខ្សែភាពយន្តដ៏ខ្លីមួយ គឺមានលេខD69 គឺមាន 00172621 គឺមានរយៈពេលដប់ពីរនាទីនិងម្ភៃមួយវិនាទី ។ ខ្សែភាពយន្តនេះមានរយៈពេលខ្លីទេ ហើយខ្ញុំសូមឲ្យចាក់ខ្សែភាពយន្តនេះចំនួនពីរដង ហើយខ្ញុំសូមឲ្យជនជាប់ចោទពិនិត្យមើលខ្សែភាពយន្តនេះឲ្យបានច្បាស់លាស់ ជាពិសេសអំពីស្ថានភាពជុំវិញ ដែលមានបញ្ចាំងបង្ហាញនៅក្នុងខ្សែភាពយន្តនោះ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ចាត់ចែងបញ្ចាំងខ្សែភាពយន្តតាមការស្នើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណ ហើយខ្ញុំសង្ឃឹមថាមានការបកប្រែជាបីភាសា ។

**ស៖** លោក កាំង ហ្កេកអ៊ាវ តើខ្សែភាពយន្តដែលលោកបានពិនិត្យមើល និងខ្សែភាពយន្តដែលលោកនិយាយថាបានថតនៅក្នុងកន្លែងធ្វើការ របស់លោកនោះ? បើសិនជាចង់ឲ្យចាក់ខ្សែភាពយន្តនោះឡើងវិញ គឺថាយើងអាចចាក់ឡើងវិញម្តងទៀតបាន ។

**ឆ៖** ខ្ញុំមិនទាមទារឲ្យបញ្ចាំងទៀតទេ ប៉ុន្តែមានច្បាប់បកប្រែជាភាសាខ្មែរទេៗ ។

[១៤:១៨:២០]

**ស៖** គឺខ្ញុំមានការបកប្រែភាសាខ្មែរតាមមីក្រូហ្វូន តាមការស្តាប់របស់ខ្ញុំហ្នឹង ប្រសិនបើជនជាប់ចោទ មិនបានស្តាប់ទេ ឬក៏អ្នកដែលស្តាប់ភាសាខ្មែរហ្នឹង គឺថាខ្ញុំសូមឲ្យអានឡើងវិញនូវការបកប្រែជាភាសាខ្មែរ ។

**ឆ៖** ខ្ញុំចង់បានជាភាសាខ្មែរ អរគុណ ។ អំមិញហ្នឹងខ្ញុំស្តាប់ឮតែភាសាវៀតណាម ហើយនិងអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

មានឯកសារជាភាសាខ្មែរទេ ខាងព្រះរាជអាជ្ញាជាតិ មានទេ? មានចាប់អារម្មណ៍បញ្ហានេះទេ? ខាងអង្គជំនុំជម្រះក៏ស្តាប់ឮដូចគ្នា គឺនេះអត់មានភាសាទេ គឺភាសាវៀតណាម ហើយបកប្រែជាភាសាអង់គ្លេសប៉ុណ្ណោះ ។

**លោក វីលៀម ស្មីត៖**

ការបកប្រែជាភាសាអង់គ្លេសនុ៎ង គឺបានផ្តល់ឲ្យដល់ខាងក្រុមអ្នកបកប្រែហើយ។ ដូច្នេះ សង្ឃឹមថា នឹងមានការបកប្រែជាភាសាខ្មែរ បើសិនជាយើងអាចឲ្យអ្នកបកប្រែអាចអាននូវសំណេរបក ប្រែជាភាសាខ្មែរបាននោះប្រហែលជាការល្អ ។

**ប្រធានអង្គជំនុំ៖**

លោកអាចឲ្យលេខដែលមានសំណេរជាភាសាខ្មែរបានទេ? លេខខ្សែភាពយន្តនេះ ។

**លោក វីលៀម ស្មីត៖**

គឺថាមិនមានលេខយោងសម្រាប់ការបកប្រែជាភាសាខ្មែរទេ ប៉ុន្តែ ខ្ញុំមានអត្ថបទជាភាសាអង់-គ្លេស ខ្ញុំប្រហែលជាអាចអាន ឬក៏ខ្ញុំអាចឲ្យក្រឡាបញ្ជី ស្នើសុំឲ្យក្រឡាបញ្ជីអាន ដើម្បីឲ្យមានការបកប្រែជាភាសាខ្មែរ ។

**ប្រធានអង្គជំនុំ៖**

ឯកសារនោះលោកដកស្រង់ចេញពីណាមក?

**លោក វីលៀម ស្មីត៖**

នោះគឺជាប្រតិចារឹកដែលបានដកស្រង់ចេញមកពីសំឡេងនៅក្នុងខ្សែភាពយន្ត ។

[១៤:២១:២៥]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាចយកឯកសារ យកឯកសារពីសហព្រះរាជអាជ្ញាមក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថាអ្វីដែលសំខាន់នុ៎ង គឺយើងត្រូវដឹងថា តើអ្នកបកប្រែអាចបកប្រែអ្វីដែលកំពុងនិយាយនៅក្នុងខ្សែភាពយន្តនោះបានឬទេ? បើសិនជាអាចប្រាប់យើងបាន ថាតើអាចបកបាន ឬក៏យ៉ាងម៉េចនោះ?

**លោក វីលៀម ស្មីត៖**

តាមពិតខ្ញុំសង្ឃឹមថា មិនមានភាពរញ៉េរញ៉ៃអ៊ីចឹងទេ អ៊ីចឹងហើយបានជាខ្ញុំបានផ្តល់ឯកសារហ្នឹងទៅឲ្យខាងក្រុមអ្នកបកប្រែមុន កាលពីព្រឹកមិញនេះ ។ ប្រហែលជាពាក្យហ្នឹងមិនសំខាន់ទេ ប៉ុន្តែ ការបង្ហាញខ្សែភាពយន្ត គឺបង្ហាញអំពីកន្លែងដែលថតនោះ ប្រហែលជាអាចនឹងត្រូវអានអត្ថបទនោះ បើសិនជាលោកប្រធានយល់ថាជាការចាំបាច់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំជឿថា ភាពងាយស្រួលនោះ គឺសម្រាប់ឲ្យលោកអាន ហើយនឹងមានការបកប្រែបន្ទាប់មក ។

**លោក វីល្យៀម ស្មីត៖**

នេះគឺជាច្បាប់ចម្លងដែលខ្ញុំមានតែមួយសន្លឹកហ្នឹងទេ បើសិនជាលោកប្រធានអាចប្រគល់មកឲ្យខ្ញុំវិញ ខ្ញុំនឹងអាចអានបាន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំជឿថា យើងអាចយកខ្សែភាពយន្តហ្នឹងចេញពីលើអេក្រង់បាន ហើយបង្វិលរូបភាពមកចរន្តធម្មតាវិញ ។

**សួរដោយលោក វីល្យៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ លោក កាំង ហ្គេកអ៊ាវ ខ្ញុំនឹងអានជាសង្ខេបនូវប្រតិចារឹកនៃសំឡេងដែលគេបានបញ្ចូលនៅក្នុងខ្សែភាពយន្តដែលលោកទើបតែបានឃើញអម្បាញ់មិញនេះ ។ គេបាននិយាយថា ឈ្លើយសឹក ត្រាន់ វ៉ាន់ធៀង បានបង្ហាញពីផែនការរបស់បក្សកុម្មុយនីស្តវៀតណាម ដើម្បីបង្កើតរបបអាយ៉ងមួយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ចម្លើយសារភាពទាំងអស់នេះបង្ហាញយ៉ាងច្បាស់ថា វៀតណាម មានបំណងបង្ខំប្រទេសកម្ពុជាឲ្យចូលរួមក្នុងសហព័ន្ធឥណ្ឌូចិនដែលគ្រប់គ្រងដោយ-- ។ បាទនេះគឺភាសាអង់គ្លេសដែលបានបញ្ចប់នៅក្នុងខ្សែវីដេអូនោះ ។

**ស៖** សំណួររបស់ខ្ញុំដែលដាក់ចំពោះលោកគឺថា តើខ្សែភាពយន្តដែលលោកបានឃើញនោះ គឺជាអ្វីដែលលោកបាននិយាយពីមុនមកនោះឬ? គឺឈ្លើយសឹកវៀតណាមដែលត្រូវបង្ខំឲ្យសារភាពនៅក្នុងមន្ទីរធ្វើការរបស់លោកនៅស-២១ នោះឬ?

[១៤:២៥:០៤]

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមធ្វើការចាប់អារម្មណ៍ចំពោះខ្សែភាពយន្តអម្បាញ់មិញ ។ ទិដ្ឋភាពរួម វាជារបស់មួយដែលយើងខ្ញុំទទួលបាន ក៏ប៉ុន្តែ ចម្លើយសារភាពនៅពេលនុ៎ងដូចយើងខ្ញុំអត់ឲ្យនិយាយហូរហែពេកទេ ។ មកដល់លើកគោរពដៃអឹចឹង ខ្ញុំឈ្មោះអីចេះមក ឧទាហរណ៍ ខ្ញុំឈ្មោះ ឡេ វាំងគៀត អីចឹង ឧទាហរណ៍ អ្ហ៊ុ! យកឈ្មោះគេធំណាស់មកនិយាយ អាយុប៉ុណ្ណោះ ចូលទាហានពីឆ្នាំនេះ មានឋានប៉ុណ្ណោះ គេបញ្ជូនខ្ញុំមកឲ្យវាយ ។ ហើយនៅគោរពអីចឹង អត់មាននិយាយវែងទេ បើមាននិយាយវែង គឺយក*កុងហ្វេសស្យុង* យកសេចក្តីសារភាពដែលមានថតខ្សែអាត់មកបញ្ចូលហើយ ។

ដូច្នេះគេមានបញ្ចូលហើយ មិនមែនជារបស់សុទ្ធ របស់ស-២១ ដែលយើងខ្ញុំផលិតទេ ។ នេះខ្ញុំចាប់អារម្មណ៍អ៊ីចឹង ជូនជាការចាប់អារម្មណ៍សិន ។ នេះសូមជម្រាបលោកប្រធានប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងលោកនិយាយថា ខ្សែភាពយន្តហ្នឹង គឺមិនមែនថតនៅក្នុងកន្លែងលោកធ្វើការទេឬ?

**ឆ៖** អរគុណៗ លោកសួរបញ្ជាក់អ៊ីចឹង កន្លែងខ្ញុំធ្វើការនៅផ្លូវលេខ៩៥ ។ កន្លែងដែលបង ម៉មណៃ សួរចម្លើយយួន អំ វៀតណាម នៅទៅខាងលិចនោះ នៅខាងលិច ។ ដូច្នេះ កន្លែងសួរចម្លើយវៀត-ណាម ទៅផ្សេង ខ្សែអាត់ដែលគេថតសម្រាប់ផ្សាយតាមវិទ្យុជាខ្សែអាត់មួយផ្សេង ឯចំណែកខ្សែអាត់ដែលថតកុនតែប៉ុណ្ណឹង ប៉ុន្មានម៉ាត់ហ្នឹងទេ ។ គោរពដៃអ៊ីចេះ គោរពនៅដៃត្រង់អ៊ីចឹង ។ នេះទិដ្ឋភាពដែលយើងអាចទទួលបាន ហើយនិងរឿងដែលខ្ញុំឃើញប្លែក ។ សូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើលោកស្គាល់ថា រូបដែលមានបង្ហាញនៅក្នុងខ្សែភាពយន្តអម្បាញ់មិញហ្នឹង គឺជាកន្លែងលោកធ្វើការ ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំមិនបានចំណាំការ៉ូឥដ្ឋទេណា សូមជម្រាបដោយត្រង់ ខ្ញុំអត់បានចំណាការ៉ូឥដ្ឋទេ ក៏ប៉ុន្តែនៅក្រោយកន្លែងហ្នឹងដែលឲ្យទាហានយួនគោរពណា ទាហានវៀតណាមគោរពណា ជារូបសញ្ញាជាតិនៃ--របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ឃើញរូបហ្នឹងក៏ដូចជាមិនច្បាស់ ប៉ុន្តែឥឡូវយើងទទួលស្គាល់ថាអាហ្នឹងវាជាកន្លែងខ្ញុំទៅចោះ ព្រោះការ៉ូឥដ្ឋក៏ខ្ញុំមិនបានចំណាំ អំមិញការ៉ូឃើញច្បាស់ៗ ។ នៃអាសញ្ញាជាតិហ្នឹងដូចឃើញមួយភ្លែតបន្តិច រួចឯកសណ្ឋានដូចព្រាលៗអាម៉េច យ៉ាងម៉េច ខ្ញុំមិនច្បាស់ ក៏ប៉ុន្តែ លំនាំប្រហែលគ្នាហ្នឹង ។ ប៉ុន្តែ ដល់សេចក្តីសារភាពវែងពេក មិនមែនសេចក្តីសារភាពដែលគេធ្វើនៅហ្នឹងមុខខ្ញុំនោះទេ ។

[១៤:២៨:០០]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំមានសំណួរចុងក្រោយពីរបីទៀត ទាក់ទងទៅនឹងការចងចាំរបស់លោក ។ តើជាការត្រឹមត្រូវទេ ដែលខ្ញុំអាចនិយាយថាពិបាកនៅក្នុងការចងចាំផ្នែកមួយចំនួនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម ដោយសារពេលវេលាបានកន្លងទៅជាច្រើនឆ្នាំមកហើយនោះ?

**ឆ៖** រឿងនេះត្រូវម្យ៉ាងហើយ ប៉ុន្តែម្យ៉ាងទៀត ខ្ញុំដឹងតិច សំខាន់មែនទែនខ្ញុំដឹងតិច ដូចខ្ញុំបាននិយាយហូរហែជម្រាបលោកចៅក្រម ហើយនិងលោកជំទាវ ខាតវ៉ាយច៍ ហើយៗ ថាខ្ញុំដឹងតិច ។

**លោក វាលៀម ស្មីត៖**

សូមអរគុណ លោកប្រធានខ្ញុំអត់មានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមប្រគល់វេទិកានេះជូនទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយចាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ក្រុមបួនមុន ។ សូមអញ្ជើញមេធាវី ។

**សួរដោយលោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន លោកស្រី លោកចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គសវនាការជាទីគោរព ។

ខ្ញុំបាទមានសំណួរតិចតួចទេ ដើម្បីសួរទាក់ទិននឹងជម្លោះប្រដាប់អាវុធ ។ ថ្ងៃនេះខ្ញុំបានឮលោកកាំង ហ្គេកអ៊ាវ ហៅ ឌុច លោកបានមានប្រសាសន៍ស្តីអំពី ការដោះលែងចំណាប់ខ្មាំង ឬក៏ពួកចលនាតស៊ូ ហ្វុលរ៉ូ តែពីថ្ងៃមុនលោកមិនបានរៀបរាប់នូវសំណួរនេះទេ ។ ហើយខ្ញុំបាទខ្ញុំក៏បានសួរហើយ គាត់ថាបើមានពេលវេលាចាំបាច់គាត់នឹងបញ្ជាក់ អ៊ីចឹងថ្ងៃនេះទាក់ទងជាមួយយើងបានឮទាំងអស់គ្នាថា មន្ទីរស-២១ មានដោះលែងមនុស្ស គ្រាន់តែជាជនជាតិបរទេស ឬអ្នកតស៊ូ ហ្វុលរ៉ូ តែប៉ុណ្ណោះ ។ អ៊ីចឹងនៅក្នុងការឆ្លើយបំភ្លឺថ្ងៃនេះ ទាក់ទងជាមួយនឹងជនជាតិវៀតណាម ទាហានវៀតណាម ឬគិញវៀតណាម ដែលយើងច្រើនតែយកមកនិយាយដេញដោល ។

**ស៖** ប៉ុន្តែ ជាសំណួររបស់ខ្ញុំបាទ ថាតើនៅក្នុងពេលដែលមានជម្លោះ ទោះតូច ទោះធំរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសវៀតណាម ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ឡើងមក ។ តើលោកបានដឹង ឬបានឮថាជម្លោះតូចតាចនៅតាមបណ្តោយព្រំដែនកម្ពុជា និងវៀតណាមដែរឬទេ?

[១៤:៣១:២៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ឯកសារព្រឹកមិញ យើងឃើញទាំងអស់គ្នាហើយ គេបញ្ជូនមនុស្សពី២៥ ពីខាងស្អាងកោះធំ ពីខាងកោះធំមក ។

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ សំណួរនេះដូចច្រំដែល សូមមេធាវីរកសំណួរថ្មីផ្សេងទៀត ។

**លោក ហុង គីមសួន៖**

នេះជាសំណួរដែលខ្ញុំចង់សួរថាការដឹង មិនមែនគាត់ច្បាស់ដូចថ្ងៃ០៦ មករា ទេ ព្រោះទាក់ទងជា

មួយនឹង គាត់ដឹងច្បាស់អំពីគេប្រកាសសង្គ្រាម ឬសង្គ្រាមកើតឡើងនៅថ្ងៃទី០៦ មករា ៧៨ ។ ដោយសារទាក់ទិនជាមួយនឹងការបញ្ជូនឈ្លើយសឹក ឬគិញ ដែលយើងកំពុងតែនិយាយគ្នានេះ ។ អំមិញលោកព្រះរាជអាជ្ញាលោកបានសួរទាក់ទិនជាមួយនឹង សុន សេន ដែលបានចេញទៅខាងមុខរហូតដល់បញ្ចាំងឯកសារស្តីអំពីចម្លើយរបស់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅសហថៅក្រមស៊ើបអង្កេត ។

អ៊ីចឹងសំណួររបស់ខ្ញុំសួរថា លោកមានដែលបានឆ្លើយបំភ្លឺចំពោះមុខតុលាការយោធា ខ្ញុំបាទសូមបង្ហាញឯកសារ ដែលមានលេខ ERN 00320808 នៃឯកសារ E52/4.41 ដោយកាលនោះមានលោកមេធាវី ការ សាវុត្ថ នៅចូលរួមស្តាប់ផងដែរ គឺកំណត់ហេតុយកចម្លើយចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០០២ ។ ចំណុចនេះខ្ញុំបាទសូមអនុញ្ញាតលោកប្រធានឲ្យខាងក្រឡាបញ្ជីអាននៅក្នុងទំព័រ ដែលខ្ញុំបាទអានជម្រាបអម្បាញ់មិញដែលមានលេខ ERN 00320808 ជាភាសាខ្មែរ ខ្ញុំបាទអត់មានជាភាសាអង់គ្លេស និងភាសាបារាំងទេ ។ ហើយដើម្បីឲ្យលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច គាត់ឆ្លើយបំភ្លឺមកវិញទាក់ទងជាមួយនឹងចម្លើយរបស់គាត់ត្រង់ចំណុចនេះ ។ ហើយខ្ញុំបាទសូមបញ្ជាក់បន្ថែមថា គឺយើងយកពីចម្លើយ “ឆ” មានន័យថា “ឆ្លើយ” ចុះមកក្រោម ។

**ប្រធានអង្គជំនុំ៖**

អានត្រង់ចំណុចណាទៅលោកមេធាវី? ហើយទំព័រទីប៉ុន្មាន?

**លោក ហុង គឹមសួន៖**

ជម្រាបលោកប្រធានក្នុងឯកសារនេះមិនដាក់ទំព័រទេ ប៉ុន្តែមានលេខ ERN ជាភាសាខ្មែរ 00320808 ហើយបើជាឯកសារអក្សរ E52/4.41 ។

[១៤:៣៥:១៤]

**ប្រធានអង្គជំនុំ៖**

នៅចំណុចដែលមានពាក្យថា “ឆ” ទាំងស្រុងនៅចំណុចនេះតែម្តង ឬក៏ប៉ុន្មានបន្ទាត់?

**លោក ហុង គឹមសួន៖**

សូមជម្រាបលោកប្រធាន បើយើងរាប់ពីជួរក្រោមទៅវិញ មួយ, ពីរ, បី, បួន, ប្រាំ, ប្រាំមួយ, ប្រាំពីរ, ប្រាំបី, ប្រាំបួន ត្រឹមបន្ទាត់ទីប្រាំបួនចុះមកក្រោម ត្រង់ពាក្យថា ចំណែកខ្ញុំទទួលភារកិច្ចដែលចាត់តាំង ។ អ៊ីចឹងខ្ញុំបាទមិនចង់អានខ្លួនឯងទេ ចង់ឲ្យខាងក្រឡាបញ្ជីអានឲ្យបានឮទាំងអស់គ្នាតែម្តង ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឃើញហើយឬនៅ? អាចអានបានទេ? អានតាមការស្នើសុំរបស់លោកមេធាវី ហុង គឹមសួន ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ចំណែកខ្ញុំទទួលភារកិច្ចដែលចាត់តាំងអ្នកទោស ណាត ឲ្យអ្នកណាសួរមើលឯកសារចម្លើយអ្នកទោស រៀបចំឯកសារចម្លើយអ្នកទោស ផ្ញើទៅលើដឹកនាំប្រជុំជីវភាព ។

ខណៈដឹកនាំអប់រំវគ្គតាមការដែលមាន តែរវល់បំផុតសម្រាប់ខ្ញុំពីអានឯកសារអ្នកទោសខ្លួនឯង ។ នៅពេលដែលចាប់កម្មាភិបាលអស់ ខ្ញុំឡើងជាលេខាភូមិភាគពួសាន ក្នុងពេលនោះប្រធាន ស-២១ គឺគាត់ នួន ជា ហើយខ្ញុំក៏នៅជាមួយលោក សុន សេន ។ ខ្ញុំទទួលបញ្ជាតាមផ្លូវពីរ ទីមួយ គឺទូរស័ព្ទ និងទីពីរ គាត់ហៅទៅធ្វើការជាមួយ ហើយក្រោយមកជាមួយ នួន ជា ។ គាត់មិនដែលទូរស័ព្ទហៅខ្ញុំទៅធ្វើការពីពីរទៅបីថ្ងៃ យ៉ាងយូរម្តង ។ ខ្ញុំសូមធ្វើការសង្កេតបញ្ហាមួយដែល ណាត គាត់នៅធ្វើប្រធាន ។ ឈ្មោះ ឈឹម សំឱយ ហៅ ប៉ង់ និងមិត្ត លីន ចុះទៅស-២១--

**សួរដោយលោក ហុង គឹមសួន៖**

អនុញ្ញាតត្រឹមហ្នឹងបានលោកប្រធាន មិនវែងពេក ។

**ស៖** បាទសូមឲ្យលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច លោកបំភ្លឺអង្គសវនាការនៅពេលនេះបន្តិច ព្រោះនៅក្នុងនេះទាក់ទងជាមួយនឹងការចាកចេញរបស់ សុន សេន ទៅខាងមុខ ហើយក្នុងនេះលោកបានក្នុងឯកសារថាលោកនៅផ្ទាល់ ឬក៏នៅជាប់ជាមួយនឹងគាត់ ។ តើវាមានន័យថា ទាក់ទងពីបន្ទាត់ដែលក្រឡាបញ្ជីអានអំមិញហ្នឹង ទាំងការងារលោក ទាំងទៅជាប់ជាមួយនឹង សុន សេន មានន័យយ៉ាង ម៉េចនៅក្នុងឯកសារដែលលោកឆ្លើយ?

[១៤:៣៨:៣៧]

**ឆ៖** ការអាន ហើយនិងអត្ថបទនេះរាងពិបាកតតាក់តតុប រាងតតាក់តតុប ពិបាករំឮកបញ្ហាឡើងវិញ ។ ខ្ញុំសូមលោក គឹមសួន អានខ្លួនឯងឲ្យស្រួលតាមឃ្លា តាមពាក្យអីឲ្យស្រួលបួល ។ ហើយខ្ញុំជម្រាបឲ្យត្រង់ ខ្ញុំមានឯកសារហ្នឹង ប៉ុន្តែរកអត់ឃើញទេ ។ បើរកឃើញ អាហ្នឹងវាស្រួល ខ្ញុំរកអត់ទាន់ឃើញ ។

**លោក ហុង គីមសួន៖**

សូមលោកប្រធានអនុញ្ញាតជូនទៅលោក កាំង ហ្គេកអ៊ាវ មួយច្បាប់ ហើយខ្ញុំបាទអានដើម្បីឲ្យគាត់យល់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមន្ត្រីតុលាការយកឯកសារ មកជូនជនជាប់ចោទ ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមអានតាមការស្នើសុំរបស់លោក កាំង ហ្គេកអ៊ាវ ។ ទំព័រទីពីរ យើងរាប់បន្ទាត់ទីប្រាំបួន នៃទំព័រទីពីរ ពីក្រោមឡើងវិញ ត្រង់ចំណុចថា៖

ចំណែកខ្ញុំទទួលភារកិច្ចដែលចាត់ចែងអ្នកទោស ។ ណាត ឲ្យអ្នកណាសួរ មើលឯកសារចម្លើយអ្នកទោស រៀបចំឯកសារចម្លើយអ្នកទោស ផ្ញើទៅលើ ដឹកនាំប្រជុំជីវភាព (ប៉ុន្តែ ក្នុងនេះសរសេរជាសញ្ញានៃ *ម៉ាតេម៉ាទិក*) ក្នុងខណៈដឹកនាំអប់រំវគ្គតាមការដែលមាន ។ តែរវល់បំផុតសម្រាប់ខ្ញុំពីអានឯកសារអ្នកទោសខ្លួនឯង ។ នៅពេលដែលចាប់កម្មាភិបាលអស់ ខ្ញុំឡើងជាលេខាភូមិភាគព្លសាន ។ ក្នុងពេលនោះប្រធានស-២១ គឺគាត់ នួន ជា ។ ហើយខ្ញុំក៏នៅជាមួយលោក សុន សេន ។ ខ្ញុំទទួលបញ្ជាតាមផ្លូវពីរ ។ ទីមួយ គឺទូរស័ព្ទ និងទីពីរ គាត់ហៅទៅធ្វើការផ្ទាល់ជាមួយ ហើយក្រោយមកជាមួយ នួន ជា ។ ខ្ញុំបាទ សូមអានតែប៉ុណ្ណេះ ។

**ជនជាប់ចោទ៖**

លោកចង់ឲ្យខ្ញុំបញ្ជាក់កន្លែងណា?

**សួរដោយលោក ហុង គីមសួន៖**

**ស៖** អ្វីដែលខ្ញុំបាទអានអម្បាញ់មិញនេះគឺទាក់ទងជាមួយ ដែលលោកបានជម្រាបអង្គសវនាការស្តីអំពីសភាពការ ដែលមានសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ហើយត្រូវបាន សុន សេន ចាកចេញទៅនោះ ។ ពេលនោះ ខ្ញុំមិនដឹងថា ក្នុងនេះនិយាយពីឆ្នាំណាទេ ប៉ុន្តែ ឯកសារនេះបានបញ្ជាក់អំពីលោកទៅនៅជាមួយ សុន សេន នេះទីមួយ ។ តើមានន័យយ៉ាងម៉េចទៅនៅជាមួយ សុន សេន ផ្ទាល់ និងទីពីរ ក្រោយពេលចាប់កម្មាភិបាលអស់ ខ្ញុំឡើងជាលេខាភូមិភាគព្លសាន ។

**ឆ៖** ខ្ញុំឃើញបញ្ហាឯកសារនេះឃ្លាតឆ្ងាយការពិត។ ។ ខ្ញុំឯណាទៅដែលឡើងធ្វើលេខាភូមិភាគព្លសាន ។ បើ ពូ នួន មែន។ ។ ពេលចាប់ យ៉ា មក ពូនួន ឡើងលេខាភូមិភាគព្លសាន ។ បងវី ឈ្មោះ

ដើម អ៊ុំ ណេង នៅជាអនុលេខា ។ ដូច្នេះ ការកត់ត្រានៅពេលនោះ ប្រហែលជាអាចលោតបាត់ពាក្យខ្លះៗ ។ ពូនួន ឡើងជាលេខាភ្លៀសាន ក្រោយពីចាប់ ម៉ែន សាន ហៅ យ៉ា ។ បង អ៊ុំ ណេង ហៅ វី នៅតែជាអនុលេខា ។ នេះរឿងពិតមួយ ។

រឿងពិតទីពីរមិនមានអីប្លែកទេ នៅជាមួយលោកគ្រូ សុន សេន ខ្ញុំទទួលការណែនាំការងារ គាត់ត្រួតពិនិត្យការងារ តម្រង់ទិសការងារ ដាក់ផែនការថ្មីឲ្យស្មើតែរាល់ល្ងាច ។ ខ្ញុំនិយាយថា "ស្មើ" ស្មើតែរាល់ល្ងាចតាមទូរស័ព្ទ ។ ហើយពីរបីថ្ងៃ គាត់ហៅខ្ញុំទៅធ្វើការម្តង ។ នេះជាសភាពការណ៍ពិត ។ ហើយដល់ជាមួយ ពូនួន គាត់មិនប្រើទូរស័ព្ទទេ ក៏ប៉ុន្តែឲ្យមិត្តប៉ង់ ចុះមកគ្រប់គ្រងខ្ញុំ អានេះខាងនយោបាយ ។ ឯចំណែកមិត្តវី មកខាងយោធា ជាពិសេសទាក់ទងជាមួយមិត្តហ៊ី ។ នេះសភាពការណ៍ពិត ។

ហើយលោកគ្រូ សុន សេន គាត់អញ្ជើញទៅ ចៀសមិនរួចទេ ។ ដូចខ្ញុំនិយាយព្រឹកមិញអ៊ីចឹងនៃការចាំបាច់សមរភូមិដែលពេលខ្លះ ខ្ញុំនិយាយទៅវាភ្ញាត់សម្តី វាទៅជាសង្គ្រាមរីកវរគ្នាខ្លាំងហើយពេលបានលោកគ្រូ សុន សេន ចេញទៅ ។ អេ៎! តាមពិតមេខ្ញុំនៅតែស៊ីញ៉េឯកសារនគរបាលដែលខ្ញុំឃើញមកដល់ដៃខ្ញុំ គឺថ្ងៃ១១ ខែវិច្ឆិកា ឆ្នាំ១៨៧៧ ។

[១៤:៤៣:៤៥]

**ស៖** សូមអរគុណ ។ អ្វីដែលខ្ញុំបាទ ចង់សួរនេះគឺសួរទាក់ទងនឹងពាក្យដែលថា ទៅធ្វើការផ្ទាល់នេះ ។ អ៊ីចឹងមិនមែនផ្ទាល់នៅជាមួយ សុន សេន ទេ ឬយ៉ាងម៉េចបាទ?

**ឆ៖** ចុះមកផ្ទាល់ ។ សូមទោស អរគុណ ។ ខ្ញុំអត់ដែលបានទៅនៅផ្ទះជាមួយនឹងមេខ្ញុំទេ អត់សោះ ។ ដែលហៅថាផ្ទាល់ហ្នឹងគឺ ដឹកនាំផ្ទាល់ ប្រចាំ គេតាមដានការងារយើងជាប់ជាប្រចាំផ្ទាល់អាហ្នឹងអ៊ីចឹងហើយ ។ តាមគោលការណ៍មាត្រា៨ នៃលក្ខន្តិកៈបក្ស ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរទៅទៀត លោកបានជម្រាបជូនអង្គសវនាការអំពីការដឹងពិតប្រាដកនៃការសង្គ្រាមគឺថ្ងៃទី៦ មករា ១៩៧៨ ។ អ្វីដែលលោកលើកឡើងញឹកញាប់ ។ ខ្ញុំសុំសួរលោកទាក់ដែលលោកបានមានប្រសាសន៍ទាក់ទងអំពីជម្លោះ នៅក្នុងឯកសាររបស់លោក ណាយ៉ាន់ ចាន់ដាតើលោកបានដឹងទេ អំពីក្រោយពេលវៀតណាម រំដោះទឹកដីវៀតណាមខាងត្បូងបានពីរសប្តាហ៍ ទ័ពកម្ពុជាប្រជាធិបតេយ្យបានឡើងទៅលើកោះត្រល់ ឬយើងហៅថា កោះភូកុក ដែលតាមជាឈ្មោះរបស់វៀតណាម ព្រមទាំងកោះដទៃទៀត ។ ហើយដែលលោកមានប្រសាសន៍ព្រឹកមិញថា អាចច្រឡំគ្នាជាមួយនឹងការចាប់កប៉ាល់ម៉ាយ៉ាហ្គេនោះ ។ តើចំណុចនេះលោកបានដឹងទេ? ដោយមានសំណួរទាក់ទង

នឹងកន្លែងនេះទៀត ។

**ឆ៖** សូមជម្រាបលោក គឹមសួន ខ្ញុំអត់ដឹងទេ ។ ពេលនុំងខ្ញុំដាក់ខ្សែពីមេផង មិនសូវបានស្តាប់វិទ្យុផង រវល់តែដើរទៅរង់ចាំស្តាប់ដំណឹងពីមេ ។ តើមេមានហៅខ្ញុំអង្កាល់ ហ្នឹងខ្ញុំអត់មានជាប់កិច្ចការងារអ្វី មិនបានគិតគូ ។

**ស៖** សូមអរគុណ ។ ខ្ញុំត្រឡប់មកទាក់ទងជាមួយនឹងពួកចលនាតស៊ូ ដែលលោកបានជម្រាបអង្គសវនាការនិយាយអំពីការដោះលែងឈ្លើយសឹក ឬអ្នកដែលចាប់មកស-២១ ពីមុន នេះខ្ញុំមិនច្បាស់ទេ តែខ្ញុំច្បាស់ត្រង់ថា ប៉ុល ពត មិនដែលប្រើសិទ្ធិខ្លួនគាត់ដោះលែងមនុស្ស ដែលមកដល់ស-២១ ហើយទេ ។ តែព្រឹកមិញនេះ ខ្ញុំបាទបានឮលោកជ្រាបអង្គសវនាការអំពីការដោះលែងពួក ហ្វុលរ៉ូ ដោយ ប៉ុល ពត គិតថាជាមិត្ត ។ តើ ប៉ុល ពត ប្រើសិទ្ធិនេះដោះលែងពួកបរទេស ដែលចាប់បាននោះឬយ៉ាងម៉េច?

[១៤:៤៦:៤៣]

**ឆ៖** អរគុណលោក គឹមសួន ដែលសួរបញ្ជាក់ខ្ញុំបញ្ហានេះ ។ ទីមួយ អាហ្នឹងយើងត្រូវយល់មាគ៌ានយោបាយ គោលនយោបាយរបស់បក្ស ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មាំងត្រូវតែកម្ទេច ។ វៀតណាមក៏ដោយ ឈ្លើយសឹកវៀតណាម ដែលច្បាប់អន្តរជាតិការពារក៏ដោយ បញ្ហាជនដែលគ្នាអត់មានបាទដៃប្រលាក់ឈាមអីហ្នឹងក៏ដោយ ឲ្យគាត់ថាខ្មាំងត្រូវតែកម្ទេច គាត់អត់ដោះលែងទេ ។ ទោះបីគាត់មានសិទ្ធិដោះលែង ក៏គាត់មិនប្រើសិទ្ធិហ្នឹងដែរ ខ្មាំងកម្ទេច ។ ដល់ពេលណាទឹកចូលច្រមុះ ។ លោកស្គាល់ហើយ ភាសាខ្មែរទឹកចូលច្រមុះ ។ ដល់ពេលទឹកចូលច្រមុះ អង្គការ ហ្វុលរ៉ូ ដែលពីដើមគាត់ចាត់ទុកជាខ្មាំង គាត់ចាត់ទុកជាមិត្ត ។ ដល់កាលណាគាត់ចាត់ទុកជាមិត្ត អំណាចជាអគ្គបញ្ជាការ គាត់ឲ្យគេដោះលែង ព្រោះមិត្ត គាត់ឲ្យគេដោះលែងពួកហ្វុលរ៉ូ ពីព្រោះវាជាមិត្ត ។ ជាខ្មាំងត្រូវតែកម្ទេច ជាមិត្តត្រូវតែឧបត្ថម្ភ នេះបែងចែកមិត្ត និងសត្រូវគឺអីចឹង បក្សកុម្មុយនីស្តកម្ពុជា ។ នេះខ្ញុំសូមបញ្ជាក់ជូនអីចេះ ។

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំទាក់ទងជាមួយនឹងសំណួររបស់លោកព្រះរាជអាជ្ញាសួរអម្បាញ់មិញដែរ ដែលលោកបានឆ្លើយថា លោកទើបតែដឹងអំពីច្បាប់ ឬសន្ធិសញ្ញាអន្តរជាតិនៅពេលដែលមានដីកាសហចៅក្រមស៊ើបអង្កេតហៅលោកទៅសួរ ។ សំណួរខ្ញុំសួរថា នៅពេលដែលលោករៀនសូត្រ ឬចូលវគ្គអប់រំ ឬស្តាប់បទឧទ្ទេសនាមជាមួយនឹងថ្នាក់មជ្ឈិម ដែលមាននិយាយអំពីការចុះហត្ថលេខាទទួលស្គាល់សិទ្ធិជាអន្តរជាតិ ឬក៏សិទ្ធិជនភៀសខ្លួន ឬការប្រល័យពូជសាសន៍រវាងកម្ពុជា

ប្រជាធិបតេយ្យ ជាមួយនឹងអង្គការសហប្រជាជាតិដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់លោក គឹម សួន ខ្ញុំអត់មានបានចូលប្រជុំជាមួយថ្នាក់មជ្ឈិមទេ ហើយខ្ញុំអត់បានចូលទៅរៀនជាមួយនឹងគេ អ្នកដែលសមាជិកមជ្ឈិមនោះទេ ។ ក៏ប៉ុន្តែ បុគ្គលដែលមកឧទ្ទេសនាមឯកសារបក្សឲ្យខ្ញុំ គឺពិតជាអចិន្ត្រៃយ៍មជ្ឈិម សុន សេន ។ ដូច្នេះ ខ្ញុំអត់ទៅរៀនសូត្រជាមួយនឹងគេ ដូច ស៊ូ ម៉េត ដូច បង មុត អីៗទេ ។ ខ្ញុំរៀនគ្នាខ្ញុំ កម្មាភិបាលមធ្យម ដោយមានលោកគ្រូ សុន សេន ជាអ្នកឧទ្ទេសនាម ។ នេះខ្ញុំសូមកែប៉ុណ្ណឹងបន្តិច កុំឲ្យខ្ញុំវាឡើងមជ្ឈិមទៅទៀត ។ ខ្ញុំមិនចង់ឡើងមជ្ឈិមដោយអត់មានគេតម្លើងទេ ។ នេះទីមួយ ។

ទីពីរទៀត ឯកសារដែលរៀនសូត្រ គេមិនរៀនសូត្រអំពីច្បាប់ទម្លាប់អន្តរជាតិទេ អានេះគេហៅថាមាគ៌ាវណ្ណៈនាយទុន ។ គេអត់បង្រៀនទេ ឯកសារដែលនៅសល់ ខ្ញុំជឿថាលោកបានឯកសារបង ម៉ម ណៃ ហើយ ដែលថៅក្រមស៊ើបអង្កេតប្រគល់ឲ្យខ្ញុំគឺលេខ 00077661 ដល់ 00078056 ។ លោកមើលចុះ៣៩៦ទំព័រ ERN នេះមានច្បាប់ដែលបក្សកុម្មុយនីស្តកម្ពុជា ឧទ្ទេសនាមឲ្យពួកយើងខ្ញុំនោះមាននៅក្នុងនុ៎ង អត់និយាយអំពីច្បាប់អន្តរជាតិ អ្នកណាចុះហេតុលេខាពីណាពីណឹមកទេ ។ ពិតជា ប៉ុល ពត គាត់ចាត់ទុកច្បាប់អស់នេះ ជាច្បាប់វណ្ណៈនាយទុន ។ នេះសូមនិយាយខ្លីប៉ុណ្ណឹង ។

[១៤:៥០:៣៥]

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំ សួរទាក់ទិនជាមួយនឹងការវ៉ៃ (សូមទោស) ដូចលោកព្រះរាជអាជ្ញាលោកឡើង ស្តីអំពីការឈ្លានពាន នៅក្នុងឯកសារសរសេរថា “ឈ្លានពានដោយកងទ័ពរបស់វៀតណាម ជាទ្រង់ទ្រាយធំនៅលើកទីពីរ” ។ ចំពោះខ្លួនលោកផ្ទាល់ ដែលលោកបានជម្រាបជូនអង្គសវនាការអំពីការបញ្ជាដោយប្រយោល នៅមុននេះបន្តិចឲ្យទៅបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់លោកទៅដឹកឈ្លើយសឹកជាទាហានវៀតណាម ។ នេះខ្ញុំបានស្តាប់ហើយ ។ សំណួរខ្ញុំសួរទាក់ទិនជាមួយនឹងការទទួលយក ក្នុងបញ្ជីអ្នកទោសនេះមានជនជាតិសៀម ជនជាតិលាវ ជនជាតិឥណ្ឌា ផ្សេងៗនោះ ។ តើអ្នកទាំងនោះទាក់ទិននឹងជម្លោះប្រដាប់អាវុធ ឬទាក់ទិននឹងទំនាស់អ្វីដែរឬទេ ដែលចាប់បញ្ជូនមក?

**ឆ៖** លោកប្រធានជាទីគោរព! រឿងនេះវាក្រៅរឿងទំនាស់ប្រដាប់អាវុធទេ វាក្រៅរឿងទំនាស់ប្រដាប់អាវុធរវាងខ្មែរនិងវៀតណាមទេ ។ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបអង្គសវនាការ កាលពីលើកមុនខ្លះៗហើយ ទាក់ទងជាមួយនឹងករណីជម្លោះរវាង ប៉ុល ពត ជាមួយនឹង ឡេ យន់ ។ អ៊ីចឹងសំណួររបស់ខ្ញុំ ខ្ញុំសួរថា សូមបញ្ជាក់បន្តិចថា លោកថា នេះជាការស៊ី គេស៊ីយើង យើងស៊ីគេ ឬក៏គេវ៉ៃយើង យើងវ៉ៃគេ នោះដែលលោកនិយាយជាសម្រាយមកវិញ ។ អ្វីដែលលោកដឹងទាក់ទងនឹងជម្លោះនេះ តើវាកើតមានឡើងនៅក្រោយ ១៧ មេសា ឬវាទាក់ទិនយូរមកហើយ? នេះខ្ញុំស្រង់សម្តីលោក ដែលលោកបានជម្រាបអង្គសវនាការអំពីឆ្នាំ១៩៧៣ ។ អ៊ីចឹង តើជម្លោះដែលទាក់ទិនគ្នានេះ ក៏វាជាជម្លោះប្រដាប់អាវុធដែរ មិនចូលទៅក្នុងយុត្តាធិការមុន១៩៧៥ ទេ តែខ្ញុំគ្រាន់តែសួរថា តើវាទាក់ទងគ្នាដែរឬទេ ពីមុនមកទល់នឹង ១៧ មេសា ១៩៧៥ រហូតមកដល់៦ មករា ១៩៧៩?

[១៤:៥៣:៣២]

**ឆ៖** ទ្រឹស្តីរបស់បក្សម៉ាក្ស-លេនីនលើសាកលលោក គេនិយាយអំពីសង្គ្រាមនិងសន្តិភាព ។ នៅក្នុងពេលសន្តិភាពកម្ពុជានិងវៀតណាម មានទំនាស់នឹងគ្នា ។ ដូចខ្ញុំបានជម្រាបរួចមកហើយ ចាប់តាំងពីឆ្នាំ១៩៥៤ មក ឡេយន់ គាត់នៅតែតាំងខ្លួនគាត់ជាបីតាឥណ្ឌូចិន ។ ផែនការគាត់ក្នុងឋានៈគាត់ជាបីតាឥណ្ឌូចិន ។ នេះគេហៅថាទំនាស់នយោបាយ រហូតៗមក ។ ហើយយើងខ្ញុំជឿថា ក្នុងទំនាស់នយោបាយ ដែលបក្សមនុស្សបុគ្គលពីរនាក់មានបក្សរៀងខ្លួន មានកងទ័ពរៀងខ្លួន ចៀសមិនរួចពីប៉ែងគ្នាមួយជើងម្នាក់ទេ ចៀសមិនរួច បើមិនប៉ែងមួយជើងទេ លេងមួយកែងដៃ អាហ្នឹងចៀសមិនរួចទេ អានេះខ្ញុំយល់អ៊ីចឹង បានជាខ្ញុំមិនយកចិត្តទុកដាក់ ដឹងថាបក្សទាំងពីរនេះ មានមាគ៌ានយោបាយមិនត្រូវគ្នា ។ ហើយទំនាស់មាគានយោបាយនេះ ជាទំនាស់ស្លាប់រស់ ដូចខ្ញុំបានជម្រាបពីថ្ងៃមុនអ៊ីចឹង ។

ដូច្នេះ ទំនាស់ពីមុនៗមក វាជាទំនាស់នយោបាយវាដើរតួ នយោបាយ ទំនាស់នយោបាយវាគ្របសង្កត់ ។ ដល់ក្រោយ៦ មករា នេះខ្ញុំយល់ថា ទំនាស់នេះ សង្គ្រាមវាគ្របសង្កត់ រូបភាពនយោបាយ ។ លែងដោះស្រាយគ្នាជាងនយោបាយហើយ សង្គ្រាមវាគ្របសង្កត់ ។ ដូច្នេះហើយបានជាខ្ញុំមិនសូវជាយកចិត្តទុកដាក់ទេ គិតតែការងារដែលគេបង្ខំឯណោះរាល់ថ្ងៃ ។ នេះមួយទស្សនៈ ទីមួយការងារដែលគេបង្ខំរាល់ថ្ងៃត្រូវតែធ្វើឲ្យហើយ ឲ្យគេ ។ គេតាមដានរាល់បីថ្ងៃ បួនថ្ងៃ ឬយ៉ាងយូរណាស់មួយអាទិត្យម្តង គេហៅខ្ញុំទៅតាមដានការងារហើយ ។ នេះបញ្ជាក់អ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ ប្រកាសសម្រាកកន្លះម៉ោងដើម្បីសម្រាក ហើយនិងមានត្រូវពិភាក្សាអំពីបញ្ហា

មួយចំនួន ដែលពាក់ព័ន្ធជាមួយនឹងរបៀបវារៈ ដែលត្រូវប្រជុំនៅថ្ងៃស្អែកផង ។ រហូតដល់ម៉ោងបីនិងម្ភៃនាទីចូលវិញ បន្តដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង ១៤:៥៦ នាទី ដល់ម៉ោង ១៥:៣៤ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

អង្គជំនុំជម្រះប្រកាស បន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ។ ហើយមុននឹងជូនវេទិកានេះទៅមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី អំពីរបៀបវារៈដែលត្រូវលើកមកប្រជុំពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃស្អែក ទី ១១ ខែមិថុនា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ នៅទីនេះដូចខាងក្រោម៖

១) ការប៉ាន់ស្មាន អំពីរយៈពេលជំនុំជម្រះ សំណុំរឿងក្តីដែលយើងកំពុងតែធ្វើសវនាការនេះ ចាប់ពីពេលប្រជុំនេះទៅរហូតដល់ខែធ្នូ ឆ្នាំ២០០៩ ។

២) លទ្ធភាពចូលរួមរបស់ភាគី និងមេធាវី និងបញ្ហាបុគ្គលិកការិយាល័យរដ្ឋបាល ដែលត្រូវគាំទ្រដល់ដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ។

៣) អំពីចំនួនថ្ងៃ និងពេលម៉ោងសម្រាប់ធ្វើសវនាការ ។

៤) ការឈប់សម្រាកមិនធ្វើសវនាករ ការមិនធ្វើសវនាការ ដោយហេតុមានបុណ្យជាតិ បុណ្យអន្តរជាតិ ថ្ងៃសវនាការរបស់អង្គបុរេ ឬក៏កិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៥) ការណែនាំអនុវត្តនូវវិធាន៨៧ ជាពិសេសលើវិធាន៨៧.៣ និងវិធាន៨៧.៦ តាមសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានស្នើសុំធ្វើវិសោធនកម្ម ។

៦) ការបែងចែកពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះបានសម្រេចតាមការស្នើសុំរបស់គូភាគី ជ្រើសរើសពួកគាត់ឲ្យមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ។

៧) បញ្ហាផ្សេងៗទៀត ដែលយើងមិនបានគ្រោង ហើយបើសិនមានបញ្ហា លេចឡើងនូវបញ្ហាផ្សេងៗទៀតនោះ គឺយើងនឹងគ្រោងនូវបញ្ហាផ្សេងៗនេះ ដើម្បីទុកលទ្ធភាពនៅក្នុងការលើកបញ្ហាផ្សេងដែលមាន ក្រៅពីរបៀបវារៈទាំងប្រាំមួយ ដើម្បីមានឱកាសក្នុងការពិភាក្សារកដំណោះស្រាយណាដែលល្អ

ប្រសើរបំផុត ។ ហើយក្នុងគោលបំណងនៃការរៀបចំដំណើរការសវនាការថ្ងៃស្អែកនេះ គឺគោលបំណងរបស់យើងសំដៅធ្វើយ៉ាងណា បង្កើនល្បឿននៅក្នុងដំណើរការពិភាក្សាដេញដោលនេះ ឲ្យបានឆាប់រហ័សតាមលទ្ធភាព ដែលអាចធ្វើទៅបាន ។ ហើយដើម្បីឲ្យបានច្បាស់លាស់ ខ្ញុំសូមប្រគល់វេទិកានេះទៅលោកស្រី ខាតរ៉ាយច៍ ដើម្បីបញ្ជាក់បន្ថែម អំពីរបៀបវារៈដែលជាភាសាអង់គ្លេស ដោយសារយើងជជែកពិភាក្សាគ្នាមានអំឡុងពេលខ្លី ហើយបន្ទាន់ ។ អ៊ីចឹងគឺសុំបញ្ជាក់បន្ថែមទៀត ។

សូមអញ្ជើញ លោកស្រីចៅក្រម ។

[១៥:៣៨:៥៤]

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍៖**

អរគុណ លោកប្រធាន ។ ភាសាអង់គ្លេស គឺបានលើកឡើងច្បាស់ហើយ ប៉ុន្តែ ខ្ញុំសុំចូលទៅដល់របៀប ចំណុចនៅក្នុងរបៀបវារៈ ។ ខ្ញុំចង់លើកឡើងចំណុចមួយ ដើម្បីជាព័ត៌មានដល់ភាគី ។ យើងនឹងមានការស្បថចូលកាន់តំណែងនៅថ្ងៃស្អែកម៉ោងប្រាំបួនព្រឹក ហើយបន្ទាប់មកយើងនឹងរៀបចំសវនាការរៀបចំរបស់យើង ហើយគឺវាមានរយៈពេលខ្លីទេ ចំពោះសវនាការស្បថនោះ ចំពោះអ្នកស៊ើបអង្កេត ។ ដូច្នេះហើយ គឺយើងនឹងរៀបចំនៅពេលបន្ទាប់ពីសវនាការនោះ ។

ចំពោះចំណុចរបៀបវារៈ សម្រាប់កិច្ចប្រជុំរៀបចំសវនាការគឺមានដូចតទៅ៖

១) គឺការប៉ាន់ស្មាន អំពីរយៈពេលជំនុំជម្រះ ។

២) ការពិភាក្សាលើលទ្ធភាពចូលរួមរបស់ភាគី និងមេធាវី និងបញ្ហារដ្ឋបាលផ្សេងៗ លើបញ្ហាបុគ្គលិក និងបញ្ហាផ្សេងៗផ្នែករដ្ឋបាល ។

៣) គឺទាក់ទងទៅនឹងម៉ោង ពេល ថ្ងៃ សម្រាប់ធ្វើសវនាការ និងសម្រាប់ការសម្រាកមិនធ្វើសវនាការ ។

៥) ការណែអនុវត្តវិធាន៨៧, វិធាន៨៧.៣ និងវិធាន៨៧.៦ ជាពិសេសលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំកែប្រែលើវិធានទាំងអស់នេះ ដោយយើងចង់ចំណាយពិភាក្សានៅលើថ្ងៃស្អែកដែរ ។

៦) គឺការបែងចែកពេលវេលា សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឡើងធ្វើសេចក្តីថ្លែង-ការណ៍ ។

៧) គឺទាក់ទងទៅនឹងបញ្ហាផ្សេងទៀត ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចង់លើកឡើង ។

ហើយខ្ញុំសង្ឃឹមថា ការលើកឡើងចំពោះរបៀបវារៈនេះ គឺបានរៀបរាប់ច្បាស់លាស់ទាំងភាសាខ្មែរ និងអង់គ្លេស ។

សូមអរគុណ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

[១៥:៤១:២០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសុំធ្វើការបំភ្លឺមួយ ទាក់ទងនឹងចំណុចបី ដែលភាសាបារាំងបានបកប្រែថា គឺកាលវិភាគ តាមពិតទៅចំណុចនេះ យើងលើកឡើងអំពី ពេល ម៉ោង ថ្ងៃ សម្រាប់ធ្វើសវនាការ ។ យើងមិនមែនលើកឡើងតែអំពីពេលម៉ោងតែប៉ុណ្ណោះទេ គឺមានថ្ងៃនៅក្នុងហ្នឹងផងដែរ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ប្រសិនបើយើងអាចធ្វើទៅបាននោះ គឺសំណើទាក់ទងទៅនឹងវិធាន៨៧.៣ ហ្នឹងគឺគួរតែផ្តល់ជូនភាគីផងដែរ មុនពេលដែលយើងចាកចេញពីសវនាការថ្ងៃនេះ ។ ហេតុអ្វីបានខ្ញុំលើកទៅលើចំណុចនេះ ដើម្បីឲ្យមានភាពស្របគ្នាទៅនឹងសេចក្តីណែនាំផ្សេងៗ ហើយយើងអាចផ្តល់អ្វីដែលមានប្រយោជន៍ ដល់អង្គសវនាការនៅថ្ងៃស្អែក ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ការបន្ថែមឃ្លាមួយនៅក្នុងវិធាន៨៧.៣ ឃ្លាបន្ថែមនោះគឺ ឲ្យកំណត់ឲ្យបានច្បាស់លាស់ និងសមស្របក្នុងតុលាការ ។ ដូច្នេះ លោក លោកស្រី អាចពិនិត្យមើលនៅក្នុងប្រយោគចុងក្រោយនៃចំណុចទី៣ នៃវិធាន៨៧ គឺលើកឡើងថា ភស្តុតាងនៅក្នុងសវនាការត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គសវនាការសាលាដំបូង ប្រសិនបើខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអានក្នុងសវនាការ ។ សំណើសុំរបស់អង្គសវនាការគឺថា ប្រយោគចុងក្រោយនោះគួរ

តែថែងថាគឺ ខ្លឹមសាររបស់វាត្រូវសង្ខេប ឬក៏កំណត់ និងលើកឡើងបញ្ជាក់ឲ្យបានសមស្របនៅក្នុងសវនាការ ។

នេះគឺជាចំណុចដែលយើងស្នើសុំឲ្យមានការផ្លាស់ប្តូរក្នុងការវិសោធនកម្មនៅក្នុងវិធាន៨៧.៣ ។ ហើយក៏មានវិសោធនកម្ម ចំពោះវិធាន៨៧.៦ ផងដែរ គឺបទប្បញ្ញត្តិថ្មីថែងថា ក្នុងករណីសហព្រះរាជអាជ្ញានិងជនជាប់ចោទ បានយល់ព្រមព្រៀងគ្នាថា អង្គហេតុដែលបានចោទប្រកាន់គឺវាមានសរសេរ និងរៀបចំនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ បញ្ជូនរឿងឲ្យទៅជំនុំជម្រះ ហើយមិនបានតវ៉ា ហើយអង្គហេតុទាំងអស់នោះមិនបានតវ៉ា អង្គជំនុំជម្រះអាចពិចារណាថា អង្គហេតុទាំងអស់នោះ គឺត្រូវបានបង្ហាញត្រឹមត្រូវ ។ តើលោកចង់ឲ្យខ្ញុំអានឡើងវិញ ទៅលើចំណុចបទប្បញ្ញត្តិនេះ ឬក៏យ៉ាងម៉េច?

[១៥:៤៤:៥៧]

**លោក វីលៀម ស្មីត៖**

គឺអត់ទេ លោកស្រី ចៅក្រម គឺការលើកឡើងរបស់លោកស្រីចៅក្រម មានប្រយោជន៍ណាស់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំសូមបញ្ជាក់ថា ចំណុចដែលខ្ញុំលើកឡើងនេះ បទប្បញ្ញត្តិទាំងអស់នេះ គឺគ្រាន់តែជាសំណើសុំវិសោធនកម្មតែប៉ុណ្ណោះទេ មិនទាន់បានធ្វើការអនុម័តនៅឡើយទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំស្នើសុំឲ្យមានការបញ្ជាក់ ទៅលើចំណុចទី៦ គឺចំណុចទី៦ នៅក្នុងរបៀបវារៈ គឺការបែងចែកពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីថ្លែងការណ៍ គឺចំណុចនេះ គឺទាក់ទងទៅនឹងការធ្វើសេចក្តីថ្លែងការណ៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ការសួរសំណួរ? ចំណុចទី៦ នៅក្នុងរបៀបវារៈទាក់ទងទៅនឹងចំណុចទី១ គឺទាក់ទងទៅនឹងការប៉ាន់ស្មានអំពីរយៈពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើបទបង្ហាញ ។

ខ្ញុំសូមអរគុណចំពោះការបំភ្លឺរបស់លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត យើងបន្តពិភាក្សាដេញដោលតទៅទៀត ។ សូមអញ្ជើញលោកមេធាវី ហុង គឹមសួន

បន្តនូវសំណួរពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ លើអង្គហេតុនៃជម្លោះប្រដាប់អាវុធនេះ ។ ហើយលោក ត្រូវចំណាយពេលប៉ុន្មានទៀត ដើម្បីក្នុងការសួរនេះ តាមការគិតរបស់លោក?

**សួរដោយលោក ហុង គីមសួន៖**

សូមអរគុណ លោកប្រធាន ។

ខ្ញុំបាទមានតែសំណួរមួយទៀតទេ ហើយក៏ជាការសុំឱ្យខាងជនជាប់ចោទហ្នឹង គាត់ឆ្លើយខ្លីៗ បានហើយ បើគាត់ដឹងគាត់ថាដឹង បើគាត់មិនដឹងទេ ក៏ខ្ញុំបញ្ចប់សំណួរត្រឹមនេះដែរ ។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំទាក់ទងជាមួយនឹងឯកសាររបស់លោក ណាយ៉ាន់ ចាន់ដា ហើយខ្ញុំសុំ លើកយកចំណុចមួយ ដែលមានចែងនៅក្នុងទំព័រលេខ២៤១ ជាអក្សរខ្មែរក្នុងឯកសារ D91/1 ហើយ ទំព័រនេះមានលេខ ERN00191546 ។ អ៊ីចឹងនេះជាសំណួររបស់ខ្ញុំ ដែលទាក់ទងជាមួយនឹងជម្លោះ ប្រដាប់អាវុធដែរ នៅក្នុងទំព័រនេះនៅពាក់កណ្ដាលទំព័រជាអក្សរខ្មែរ និយាយអំពីទំនាក់ទំនងដែលនាំឱ្យ វៀតណាមមានជម្លោះជាមួយកម្ពុជា ហើយដែលមានទាក់ទងដល់ប្រទេសចិន និងប្រទេសសូវៀតផង។ ខ្ញុំបាទគ្រាន់តែសួរថា នេះជាការសរសេររបស់លោក ណាយ៉ាន់ ចាន់ដា ដែលប្រែជាភាសាខ្មែរ តើលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដឹងទេថា វៀតណាមបានផ្សាយវិទ្យុនៅឆ្នាំ១៩៧៨ ស្ដីបន្ទោសប្រទេស ចិនយកទឹកដីកម្ពុជា ឬប្រើកម្ពុជាសម្រាប់ធ្វើជម្លោះជាមួយនឹងប្រទេសវៀតណាម? នេះជាសំណួរចុង ក្រោយរបស់ខ្ញុំប៉ុណ្ណឹងឯង ។

**ឆ៖** វៀតណាម សុំទោសណ៎ា វៀតណាមគេ គេនិយាយពីខែណាឆ្នាំណា?

**ស៖** នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៨ វិទ្យុហាណូយ បានផ្សាយឱ្យដឹង ។

**ឆ៖** សូមគោរពលោកប្រធាន! ឱ្យស្ដាប់ ខ្ញុំមិនស្ដាប់ទេ អត់បានស្ដាប់ទេ ក៏ប៉ុន្តែសង្គ្រាម វាបើក ចំហទៅហើយ ដូច្នេះការចោទប្រកាន់គ្នាតាមវិទ្យុ តាមទូរទស្សន៍ជារឿងធម្មតា រវាងប្រទេសទាំងពីរដែរ សង្គ្រាមផ្ទុះឡើងពេញបន្ទុកនោះ ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។

**លោក ហុង គីមសួន៖**

សូមអរគុណ លោកធាន ខ្ញុំបាទចប់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ សូមប្រគល់វេទកាទៅមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី បើសិនជា មានសូមអញ្ជើញ មេធាវីតំណាងដើមបណ្ដឹងក្រុមបី ។

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព!

ដោយពិនិត្យទៅលើវិសាលភាពដែលយើងកំពុងដេញដោលទៅលើជម្លោះប្រដាប់អាវុធ ហើយពិនិត្យទៅលើអង្គហេតុដែលបានលើកឡើង គឺវាមិនប៉ះពាល់ទៅនឹងចម្លើយផ្សេងៗដែលយើងបានលើកឡើង ។ ហើយដោយយើងពិនិត្យមើលទៅលើស្ថានភាពដែរថា ក្រុមដើមបណ្តឹងរដ្ឋប្បវេណីលេខបី មិនចង់ធ្វើការពន្យារទៅលើការពិភាក្សាដេញដោល គឺយើងខ្ញុំមិនចង់ធ្វើការតាំងសំណួរលើជនជាប់ចោទទាក់ទងទៅនឹងអង្គហេតុជម្លោះប្រដាប់អាវុធនោះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ។ ជាបន្តនេះ សូមប្រគល់វេទិកាជូនទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ប្រសិនបើមានសំណួរត្រូវសួរដល់ជនជាប់ចោទ សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តី៖**

សូមអរគុណលោកប្រធាន ។ គឺយើងខ្ញុំក៏អត់មានសំណួរដូចក្រុមរបស់យើងខ្ញុំ ក្រុមទីបីផងដែរ ដែលទាក់ទងទៅនឹងការចោទសំណួរទៅលើជម្លោះប្រដាប់អាវុធ ហើយយើងនឹងមានសំណួរផ្សេងទៀតទាក់ទងទៅការកិច្ចដំណើរការផ្សេងៗ និងអង្គហេតុផ្សេងៗទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ។ ទៀតបន្តគឺ សូមជូនវេទិកានេះទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។ ប្រសិនបើមានសូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំអត់មានសំណួរទេ ។ សូមអរគុណ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវី ។ ជាបន្ត សូមប្រគល់វេទិកានេះជូនទៅខាងមេធាវីការពារក្តី ។ប្រសិនជាមាន សូមអញ្ជើញ លោកមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ។ សូមគោរពលោកប្រធាន ។ ខាងមេធាវីការពារក្តីយល់ឃើញថា លោកជំទាវចៅក្រម បានសួរពីម្សិលមិញហ្នឹង គឺថាភាសាខ្មែរយើងថា វាអស់អាថ៌ អស់នោមទៅហើយ ដូច្នេះ

ហ្នឹង វាមិនដឹងជារកអីទៅសួរទៀតកើតទេ ។ ដូច្នេះ ខ្ញុំខាងមេធាវីការពារមិនមានសំណួរទេនាំច្រំដែល ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ ចុះខាងមេធាវីការពារអន្តរជាតិ?

ចុះអស់លោក? សូមអញ្ជើញលោក ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណ លោកប្រធាន ។ មេធាវីការពារក្តីមិនមានសំណួរបន្ថែមចោទសួរទៅលើជនជាប់ចោទទាក់ទងទៅនឹងអង្គហេតុនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ ។ ចុះអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទទៀតទេ អំពីអង្គហេតុដែលកំពុងតែជជែកពិភាក្សាដេញដោលនេះ? ប្រសិនជាមានសូមអញ្ជើញ ។ បើគ្មានទេ ខ្ញុំខ្លួនឯងតាំងសំណួរមួយចំនួន ដល់ជនជាប់ចោទ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកបាននិយាយថា ប៉ុលពត បានយកថ្ងៃ០៦ មករា ឆ្នាំ១៩៧៨ ជាទិវាជ័យជម្នះលើកងទ័ពវៀតណាម តើលោកពិតជានិយាយដូច្នេះមែនទេ?

[១៥:៥៤:១៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំពិតជានិយាយដូច្នេះ ហើយមីទ្ទិងនេះក៏មានខ្លឹមសារយ៉ាងនេះដែរ ។

**ស៖** បើដូច្នេះ តើលោកអាចនិយាយប្រាប់ដល់អង្គសវនាការបានទេ ថាតើហេតុផលដូចម្តេចទៅទើប ប៉ុល ពត កំណត់យកថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ជាទិវាធ្វើមីទ្ទិងប្រកាសអំពីជ័យជម្នះរបស់ខ្លួនលើកងទ័ពវៀតណាមនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មុនថ្ងៃ០៦ មករា នេះកងទ័ពវៀតណាមគេរើលុកចូលទឹកដីកម្ពុជាជ្រៅ ។ ដូច្នេះ កងទ័ពរបស់ប៉ុល ពត ហ្នឹង រើដេញចេញ ផុតមិនដឹងប៉ុន្មានថ្ងៃមុនទេ មួយថ្ងៃពីរមុន០៦ មករា ដល់០៦ មករា ហ្នឹង គាត់ធ្វើបុណ្យ គាត់ធ្វើមីទ្ទិងមួយ ។ នេះសូមបញ្ជាក់ប៉ុណ្ណោះ ។

**ស៖** សំណួរមួយទៀត តើលោកបានដឹងទេ អំពីការវ៉ៃលុកលុយរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យចូលទៅទឹកដីវៀតណាម?

**ឆ៖** រឿងនេះមិនមានឯកសារអីច្បាស់លាស់ទេ ខ្ញុំអត់បានឃើញឯកសារអីបានច្បាស់លាស់ទេ អត់ទាន់ប៉ាានឆ្លើយថាម៉េចទេ ។ សូមទោស ។

**ស៖** លោកដែលទទួលព័ត៌មាននេះទេ? ពីព្រោះអ៊ីចេះយើង បញ្ហាយើងមានសញ្ញាណពីរ ដែលមានការកត់សម្គាល់ ។ ទីមួយ យើងប្រើពាក្យ ជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាម ។ បញ្ហាទីពីរ គឺលោកបាននិយាយហើយ ថាវាមានទៅមានមក ។ និយាយរួម បើនិយាយពីពាក្យសាមញ្ញកម្ពុជាគឺថាវាមានទៅ វាមក ទាំងសងខាង ទាំងកម្ពុជា ទាំងវៀតណាម អានេះការនាំឲ្យប៉ះទង្គិចផ្នែកខាងប្រដាប់អាវុធនេះ ហើយនេះបញ្ហាទីមួយ។ ហើយបញ្ហាទីពីរនេះ គឺការកត់សម្គាល់របស់ខ្ញុំឃើញដូច្នេះថាការដែលចាប់ជនជាតិវៀតណាមទាំងបីប្រភេទ ដែលយើងបានបែងចែករួចហើយនេះ បញ្ជូនមកដល់ស-២១ នៅក្នុងនោះមានមនុស្សមួយចំនួនដែលយើងកំណត់ថា ចាប់នៅលើទឹកដីវៀតណាម នេះដែលនាំឲ្យមានការចាប់អារម្មណ៍ រវាងពាក្យថា ជម្លោះនេះ ហើយពាក្យថា មានទៅ មានមក ។

[១៥:៥៦:៥៦]

**ឆ៖** អរគុណលោកប្រធាន ។ ព្រឹកមិញ យើងឃើញ ខ្ញុំបានអានជូនលោកប្រធានហើយ ក្នុងចំណោមចំនួនដប់ប្រាំពីរនាក់ មានប្រាំមួយនាក់ចារនៅក្នុងនោះថា ចាប់ក្នុងទឹកដីវៀតណាម ខ្ញុំទទួលស្គាល់ឯកសារនេះ គឺជាឯកសារពិត ។ ក៏ប៉ុន្តែ ព័ត៌មានដែលបានទទួលអំពីប្រតិបត្តិការសឹក ចូលទៅដល់ទឹកដីគេ ខ្ញុំនៅមិនចាំថាបានទទួល ។ ក៏ប៉ុន្តែ ជាក់ស្តែងនៅពេលដែលខ្ញុំទៅរៀនវគ្គជាមួយនឹង ប៉ុល ពត នៅឆ្នាំ១៩៧៨ គាត់ថា ចង់ការពារទឹកដីកម្ពុជាឲ្យបាន យើងវ៉ៃតែអានឡុក ហើយនិងឡុកមិញ ។ វ៉ៃអាពីរហ្នឹង បានយើងការពារទឹកដីយើងបានយើងហើយ នេះគាត់និយាយប៉ុណ្ណឹង ។ ដូច្នេះ បានន័យខ្ញុំតែងតែនិយាយថា វាមានទៅ វាមានមក ហើយពេលដែលវៀតណាម គេចូលមកដល់ទឹកដីខ្មែរ មិនដឹងជាជម្រៅណា ខាងផ្លូវលេខ១ ក៏មិនដឹងជម្រៅណា ហើយខាងផ្លូវលេខ១៣ ក៏មិនដឹងជម្រៅណា ខ្ញុំអត់ដឹង ។ នេះសូមជម្រាបដោយត្រង់ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ អ៊ីចឹងដោយសារ ដំណើរការសវនាការដេញដោលលើអង្គហេតុជម្លោះប្រដាប់អាវុធនេះ ក៏ដល់ទីបញ្ចប់ហើយ លើកលែងតែសាក្សីពីររូប ដែលយើងអាក់ខានមិនបានធ្វើសវនាការ ស្តាប់

សក្ខីកម្មរបស់គាត់ តាមកម្មវិធីដែលបានគ្រោងទុក ដោយហេតុនៃកាលវេលាដែលមិនអំណោយផល ដោយមានការឃើតយ៉ាវក្នុងការជជែកពិភាក្សាដេញដោល ។ អ៊ីចឹង គឺយើងបានជម្រាបជូនភាគី និងសាធារណជនរួចហើយ ថាសាក្សីពីររូបនោះ យើងនឹងអញ្ជើញគាត់មកស្តាប់សក្ខីកម្មនៅក្នុងអង្គហេតុនៃប្រតិបត្តិការស-២១ និងជើងឯក នៅក្នុងកាលវេលាសមស្របទៅតាមកាលវិភាគដែលអង្គជំនុំជម្រះនឹងគណនា ហើយនិងជូនដំណឹងដល់ភាគីជាក្រោយ ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគីផងដែរថា អង្គជំនុំជម្រះនឹងលើកផ្អាកសវនាការនឹងថ្ងៃនេះតែត្រឹមនេះ ហើយលើកបន្តទៅសវនាការដេញដោលលើអង្គហេតុនេះ រហូតដល់ទៅថ្ងៃទី១៥ ថ្ងៃច័ន្ទ ទី១៥ ខែមិថុនា ឆ្នាំ២០០៩ ។ ហើយនៅក្នុងអង្គហេតុបន្ទាប់ ដែលយើងនឹងធ្វើសវនាការនោះគឺប្រតិបត្តិការស-២១ ហើយនិងជើងឯកផង នេះសូមភាគីទាំងអស់ជម្រាប ។

ដោយឡែកគឺ ថ្ងៃស្អែកយើងនឹងធ្វើកិច្ច បើកកិច្ចប្រជុំត្រៀមរៀបចំដំណើរការសវនាការរបស់យើង ដោយសារមានបញ្ហាជាច្រើនដែលនាំឲ្យមានការរអាក់រអួល យើងធ្វើការពិភាក្សាគ្នាលម្អិតអំពីដំណើរការ ថាតើគួរតែយើងធ្វើតាមរបៀបណា? វិធីណា? ដែលល្អប្រសើដែលពន្លឿននៅក្នុងកិច្ចដំណើរការសវនាការរបស់យើងហ្នឹង បានឆាប់រហ័ស ។

អ៊ីចឹង គឺអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយថ្ងៃស្អែក គឺសូមអញ្ជើញភាគីចូលរួមនៅក្នុងកិច្ចប្រជុំតាមការកំណត់ជាធម្មតា គឺម៉ោងប្រាំបួនព្រឹក ។ អ៊ីចឹងខាងសាធា-រណជន គឺសូមជម្រាបថា ថ្ងៃស្អែកនេះ គឺអង្គជំនុំជម្រះមិនធ្វើសវនាការទេ គឺមានការប្រជុំពិភាក្សាផ្ទៃក្នុងផ្នែកបច្ចេកទេសនៅក្នុងគ្រប់គ្រង ក្នុងការដឹកនាំសវនាការធ្វើយ៉ាងណាឲ្យបានឆាប់រហ័សប៉ុណ្ណោះ ។ ដូច្នេះ មិនចាំចូលរួមទេខាងសាធារណជន គឺអញ្ជើញតែភាគីដែលមានការពាក់ព័ន្ធនៅក្នុងរឿងក្តីប៉ុណ្ណោះ ហើយព្រមទាំងខាងការិយាល័យរដ្ឋបាលផង ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅថ្ងៃស្អែក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី]*